# តម្រង់ផ្លូវប្រាប់ប្អូន



រៀបរៀងនិងសំដែងដោយ

សាមណេរ ផល សីហវឌ្ឍន៍

រៀបចំដោយ ចៅលោក ឡូ យុន សារឿន អាចរកបាន
ជំនួយ ដើម្បីដាក់ចូលក្នុង eLibrary of Cambodia
តុលា 2016

## អារម្ភកថា

មនុស្សយើងគ្រប់គ្នា គ្មានអ្នកណាចង់ឱ្យជីវិតរបស់ខ្លួនធ្លាក់ទៅរ សេចក្ដីអាក្រក់ ព្រោះការដើរខុសផ្លូវនោះទេ គឺសុទ្ធតែចង់ដើរលើវិថី ជីវិតដ៏ត្រឹមត្រូវដូចគ្នាទាំងអស់ ។ តែភាគច្រើនមនុស្សយើងមិនសូវបា ពិចារណារកហេតុដែលនាំឱ្យខុសនោះឡើយ ហើយចេះតែទ្រាំរស់នេ ទាំងភាពនៃខ្លួនជាមនុស្សបរាជ័យយ៉ាងនេះរហូតទៅ ។

តាមពិត កត្តាដែលនាំឱ្យយើងឈានទៅរកផ្លូវខុសនោះមានច្រើ យ៉ាងដូចជា: ចរិតអធ្យាស្រ័យរបស់យើងផ្ទាល់ដែលមិនបានអប់រំ ចរិ អធ្យាស្រ័យរបស់ឪពុកម្ដាយឬក្រុមគ្រួសារ ប្រព័ន្ធនៃការអប់រំ សង្គ ឬបរិយាកាសដែលនៅជុំវិញ និងការសេពគប់ជាដើម ។ ប្រសិនបើចំណុ ទាំងអស់នេះល្អ នោះការរស់នៅរបស់យើង ក៏ងាយក្នុងការរកផ្លូវល្ សម្រាប់ដើរ តែបើចំណុចទាំងអស់នោះមិនល្អទេ នោះវាងាយជាទីបំផុ ក្នុងការងាករេទៅរកផ្លូវខុស វាមិនខុសពីការធ្វើដំណើរកាត់សមុទ្រដែល មានរលកធំៗនោះឡើយ គឺងាយជាទីបំផុតសម្រាប់ការលិច ។ ដើម្បីឱ្ កត្តាទាំងអស់នោះល្អបាន លុះត្រាតែឆ្លងកាត់នូវចំណុចទាំងឡាយ៥ គឺ :

ការអាន + ការស្ដាប់ + ការគិត + ការសម្រេចចិត្ត + ការអនុវត្តន៍

(((គោលដៅដែលអ្នកតែងតែរំពឹងទុក))) ។

# ទម្រង់ផ្លូវត្រាស់ទ្លូង




រៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

សាមណេរ ផល សីហាចន្ទ


សម្រាប់ជាធម្មទាន

ដើម្បីរួមចំណែកក្នុងការចែករំលែកនូវចំណេះដឹងខ្លះៗ ដែលខ្ញុំមានបន្តិចបន្តួច ឱ្យបានជាមគ្គុទ្ទេសសម្រាប់សាធារណជនអ្នកចង់បាននូវសេចក្តីសុខដែលអាស្រ័យនៅក្នុងលោកសន្និវាសនេះ ។ ខ្ញុំសម្រេចចិត្តថា សរសេរសៀវភៅមួយដែលមានឈ្មោះថា "តម្រង់ផ្លូវប្រាប់ប្អូន" ឯពាក្យថា បងឬប្អូន ដែលខ្ញុំបានប្រើនៅក្នុងសៀវភៅនេះ គឺក្នុងនាមជាភាតរភាពរវាងគ្នានិងគ្នា ។ ព្រោះយើងមាន ជាតិ គ្រួសារ សាសនាតែមួយ គឺជាតិខ្មែរ គ្រួសារខ្មែរ និងជាព្រះពុទ្ធសាសនាដូចគ្នា មានព្រះពុទ្ធជាបិតារួម ។ ហើយន័យមួយទៀត គឺខ្ញុំបានផ្តោតទៅលើស្រទាប់នៃក្រុមយុវវ័យ ដែលជាវ័យកំពុងតែមានខួរក្បាលបើកចំហរ រងចាំទទួលនូវចំណេះដឹងដែលមាននៅលើពិភពលោកយើងនេះ ។

ហើយខ្ញុំក៏សូមអភ័យទោសអំពីសំណាក់អ្នកអានគ្រប់រូបផងដែរ ប្រសិនបើការសរសេរមានការលើសហួសខ្វះខាតដោយបទបាតអក្ខរៈ ឬអត្ថន័យដែលមាននៅក្នុងសៀវភៅនេះ ព្រោះនេះគឺជាកិច្ចការទី១សម្រាប់រូបខ្ញុំទាំងផ្នែកខាងការរៀបរៀងនិងកុំព្យូទ័រ ។ ចំពោះការពិនិត្យផ្ទៀងផ្ទាត់វិញបានធ្វើជាច្រើនលើកច្រើនសារ តែសៀវភៅនេះពិតជានៅមានភាពខុសឆ្គងនិងខ្វះខាតជាមិនខាន ហេតុនេះសូមព្រះករុណាជាម្ចាស់ និងពុទ្ធ

បរិស័ទគ្រប់រូបដែលជាវិញ្ញូជន មេត្តាជួយរិះគន់ ដើម្បីជួយកែសម្រួលនិងស្ថាបនាផងចុះ ដើម្បីជាតិ សាសនា និងប្រទេសរបស់យើងទាំងអស់គ្នា។

ជាចុងក្រោយខ្ញុំសូមឧទ្ទិសនិងជូនបុណ្យកុសលទាំងអស់នេះ ដល់លោកឪពុក ឈ្មោះ អ៊ឹម ផល ដែលបានស្លាប់ទៅក្នុងឆ្នាំ២០០៥ និងអ្នកម្តាយឈ្មោះ ខេន ឌី ដែលជាអ្នកផ្តល់នូវកំណើតឱ្យខ្ញុំក្នុងភាពជាមនុស្សនេះ លោកឪពុក សួន ផន និង អ្នកម្តាយ ធី ម៉ានី ដែលរស់នៅក្នុងខេត្តក្រចេះ ស្រុកស្នួល ឃុំឃ្សឹម ភូមិឃ្សឹមក្រៅ ហើយនិងបុព្វការីជនទាំងអស់ ដែលជាអ្នកស្នេហាជាតិនិងសាសនា ទាំងអតីតនិងបច្ចុប្បន្ន សូមតាំងចិត្ត ជ្រះថ្លាអនុមោទនានូវបុណ្យកុសលទាំងអស់នេះ សូមអនុមោទនា !!!!។

វត្តរស្មីសោភណោរាម (សន្ទុង) ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

៦ ១២ ១១ ព.ស ២៥៥៣ ត្រូវនឹងថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩

ពីខ្ញុំព្រះករុណា អាត្មាភាព

សាមណេរ ផល សិលាធឡន៍

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងអំណរគុណចំពោះ

-ព្រះគ្រូចៅអធិការ ពុទ្ធខិរោ យូ ជួប ដែលបានផ្តល់កន្លែងសម្រាប់ខ្ញុំព្រះករុណាសិក្សារៀនសូត្រមករហូតដល់ពេលនេះ

-ព្រះគ្រូចៅអធិការវត្តស៊ីសុវត្ថិរតនារាម ចិន្តាធម្មោ ម៉ៅ វុឌ្ឍី ជួយផ្សព្វផ្សាយធម្មទាន

-ព្រះគ្រូចៅអធិការវត្តព្រៃកប្បស្សី ព្រះនាម សែម សុធារី ដែលបានអនុញ្ញាតិឱ្យខ្ញុំព្រះករុណាប្រើប្រាស់ភ្លើងក្នុងការវាយអត្ថបទ និងព្រះគុណម្ចាស់គ្រប់ព្រះអង្គដែលគង់នៅក្នុងវត្តនោះ មានព្រះគុណម្ចាស់ គា ជាដើម បានជួយផ្សព្វផ្សាយធម្មទាន

-ព្រះគ្រូចៅអធិការវត្តរស្មីសាមគ្គី ព្រះនាម មណ្ឌិតោ ហុង ស៊ីថាត និងអាចារ្យគណៈកម្មការ

-លោកម្ចាស់ សាសនរតោ ប៊ុន រ៉ា វត្តធម្មតេជះ និងអាចារ្យគណៈកម្មការ

-លោកម្ចាស់ ឋានរដ្ឋានិយោ ឡាង រដ្ឋា វត្តកោះសុក្រំ

-សាមណេរ ឈាង គីមយ៉ាង -សាមណេរ ម៉ៅ រ៉ាមី

-បងឧបាសក ជួន ណាត -និស្សិត ពាន រ៉ាវី វត្តព្រៃកប្បស្សី

-លោកតា អាចារ្យ អ៊ុំ សាមុត -លោកតា អាចារ្យ គឹម ហាន

-លោកអ៊ំ ឧបាសក ជួង ងី -លោកអ៊ំឧបាសិកា ស្រេង លឹមហេង

-បងឧបាសក វន ចាន្នី

ដែលជាអ្នកជួយជ្រុំជ្រែងក្នុងការផ្សព្វផ្សាយធម្មទាន

-លោកពូ ផន ប្រុសពៅ ជាអ្នកជូនដំណើរក្នុងការផ្សព្វផ្សាយធម្មទាន

-បងប្រុស អ៊ំ គឹមអ៊ិន ដែលបានអនុញ្ញាតិឱ្យខ្ញុំព្រះករុណាអាត្មាភាព

ប្រើប្រាស់ភ្លើង ក្នុងការវាយអត្ថបទ

និងព្រះករុណាជាម្ចាស់គ្រប់ព្រះអង្គ ពុទ្ធបរិស័ទគ្រប់រូប ដែលបានបរិច្ចាគថវិកាបោះពុម្ពសៀវភៅឱ្យបានជារូបរាងឡើង ហើយនិងព្រះករុណាជាម្ចាស់ញាតិញោមដទៃទៀត ដែលមានឧបការៈក្នុងកិច្ចការធម្មទាននេះ ដោយអំណាចនៃធម្មសទានដែលកើតឡើងព្រោះកំលាំងសាមគ្គីភាពរបស់ពុទ្ធបរិស័ទ សូមលើកនូវមហាកុសលនេះ ប្រគេនចំពោះគ្រូឧជ្ឈាយាចារ្យមាតាបិតានិងញាតិកាទាំងឡាយរបស់ព្រះគុណម្ចាស់ព្រមទាំងញាតិញោមទាំងអស់ សូមទទួលនូវសម្បត្តិដ៏ប្រសើរនេះឱ្យបានគ្រប់ៗគ្នា

សូមអនុមោទនា !!!!។

ហើយខ្ញុំព្រះករុណាអាត្មាភាព សូមអភ័យទោសចំពោះព្រះករុណាជាម្ចាស់និងពុទ្ធបរិស័ទទាំងអស់ ដែលបានចូលថវិកាហើយតែមិនបានដាក់

ឈ្មោះឬព្រះនាម ព្រោះកាលក្នុងពិធីបុណ្យភ្ជុំនោះ លោកអ៊ំអាចារ្យនិង គណៈកម្មការគាត់មានការមមាញឹកច្រើន ហេតុនេះហើយក៏មិនបានកត់ ឈ្មោះខ្លះ តែទោះជាយ៉ាងណាក៏ថវិការបស់ញាតិញោមមិនបានបាត់ទៅ ណាទេ គឺមានគ្រប់ចំនួនទាំងអស់ ។ ដូច្នេះ ប្រសិនបើព្រះគុណម្ចាស់ ញាតិញោមមានបំណងចង់ដាក់ឈ្មោះ វិរៈគន់ដើម្បីស្ថាបនា សូមទាកទង តាមរយៈលេខ ០៩៧ ៩១ ៣៨ ២០៧ នោះខ្ញុំព្រះករុណាអាត្មាភាព និងដាក់ឈ្មោះទាំងនោះទៅ ក្នុងសៀវភៅដែលត្រូវបោះពុម្ពលើកក្រោយ ទៀត សូមអរព្រះគុណ និង សូមអរគុណ ។

## នាមអ្នកមានឧបការៈក្នុងការរៀបរៀង

-លោកម្ចាស់គ្រូ ធម្មាចារ្យ គុបសីលោ អ៊ុំ គីមអាន ជួយពិនិត្យខ្លឹមសារធម៌ ជួយផ្សព្វផ្សាយធម្មទាន និង ជួយទំនាក់ទំនងរោងពុម្ព

-ម្ចាស់គ្រូ ធម្មាចារ្យ ឋិតញ្ញាណោ ឡាញ់ សារឿន វត្តស្រីអ៊ុំប្រសិទ្ធិ ជួយពិនិត្យខ្លឹមសារធម៌ និង អក្ខរាវិរុទ្ធ

-លោកម្ចាស់ វជិរប្បញ្ញោ មហា គូ សុភាព វត្តនិគ្រោធវ័នតល់ទទឹង ជួយពិនិត្យខ្លឹមសារធម៌

-លោកម្ចាស់ ឧទ្ទេសាចារ្យ អត្ថកោវិទោ ខុម សុខឃាង ជួយកែអក្ខរាវិរុទ្ធ

-លោកម្ចាស់ ឧទ្ទេសាចារ្យ ឧត្តមប្បញ្ញោ ប៉ុល សុវណ្ណី ជួយកែអក្ខរាវិរុទ្ធ

-លោកម្ចាស់ សុន្ទរបញ្ញោ ផាវ ផារិទ្ធ ជាសមណសិស្សនៃពុទ្ធិកវិទ្យាល័យក្រពើហា ជួយកែអក្ខរាវិរុទ្ធ

-លោកម្ចាស់ ធម្មទិន្នោ ណុប ពិសិដ្ឋ សមណសិស្សនៃពុទ្ធិក អនុវិទ្យាល័យ សុវណ្ណគិរី (ជើងឆ្នុក) ខេត្តកំពង់ចាម ជួយកែអក្ខរាវិរុទ្ធ

-សាមណេរ គិន សុជា ជាសមណសិស្សនៃពុទ្ធិវិទ្យាក្រពើហា ជួយកែអក្ខរាវិរុទ្ធ

-លោកគ្រូ សាស្ត្រាចារ្យ ម៉ម សឿង ជួយកែអក្ខរាវិរុទ្ធ និងសម្រួលសេចក្តី

# មាតិកា

១ មកដល់ប្អូន១ជាទីស្រឡាញ់.....................................១
២ មនុស្សមានប្រយោជន៍.........................................៤
៣ ពាក្យថាមិត្ត....................................................៦
៤ មិត្តមាន ២ យ៉ាង.................................................៧
៥ អំពីបុគ្គលពាល ..................................................៩
៦ ប្រភេទនៃបុគ្គលពាល ........................................១១
៧ អ្នកបួសមាន ៨ ប្រភេទ ......................................១៦
៨ ជនពាលដូចជាអមិត្ត បណ្ឌិតដូចពួកញាតិ ..................២៣
៩ តាបស់ឱ្យដំបូន្មានដល់បុត្រ ....................................២៤
១០ ភ័យឧបទ្រពនិងឧបស័គ្គកើតមានព្រោះជនពាល ...............២៧
១១ រឿងអកិត្តបណ្ឌិត មិនចង់ជួបប្រទះជនពាល ....................៣៤
១២ បណ្ឌិតធ្វើខ្លួនឯងនិងអ្នកធ្វើខ្លួនឱ្យចម្រើន ....................៣៨
១៣ កំណាព្យស្តាយវ័យកុមារ .......................................៤៥
១៤ អំពីការសេពគប់មិត្ត ..........................................៥១
១៥ មិត្តដែលមិនគួរសេពគប់មាន ៤ ប្រភេទ .....................៥២
១៦ កំណាព្យទេ!មិនត្រូវការ ទេ! ...................................៥៦
១៧ មិត្តគួរសេពគប់មាន ៤ ប្រភេទ ...............................៥៨
១៨ ចរិតមនុស្ស ......................................................៦១
១៩ ចរិតមាន ៦ យ៉ាង ...............................................៦៣

២០ វិធីមើលចរិតមនុស្ស ..........................................៧៤
២១ សំគាល់ដោយឥរិយាបថ ..........................................៧៥
២២ សំគាល់ដោយកិច្ចការ ..........................................៧៨
២៣ សំគាល់ដោយភោជនវិការបរិភោគ ..........................................៧៩
២៤ សំគាល់ដោយការមើល ..........................................៨០
២៥ សំគាល់ដោយការប្រព្រឹត្តធម៌ ..........................................៨១
២៦ អស្មិមានៈ ៩ យ៉ាង ..........................................៨៩
២៧ ធម៌របស់សប្បុរសមាន ៧ យ៉ាង ..........................................៩៥
២៨ សប្បុរសធម៌ ៧ យ៉ាងទៀត ..........................................៩៨
២៩ កំណាព្យអ្វីៗទាំងអស់កើតព្រោះគំនិត ..........................................១០២
៣០ ការគិតតែពីខ្លួនឯង ..........................................១០៥
៣១ វិធី ៦ យ៉ាងដើម្បីទាកទាញសន្ដានចិត្តមនុស្ស ..........................................១១៣
៣២ វិធី ១២ យ៉ាងធ្វើឱ្យអ្នកដទៃស្ដាប់តាមខ្លួន ..........................................១១៥
៣៣ មូលដ្ឋាន ៤ យ៉ាងធ្វើឱ្យអ្នកដទៃជឿទុកចិត្ត ..........................................១១៧
៣៤ វិធីកែមនុស្ស ៩ យ៉ាងដែលមិនឱ្យគេខឹងច្រឡោត ..........................................១១៩
៣៥ សក្ខណៈរបស់បុគ្គលដែលអាចជួយបានមាន ២ យ៉ាង ..........................................១២១
៣៦ ប្រភេទនៃការយល់របស់មនុស្ស ..........................................១២៣
៣៧ រឿងបុរសលីងស្រូវ ..........................................១២៥
៣៨ កំណាព្យខ្លួនទីពឹងខ្លួន ..........................................១៣១
៣៩ ទស្សនៈ និង ខ្លឹមសារខ្លីៗ ..........................................១៣២

## ១-មកដល់ប្អូនជាទីស្រលាញ់

បងមានបំណងចង់ឱ្យប្អូនៗគ្រប់គ្នា ក្លាយជាមនុស្សល្អពិតប្រាកដ ជាមនុស្សចេះលះបង់នូវសេចក្តីកំណាញ់ និងសេចក្តីសុខផ្ទាល់ខ្លួន ។ លើសពីនេះ ប្អូនត្រូវមានសេចក្តីអត់ធន់ រឹងប៉ឹងស្វាហាប់ មានអធ្យាស្រ័យតស៊ូព្យាយាមហើយឈ្លាសវៃ មិនលះបង់នូវតួនាទី ។ ជាមួយគ្នានេះដែរ បងសូមឱ្យប្អូនត្រូវតែជាមនុស្សសុភាពរាបសារ មានចរិយាទន់ភ្លន់ ព្រោះថាមនុស្សដែលសុភាពរាបសារមានចរិយាទន់ភ្លន់ ពុំមែនមានន័យថាជាមនុស្សទន់ខ្សោយនោះទេ ។ រីឯមនុស្សដែលរឹងប៉ឹងម៉ឺងម៉ាត់ស្វាហាប់ ក៏មិនមែនបានសេចក្តីថា ជាមនុស្សកាចសាហាវ ប្រាសចាកមនុស្សធម៌នោះឡើយ ។ ប្អូនត្រូវយកគុណសម្បត្តិទាំងពីរប្រការនេះ មករួមបញ្ចូលគ្នាឱ្យតាំងនៅក្នុងខ្លួនប្អូនឱ្យបានកុំខាន គឺរឹងប៉ឹងស្វាហាប់អត់ធន់ទន់ភ្លន់និងសុភាពរាបសារ ចេះខ្លាចក្រែងចំពោះទឹកចិត្តអ្នកផងទាំងពួងដែលរស់នៅក្នុងសង្គមជាមួយគ្នា ពោលគឺគ្រប់គ្នាដែលរស់នៅក្នុងសង្គម សុទ្ធតែត្រូវការនូវមនុស្សមានចរិយាប្រកបដោយសីលធម៌ជានិច្ច ។

ក្នុងជីវិតដែលរស់នៅសព្វថ្ងៃក៏ដូចគ្នាដែរ បងបានព្យាយាមអប់រំ និងដាស់តឿនរាល់ពេល ឱ្យប្អូនតាំងចិត្តសិក្សារៀនសូត្រ រៀបចំខ្លួនឱ្យ

ស្ថិតនៅក្នុងភាពជាមនុស្សល្អ មិនឱ្យប្អូនប្រព្រឹត្តនូវរាល់អំពើដែលឥតប្រយោជន៍ តែបើពេលណាដែលប្អូនប្រព្រឹត្តភ្លាំងភ្លាត់ដោយហេតុណាមួយនោះ បងនឹងព្យាយាមជួយប្អូនជានិច្ច ។ ពំនោលមកទាំងប៉ុន្មាននេះ គឺបងចង់បញ្ជាក់អំពីសន្តានចិត្តរបស់បងប្រុស ដែលមានចំពោះប្អូនៗគ្រប់រូប ។ បងសូមឱ្យប្អូនចងចាំជានិច្ចថា រាល់បញ្ហាដែលកើតឡើង សូមប្អូនប្រឹក្សាពិគ្រោះយោបល់ជាមួយនឹងក្រុមគ្រួសារ ជាពិសេសគឺមាតាបិតារបស់យើងកុំលាក់លៀមឱ្យសោះ ព្រោះមិនមានអ្នកណាដែលស្មោះត្រង់ និងប្រុងប្រៀបដើម្បីជួយប្អូន ឱ្យក្រៃលែងជាងមាតាបិតាយើងឡើយ ។ ពេលដែលពួកគាត់បានដឹងហើយ មិនថាបញ្ហានោះ លំបាកលំបិនយ៉ាងណានោះទេ មាតាបិតា លោករមែងរួមគ្នាដោះស្រាយកែខៃគ្រប់មធ្យោបាយទាំងអស់ ដើម្បីកូនៗ ។ បន្ទាប់ពីមាតាបិតាទៅ គឺនៅមានរូបបងម្នាក់ទៀតដែលជាអ្នកចូលរួមដោះស្រាយនូវរាល់បញ្ហានោះដែរ ព្រោះបងជាអ្នកទទួលនូវភារៈក្រោយពីមាតាបិតាមក ហើយនឹងរីករាយជួយប្អូនៗជានិច្ចក្នុងនាមជាបងប្រុស ។

ចូរប្អូនចងចាំថា កាលបើប្អូនបំពេញតួនាទីដោយសុចរិត ដោយការឆ្លាតវៃ មានសេចក្តីស្មោះត្រង់និងកតញ្ញូ ប្អូនរមែងទទួលបាននូវសេចក្តីរីករាយ ដោយរលឹកឃើញនូវអំពើដ៏បរិសុទ្ធរបស់ខ្លួន ហើយប្អូន

និងបានទទួលនូវផលគឺសេចក្ដីសុខ មានការរីកចម្រើនទៅថ្ងៃអនាគត សម្រាប់ប្អូន ព្រមទាំងក្រុមគ្រួសារនិងប្រទេសជាតិយ៉ាងពិតប្រាកដ ។

ខេត្តកណ្ដាល ថ្ងៃទី ៧ កើត ខែ ផល្គុន ព.ស. ២៥៥២

ពីបងប្រុសរបស់ប្អូន

# មនុស្សមានប្រយោជន៍

ប្អូនត្រូវហាត់ធ្វើខ្លួនឱ្យសុភាពរាបសារ មានការព្យាយាម ចេះអើពើជួយធ្វើការអ្នកដទៃដោយសេចក្ដីពេញចិត្ត នឹងធ្វើខ្លួនឱ្យជាមនុស្សមានប្រយោជន៍ ដើម្បីជាប់ជាឧបនិស្ស័យ ដល់ធំឡើងប្អូនបានធ្វើជាមនុស្សល្អ ជាមនុស្សមានសេចក្ដីចម្រើននិងមាំទាំក្នុងជីវិត ។

ប្អូននៅតូចៗ ប្អូនធ្វើអ្វីគ្រប់យ៉ាង ត្រូវឱ្យនៅក្នុងការហ្វឹកហាត់លុតដំនិងកសាងខ្លួន បើប្អូនមានស្មារតីកសាងខ្លួនជានិច្ចហើយនោះ ប្អូនធ្វើអ្វីៗតែងមានរបៀបរៀបរយ កាលបើមានរបៀបរៀបរយល្អហើយ ប្អូនអាចរៀនសូត្រនិងធ្វើការងារផ្សេងៗ បានដោយត្រឹមត្រូវ ហើយតទៅមុខប្អូននឹងបានទៅជាមនុស្សទទួលបានសេចក្ដីសម្រេច និងសេចក្ដីចម្រើនដល់ខ្លួនឯង ព្រមទាំងសង្គមគ្រួសារ សង្គមជាតិ នាពេលអនាគតជាក់ជាមិនខាន ។

នៅក្នុងភាពជាមនុស្សមានប្រយោជន៍ ប្អូនត្រូវតែធ្វើខ្លួនជាមនុស្សដូចតទៅ :

១- ជាកុលបុត្រ កុលធីតារបស់មាតាបិតា

២-ជាសិស្សល្អរបស់លោកគ្រូ អ្នកគ្រូ

៣- ជាមិត្តល្អរបស់មិត្ត

៤-ជាប្រជាពលរដ្ឋដ៏ល្អរបស់ប្រទេសជាតិ

៥- ជាសាវ័កដ៏ល្អរបស់ព្រះសម្មាសម្ពុទ្ធ ។

ប្អូនត្រូវដឹងថា ការដែលធ្វើខ្លួនឱ្យក្លាយជាមនុស្សល្អ គឺកម្រនឹងបានណាស់ ប៉ុន្តែវាក៏មិនមែនលំបាកដល់ថ្នាក់មនុស្សធ្វើមិនកើតនោះទេ ព្រោះវាទាក់ទងទៅនឹងឧបនិស្ស័យ ការអប់រំ និង ការសេពគប់ ។ នៅក្នុងជីវិតប្រចាំថ្ងៃ ប្អូនអាចដឹងដោយខ្លួនឯងថា មានមនុស្សជាច្រើនប្រភេទច្រើនយ៉ាង ខ្លះល្អ ខ្លះអាក្រក់ ខ្លះស្លូត ខ្លះកាច ខ្លះខ្ជិល ខ្លះឧស្សាហ៍ ខ្លះចូលរៀន ខ្លះគេចសាលា និងខ្លះទៀតនោះ សេពគ្រឿងញៀនកញ្ឆាផឹកសុរាបង្កបញ្ហាគ្រប់ទីកន្លែង ធ្វើឱ្យគេឯងក្រែងញញើត ។ ក្នុងចំណោមបុគ្គលទាំងនោះ បុគ្គលខ្លះ ហេតុតែចង់ឱ្យគេខ្លាចនិងសរសើរ ក៏ធ្វើឫកជាគ្រាន់បើ ប្រព្រឹត្តនូវអំពើបាបមិនញញើតដៃឡើយ ។ ដោយឡែកបុគ្គលមួយចំនួនទៀត ជាមនុស្សចេះកោតក្រែងអ្នកដទៃ ជួយធ្វើកិច្ចការមាតាបិតា យកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងគោរពតួនាទីបានល្អ តែក្រោយមកគេមានមិត្តភក្តិច្រើន ដែលតែងតែនាំឱ្យគេធ្វើអំពើទុច្ចរិតផ្សេងៗ មានការលួចប្លន់កាប់សម្លាប់និងដើរលេងច្រើនជាដើម ។ដោយវង្វេងនឹងការបង្ខំរបស់បាបមិត្ត គេក៏ទំលាក់ចោលនូវសេចក្តីល្អរបស់ខ្លួនទៅជាមនុស្សពាល ប្រាស

ចាកគន្លងធម៌ ធ្វើឱ្យអ្នកដែលធ្លាប់រាប់អាន បែរជាស្អប់ខ្ពើម។ កាលដែលបងបានពោលមកនេះ មិនមែនមានន័យថា ឱ្យតែមិត្តសុទ្ធតែអាក្រក់នោះទេ មិត្តល្អក៏មានដែរ តែមិត្តអាក្រក់មានច្រើនជាង។ តទៅនេះ បងចង់ឱ្យប្អូនស្វែងយល់អំពីមិត្តឱ្យបានច្រើន ព្រោះមនុស្សម្នាក់ៗ សុទ្ធតែមានមិត្ត ឥតមានអ្នកណាមួយដែលថា គ្មានមិត្តនោះទេ គ្រាន់តែតិចនិងច្រើនតែប៉ុណ្ណោះ ។

## ពាក្យថាមិត្ត

មិត្តមកពី មិទ+ត[១] = មិត្ត ប្រែថា បុគ្គលអ្នកចងនូវជនដទៃចំពោះខ្លួន ឬ អ្នករាប់អាន គឺស្រលាញ់នូវជនដទៃ រាប់អានគ្នា ឬ ប្រែបានម្យ៉ាងទៀតថា "អ្នកដែលរាប់អានគ្នាជិតដិត មនុស្សដែលស្រលាញ់រាប់អានគ្នាយ៉ាងជិតដិត"[២] បើតាម មិទ ធាតុ អាចប្រែបានច្រើនយ៉ាង គឺអាចប្រែថា "អាណិតអាសូរ ស្នេហា" យ៉ាងនេះជាដើម ។ តាមសេចក្តីនៃពាក្យខាងលើនេះ បានបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា បុគ្គលណា

១ បទានុក្រម ធម្មបទ ភាគ ៣ ទំព័រ ២៧៣ បន្ទាត់ទី ៣

២ វចនានុក្រម សម្តេច ជួនណាត ទំព័រ ៨៨៨ បន្ទាត់ទី ១៥

ក៏ដោយ មិនថាអ្នកនោះ មានអាយុតិចអាយុច្រើន គុណធម៌តិចគុណធម៌ច្រើន ចំណេះដឹងតិចចំណេះដឹងច្រើន ត្រកូលទាបខ្ពស់ យសសក្តិតូចធំ ភេទដូចគ្នាឬផ្សេងគ្នា ជាព្រះសង្ឃ យាយជីតាជី អ៊ំ ពូ មីង យាយតា មហាមាត្យ ព្រះរាជា មាតាបិតា ណាៗ ដទៃណាទៀតទេ ដោយហោចទៅ សូម្បីសត្វតិរច្ឆានក៏អាចឈ្មោះថា ជាមិត្តបានដែរ។ ព្រោះអ្នកទាំងនោះ សុទ្ធតែអាចប្រព្រឹត្តធ្វើនូវសេចក្តីស្រលាញ់ពេញចិត្ត រាប់រកគ្នាទៅវិញទៅមកដោយពិតប្រាកដ។ ហេតុនេះ ចូរប្អូនស្វែងយល់អំពីពាក្យថា មិត្តនេះឱ្យបានទូលាយ ។ ចំណែកការហៅជំនួសពាក្យថាមិត្តនោះសោត ក៏មានច្រើនណាស់ដែរ ។ អ្នកខ្លះគេប្រើពាក្យថា សម្លាញ់ ពួកម៉ាក ម្រាក់ ខ្លើ ភឿន កនយើង គ្នាយើង ជាដើម តែទោះជាយ៉ាងនេះក្តី ក៏នៅតែមានន័យថា ជាមិត្ត ដដែល។ ត្រង់ស័ព្ទថា មិត្ត ឬ មិត្រ ទាំងពីនេះ មានសេចក្តីនិងន័យដូចគ្នា គ្រាន់តែ មិត្ត សព្ទនេះ ជាភាសាបាលី មិត្រ សព្ទនេះ ជាភាសាសំស្ក្រឹតតែប៉ុណ្ណោះ ។

## ✌ មិត្តមាន ២ យ៉ាង

ចំពោះមិត្តដែលប្អូនតែងតែសេពគប់នោះមានពីរយ៉ាង គឺៈ

**១ -បាបមិត្ត**

**២ -កល្យាណមិត្ត**

**បាបមិត្ត** ជាមិត្តដែលអាក្រក់ ធ្វើនូវអំពើមិនជាប្រយោជន៍ដល់មិត្ត តែងនាំមិត្តឱ្យធ្វើនូវអំពើទុច្ចរិតផ្សេងៗ មានការដើរលេងលួចប្លន់ល្បែងស៊ីផឹក ហិតការប្រើគ្រឿងញៀនជាដើម។ ហើយតែងបោះបង់ចោលមិត្តនូវពេលមានអាសន្ន ឬ ខ្លួនសុខស្រួល (រកស៊ីមានបាន)។ ពាក្យថា បាបមិត្ត អសប្បុរស បុគ្គលពាល ពាក្យទាំងបីនេះ មានន័យដូចគ្នា ខុសតែពាក្យហៅតែប៉ុណ្ណោះ ។

**កល្យាណមិត្ត** ជាមិត្តដែលចេះជួយគ្នា មិនបោះបង់ចោលមិត្តនៅពេលមានអាសន្ន ឬ ខ្លួនបានសេចក្តីសុខស្រួល តែងផ្តល់នូវចំណេះដឹងជាច្រើនដល់មិត្ត គឺរមែងនាំមិត្តឱ្យធ្វើតែអំពើណាដែលល្អៗ និង ស្មោះត្រង់ចំពោះមិត្ត ។ ពាក្យថា កល្យាណមិត្ត និង បណ្ឌិត ទាំងពីរនេះក៏មានន័យដូចគ្នាដែរ ព្រោះមានកាយវាចាចិត្ត និងដឹកនាំអ្នកដទៃដែលធ្វើតាមខ្លួនឱ្យទៅរកសេចក្តីល្អដូចគ្នា ។

" គុណតម្លៃរបស់មនុស្ស ដែលប្រសើរជាងសត្វតិរច្ឆាននោះ
គឺដោយអាស្រ័យស្មារតី "





ឥឡូវនេះដើម្បីឱ្យយល់ច្បាស់អំពីមិត្ត ចូរប្អូនសិក្សាអំពីលក្ខណៈរបស់បុគ្គលពាល និង បណ្ឌិតខាងក្រោមនេះបន្តិចសិន ។

## អំពីបុគ្គលពាល

ដើម្បីឱ្យជីវិតរបស់យើងមានសិរីសួស្តីនិងរីកចម្រើនបាននោះ គឺយើងមិនត្រូវយកបុគ្គលពាលមកធ្វើជាមិត្តឡើយ ។ ការគប់រក ការមានបុគ្គលពាលនោះជាសម្លាញ់ ការចូលជាពួកជាមួយនឹងបុគ្គលពាលនោះឈ្មោះថាយកមកជាមិត្ត ឬ កិរិយាសេពគប់ ។ តើប្អូនដឹងទេថា នរណាខ្លះជាបុគ្គលពាល ?

បុគ្គលពាល គឺជាបុគ្គលដែលកាត់បង់ចោលនូវប្រយោជន៍ទាំងឡាយពីរ គឺប្រយោជន៍ក្នុងជាតិនេះ១ និងប្រយោជន៍ជាតិខាងមុខ១ ។

### កាត់បង់ប្រយោជន៍ជាតិនេះមាន ៤ ប្រការគឺ:

១-ជាមនុស្សខ្ជិលច្រអូសមិនធ្វើការ និង មិនស្វែងរកវិជ្ជាជាគ្រឿងចេះដឹងនាំឱ្យកើតបញ្ញា

២- មិនរក្សាទ្រព្យរបស់ខ្លួន ដោយឧបាយនៃបញ្ញា

៣- ចិញ្ចឹមជីវិតដោយសេចក្តីប្រមាទ គឺមានទ្រព្យតិច ចាយច្រើន

៤-សេពគប់នូវបុគ្គលដែលប្រព្រឹត្តនូវអំពើទុច្ចរិតមកធ្វើជាមិត្ត ។

**កាត់បង់នូវប្រយោជន៍ជាតិខាងមុខមាន ៥ ប្រការ គឺៈ**

១- មិនមានសទ្ធាជឿក្នុងគុណព្រះរតនត្រ័យ

២- មិនរក្សាសីលប្រាំ សីលប្រាំបី សីលដប់ ជាគ្រឿងរក្សាកាយ វាចា ឱ្យមានរបៀបរៀបរយ ក្នុងភាពជាមនុស្ស

៣- មិនមានសុតៈ គឺការស្តាប់នូវព្រះធម៌ រឺចំណេះដឹងប្លែកៗ

៤- មិនមានចាគៈ គឺការបរិច្ចាគទាន រឺលះបង់ផ្សេងៗ ។

៥-មិនមានបញ្ញាពិចារណាសង្ខារថា ជីវិតមិនទៀងដូច្នេះជាដើម រឺមិនជឿអំពីច្បាប់ដាច់ខាតរបស់ធម្មជាតិ ។

បុគ្គលដែលកាត់ចោលនូវប្រយោជន៍ទាំងពីរប្រការនេះឯង លោកហៅថា បុគ្គលពាល ។ ហើយម្យ៉ាងទៀត ដែលលោកហៅថា ពាល ព្រោះរស់នៅ មិនប្រកបដោយបញ្ញា គឺដោយហេតុត្រឹមតែការដកដង្ហើមចេញ និងដកដង្ហើមចូល ។

## ប្រភេទនៃបុគ្គលពាល

**ពាល** មកពី ពល+ណ លុប ណ ចេញ ហើយដោយអំណាច ណ នេះ អាចធ្វើ ព ទៅជា ពា បានជា ពាល ប្រែថា ល្ងង់ ខ្លៅ ឆោត ក្មេង ខ្ចី កាច សាហាវ មិនមានគុណធម៌ ។

ពាក្យថា ពាល មួយម៉ាត់នេះ មានសេចក្តីទូលំទូលាយណាស់ សូម្បីតែជនល្ងង់ឆោត មិនចេះអក្សរជាដើម ក៏លោកហៅថាពាលបានដែរ ។ ដោយយោងតាមសេចក្តីខាងលើនេះ ទើបលោកអ្នកប្រាជ្ញចែកប្រភេទ នៃបុគ្គលពាលជា ៣ ប្រភេទ គឺ:

១- ពាលោ បុគ្គលល្ងង់ខ្លៅ

២-ពាលោខោ បុគ្គលល្ងង់ខ្លៅហើយធ្វើអាក្រក់ដោយកាយវាចាចិត្ត

៣- អតិពាលោខោ បុគ្គលល្ងង់ខ្លៅ ធ្វើអាក្រក់ដោយកាយវាចាចិត្តខ្លួនឯងហើយ ដឹកនាំអ្នកដទៃឱ្យធ្វើតាមទៀត ។

**ពាលោ** មកពី ពាល+សិ ផ្លាស់ សិ ជា េ-ា បានជា ពាលោ ប្រែថា បុគ្គលល្ងង់ខ្លៅ។ ល្ងង់ខ្លៅក្នុងទីនេះ សំដៅយកបុគ្គលអ្នកមិនមានការចេះដឹងទូទៅ មិនចេះឱ្យទាន មិនចេះរក្សាសីល មិនចេះគោរព

មាតាបិតា មិនចេះគោរពព្រះសង្ឃ មិនចេះគោរព យាយ តា អ៊ំ ពូ មីង បង ឬ មិត្តភក្តិដែលមានវ័យប្រហាក់ប្រហែលគ្នា ហើយមិនដឹងអំពីរបៀបរបបនៃការប្រាស្រ័យទាក់ទងគ្នាក្នុងសង្គមមនុស្ស ។ ឯការប្រើពាក្យសម្ដីក៏មិនបានលៃលកទៅតាមឋានៈរបស់មនុស្ស អ្នកណាគួរប្រើពាក្យយ៉ាងណាៗ ក៏អត់ដឹង ពោលគឺ សុជីវធម៌ សីលធម៌ សណ្ដាប់ធ្នាប់របស់សង្គម គឺគេមានការយល់ដឹងតិចតួច ថែមទាំងមិនដឹងថា អំពើណាធ្វើទៅមានប្រយោជន៍ អំពើណាធ្វើទៅមិននាំមកនូវប្រយោជន៍ ហើយអាចមានសេចក្ដីអន្តរាយដល់ខ្លួនឯង ព្រមទាំងអ្នកដទៃទៀតផង ក៏ព្រោះតែគេមានការសិក្សារៀនសូត្រចេះដឹងតិច ហ្នឹងឯង ។

☠ **ពាលោខោ** មកពី ពាលោ+ខោ ពាក្យថា **ខោ** មួយមាត់នេះគ្រាន់តែជានិបាតចុះមកបំពេញបទតែប៉ុណ្ណោះ ឱ្យបានជា ពាលោខោ ប្រែថា បុគ្គលល្ងង់ហើយធ្វើអាក្រក់ដោយកាយវាចាចិត្តទៀត ។ បុគ្គលនេះមិនដឹងថា អ្វីដែលធ្វើទៅនោះ ប៉ះពាល់ដល់សេចក្ដីសុខរបស់អ្នកដទៃយ៉ាងណាៗនោះទេ ចេះតែធ្វើទាំងងងឹតងងុល ទៅតាមអំណាចនៃមោហៈ អវិជ្ជា គឺការមិនចេះមិនដឹងហ្នឹងឯង ។ គេរមែងប្រព្រឹត្តនូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ដោយមិនចេះគោរពសិទ្ធិអ្នកដទៃ ។ ជួនកាល

គេកំពុងសិក្សារៀនសូត្រ ក៏ទៅរំខានដោយសម្លេងក្ដុងក្ដាំង ឬ សម្លេងដទៃ ទៀតដូចជា ស្រែកហ៊ោ រោទ៍ម៉ូតូខ្លាំងៗ ឬ បង្អោះ ម៉ូតូជាដើម ។ បើពុំនោះទេ គេដើរអុកឡុកឆាឆៅ ដល់ជនដទៃគ្រប់មជ្ឈដ្ឋានអីចឹងទៅ ។ បុគ្គលប្រភេទនេះ ហេតុតែចង់ឱ្យគេដឹងថាខ្លួនជាមនុស្សអស្ចារ្យ ធ្វើអ្វីក៏ធ្វើ ដែរ ឱ្យតែគេសរសើរ ជាប្រភេទពួកមនុស្សស៊ីខ្សៀជោរ ។

បុគ្គលបែបនេះ ធ្វើទានរក្សាសីលទៅវត្តអី ៗ មិនសូវជាទៅ ប៉ុន្មានទេ ឬ ទៅដែរត្រឹមតែដើរលេង បើនាំទៅកន្លែងដែលមាន ស្រា ស្រី ល្បែង.. ។ល ។.ទើបជាទីសប្បាយ របស់ពួកគេ ។



☠ **អតិពាលោខោ** មកពី អតិ+ពាលោ+ខោ អតិ ប្រែថា កន្លង ក្រៃ ក្រៃពេក ពេក អតិពាលោខោ បុគ្គលល្ងង់ផង ធ្វើអាក្រក់ ដោយកាយ វាចាចិត្ត ដ៏ក្លៀវក្លាយ៉ាងក្រៃលែងផង ដឹកនាំគម្រោមអ្នកដទៃឱ្យធ្វើតាម ផង ហៅមហាពាល ឬ មហាពាលពិតពេកណាស់ មានពិសក្រៃលែង ជាងពស់វែក គួរឱ្យខ្លាច គួរឱ្យចៀសវាងចេញឱ្យឆ្ងាយ ។ អ្នកប្រាជ្ញ ទាំងឡាយមានអតិត្តិតាបសជាដើម លោកផ្ដាំកូនថា បើទុកជានៅក្នុង

ជម្ងឺទីបនេះ មានមនុស្សតែពីរនាក់ទឹងជនពាលនោះក៏ដោយ លោកថា កុំឱ្យនៅជាមួយនឹងបុគ្គលពាលនោះឱ្យសោះ ។ ហេតុអ្វីបានជា លោកខ្លាច ពាលខ្លាំងម៉្លេះ ? ព្រោះពាលនោះ បើសេពគប់ទៅកាលណាហើយ តែង នាំឱ្យធ្វើអំពើអាក្រក់ផ្សេងៗ មានសម្លាប់លួចយកទ្រព្យសម្បត្តិ និងលួច កូនប្រពន្ធជនដទៃ ភូតកុហកផឹកទឹកស្រវឹងជាដើម ។ កុំថាអ្នកដទៃ សូម្បី តែមាតាបិតាបង្កើតរបស់ខ្លួន ក៏ជនពាលនោះនាំឱ្យសម្លាប់ចោលបានដែរ ។ ដូចជារឿងអជាតសត្តុកុមារ ដែលភិក្ខុពាលឈ្មោះ ទេវទត្ត ធ្វើឧបាយកល ឱ្យសម្លាប់ព្រះបាទពិម្ពិសារជាបិតារបស់ខ្លួន ដោយដាក់ទ្រុងដែកវះព្រះបាទ បង្អត់អាហារ ទាល់តែសោយទិវង្គតទៅ ដើម្បីដណ្តើមយករាជសម្បត្តិ សូម្បីព្រះមាតា សូមអង្វរយ៉ាងណា ក៏ពុំព្រមសោះឡើយ ។ កាលដែល ព្រះបាទអជាសត្តុធ្វើយ៉ាងនេះ គឺដោយអាស្រ័យការដឹកនាំរបស់ ភិក្ខុពាល ឈ្មោះទេវទត្តហ្នឹងឯង ។

ក្នុងបច្ចុប្បន្នឥឡូវនេះ មានមនុស្សច្រើនប្រភេទច្រើនយ៉ាង ពួកខ្លះមិនជួយធ្វើការមាតាបិតា បបួលពួកម៉ាកមិត្តភក្តិដើរលេងផឹកស៊ី បង្កបញ្ហា មានការរករឿងកាប់ចាក់គ្នាជាដើម រំខានដល់អ្នកដទៃ ខ្លះយក លុយម្តាយឪពុក ហើយគេចសាលានាំមិត្តភក្តិដើរលេងល្បែងស៊ីសង សព្វ បែបយ៉ាង បើពុំនោះទេ ក៏ទៅមានដៃគូស្នេហាសង្សារច្រើន ចាយខ្ជះខ្ជាយ

ថែមទាំងមានរោគដល់ខ្លួនទៀត។ ខ្លះទៀតនោះ លួចយកទ្រព្យសម្បត្តិរបស់មាតាបិតាលក់ ដើម្បីយកប្រាក់ទិញគ្រឿងញៀន ឬ បង្កើតក្រុមបងតូចបងធំ ដែលសង្គមគេស្អប់ខ្ពើម ។ គេមានការទន់ខ្សោយ ផ្នែកខាងគុណធម៌ សុជីវធម៌ និង សណ្តាប់ធ្នាប់របស់សង្គម មានន័យថា ធម៌របស់សប្បុរសមិនមានក្នុងខ្លួនពួកគេទេ ។ បុគ្គលប្រភេទនេះ ឈ្មោះថាធ្វើឱ្យមាតាបិតាស្លាប់ទាំងដែលគាត់កំពុងរស់នៅ ហើយចំពោះរូបគេផ្ទាល់ ក៏ឈ្មោះថា ស្លាប់ទាំងរស់ដែរ ។





ប្រភេទនៃបុគ្គលពាលទាំងបីដែលបានពោលមកនេះ បុគ្គលពីរពួកខាងដើម គឺ ពាលោ និង ពាលោខោ អាចនឹងកែខ្លួនឱ្យទៅជាល្អបាន ប្រសិនបើមានការអប់រំ និង ការសេពគប់ល្អ ។ ចំណែកបុគ្គលមួយពួកខាងចុង គឺ

អតិពាលោខោនេះ កម្រនឹងកែខ្លួនបានពិតប្រាកដណាស់ ទោះជាមានការអប់រំ និងការសេពគប់ត្រូវក៏ដោយ ។

បួនត្រូវចាំថា បុគ្គលពាលមិនមែនមានចំពោះតែគ្រហស្ថ អ្នកគ្រប់គ្រងផ្ទះតែប៉ុណ្ណោះនោះទេ សូម្បីតែអ្នកបួសក្នុងព្រះពុទ្ធសាសនានេះក្តី ក្រៅព្រះពុទ្ធសាសនាក្តី គឺមានដូចគ្នា ដូចជាភិក្ខុទេវទត្តជាដើម ដែលជាអ្នកបួសក្នុងព្រះពុទ្ធសាសនានេះ។ ហេតុនេះហើយបាន ជាលោកអ្នកប្រាជ្ញ ចែកប្រភេទនៃអ្នកបួសដែលជាសម្មតិសង្ឃ (សង្ឃដែលមិនមែនជាព្រះអរិយៈ សង្ឃជាបុថុជ្ជន សង្ឃដែលនៅមានកិលេស) ជាប្រាំបីប្រភេទ ។





## អ្នកបួសមាន ៨ ប្រភេទ

១-ឧបនិស្សរណា អ្នកបួសខំបដិបត្តិធម៌វិន័យដើម្បីរំលត់កិលេសខ្លួនឯងផង ជួយប្រាប់ពន្យល់អ្នកដទៃផង ។

២- ឧបសង្គហិកា  អ្នកបួសបដិបត្តិធម៌វិន័យខ្លះ ជួយសង្គមខ្លះ ជីកស្រះ ជីកអណ្តូង លើកថ្នល់ សង់ស្ពាន សង់សាលារៀន ធ្វើមន្ទីរពេទ្យ ។ល។

៣- ឧបជីវិកា  អ្នកបួសទាល់ច្រក ព្រោះរកចិញ្ចឹមជីវិតមិនបាន

៤ -ឧបចិណ្ណិកា  អ្នកបួសសន្សំទ្រព្យ គិតយកតែប្រយោជន៍ខ្លួន

៥-ឧបកីឡិកា  អ្នកបួសរកឱកាសទំនេរ ដើម្បីលេងល្បែងផ្សេងៗ លេងអុកលេងចត្រង្គ ចិញ្ចឹមទទា ចិញ្ចឹម លលក ។ល។

៦-ឧបមុយ្ហិកា  បួសល្ងីតល្ងង់ ជឿអាបធ្មប់មន្តអាគម ឱមអាមជាដើម ។

៧-ឧបសិក្ខិកា  បួសគ្រាន់តែជាយាន ដើម្បីស្រួលរៀនសូត្រខាងវិជ្ជាផ្លូវលោក ។

៨-ឧបទូសិកា  អ្នកបួសប្រទូស្តរ៉ាយ  បួសធ្វើនយោបាយបក្សនេះបក្សនោះ ឬ បួសក្លែងបន្លំបង្ខូចកិត្តិយសព្រះពុទ្ធសាសនា ។[1]

ដោយសារតែមានអ្នកបួសប្រភេទមិនល្អខាងលើពួកខ្លះនេះឯងបានជាព្រះពុទ្ធសាសនា ចេះតែមានការអន់ថយជាលំដាប់ ទាំងផ្នែកខាង

---

១ ព្រះរតនត្រ័យ លោកគ្រូ ងិន ភេន ឥន្ទ បញ្ញោ  ទំព័រ ទី ១៥

ការបដិបត្តិ ទាំងការអប់រំ ធ្វើឱ្យពុទ្ធបរិស័ទមួយចំនួន ពុំមានការជឿជាក់នឹងព្រះពុទ្ធសាសនា បែរទៅជឿមង្គលភ្ញាក់ផ្អើលផ្សេងៗ មានជឿថាមង្គលស្ថិតនៅលើ ថ្ងៃ ខែ ឆ្នាំ ដើមឈើ សត្វ យ័ន្ត ខ្សែចង្កេះ ជាដើម ។ សាសនាដទៃទៀត គេមានឱកាសក្នុងការជ្រៀតចូលមក តាមរយៈការបញ្ចុះបញ្ចូលមនោគមវិជ្ជាផ្សេងៗ ដល់កូនខ្មែរដែលពុំសូវចេះដឹងអំពីព្រះពុទ្ធសាសនា ឱ្យចូលទៅក្នុងសាសនាគេបានដោយងាយ ជាទីបំផុត ។

តែសម្រាប់រូបយើងដែលជាអ្នកគោរពរាប់អានព្រះពុទ្ធសាសនា ត្រូវស្វែងយល់ឱ្យបានច្រើន អំពីព្រះពុទ្ធសាសនា គឺត្រូវញែកចេញឱ្យដាច់នូវព្រះពុទ្ធសាសនា និង អ្នកកាន់ព្រះពុទ្ធសាសនា យ៉ាងនេះទើបជ្រាបច្បាស់ថា (( ព្រះពុទ្ធសាសនាថ្លៃថ្លាជានិច្ច )) ។

តើប្អូនដឹងទេថា បុគ្គលណាខ្លះដែលគួរយកមកធ្វើជាមិត្ត ? បងសូមប្រាប់ប្អូនថា បណ្ដាជនពាលនិងបណ្ឌិតទាំងពីរពួកនេះ មានតែពួកបណ្ឌិតប៉ុណ្ណោះ ដែលប្អូនត្រូវគប់រក ។ ពួកជនពាល គឺប្អូនមិនត្រូវគប់រកទេ ព្រោះពួកជនពាលប្រៀបដូចជាត្រីស្អុយអ៊ីចឹងឯង ។ បើបុគ្គលណាសេពគប់ជាមួយនឹងជនពាល បុគ្គលនោះប្រៀបដូចជាស្លឹកឈើដែលសម្រាប់ខ្ចប់នូវត្រីស្អុយ ។ ស្លឹកឈើមួយនោះជាទីសម្អប់នៃពួកវិញ្ញូជន ( អ្នកចេះដឹង ) ។ ដូចនេះចូរប្អូនគប្បីបោះបង់ចោល និងស្អប់ខ្ពើមពួកពាល ។

សេចក្ដីល្អជាលម្អនៃជីវិត

ចំណែកបណ្ឌិត គឺប្អូនត្រូវតែសេពគប់ជាដាច់ខាត ព្រោះបណ្ឌិតប្រៀបដូចជាភណ្ឌ(សំភារៈ) សម្រាប់វេចខ្ចប់នូវគ្រឿងក្រអូបមានខ្លឹមចន្ទន៍ក្រស្នានិងមាលាជាដើម តែងដល់នូវភាពជាអ្នកគួរសរសើរនិងគួរជាទីពេញចិត្តនៃពួកវិញ្ញូជន ។

ប្អូនត្រូវដឹងថាអ្នកណាក៏ដោយ ឱ្យតែសេពគប់ជាមួយបុគ្គលបែបណា អ្នកនោះរមែងមានចរិត ការប្រព្រឹត្ត ដូចគ្នានឹងបុគ្គលនោះដោយពិត។ ដូចរឿងកូនសេកពីរដែលបងបាននិទានប្រាប់ប្អូនជារឿយៗ គឺសេកមួយរស់នៅជាមួយពួកចោរ សេកមួយទៀតរស់នៅជាមួយតាបសឥសី សេកទាំងពីរមានចរិតមិនដូចគ្នា ។ សេកដែលរស់នៅជាមួយចោរមានចរិតកាត់ទៅតាមពួកចោរ សេកដែលរស់នៅជាមួយតាបសឥសី មានចរិតកាត់ទៅតាមតាបសឥសីនោះ។ ហេតុដូច្នេះហើយទើបសេក ឈ្មោះបុប្ផកៈ បានពោលនូវគាថាទាំងឡាយនេះនឹងព្រះរាជា ថា :

**បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់នូវបុគ្គលបែបណាៗ ទោះជាសប្បុរស ឬ អសប្បុរស មានសីល ឬ ឥតសីល រមែងលុះក្នុងអំណាចនៃបុគ្គលនោះឯង ។ បុគ្គលធ្វើបុគ្គលបែបណាឱ្យជាមិត្ត និង ចូលទៅគប់រកនូវបុគ្គលបែបណា បុគ្គលនោះក៏មានអាការបែបនោះ**

ដែរ ព្រោះកិរិយានៅរួម ក៏រមែងប្រាកដដូច្នោះ។ អាចារ្យត្រូវកូនសិស្សគប់រក ត្រូវកូនសិស្សប៉ះពាល់ហើយ ក៏រមែងប្រឡាក់កូនសិស្ស ប្រៀបដូចជាកូនសរដែលជ្រលក់ដោយថ្នាំពិស តែងប្រឡាក់បំពង់សរដូច្នោះឯង។ ការភ័យខ្លាចអំពីការប្រឡាក់នេះ អ្នកប្រាជ្ញមិនយកបុគ្គលលាមកជាសំឡាញ់សោះឡើយ ។ ជនណាខ្ចប់នូវត្រីស្អុយដោយចុងស្បូវភ្លាំង សូម្បីស្បូវភ្លាំងក៏មានក្លិនស្អុយ ផ្សាយចេញទៅដែរយ៉ាងណាមិញ ការចូលទៅសេពគប់នូវបុគ្គលពាលក៏យ៉ាងដូច្នោះដែរ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ សូម្បីស្លឹកឈើ ក៏មានក្លិនក្រអូបផ្សាយចេញទៅដែរ យ៉ាងណាមិញ ការចូលទៅសេពគប់នូវអ្នកប្រាជ្ញរបស់ជននោះ ក៏យ៉ាងដូច្នោះដែរ។ ព្រោះហេតុនោះបុគ្គលជាបណ្ឌិត ដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាខ្ចប់ស្លឹកឈើ ហើយមិនគួរសេពគប់នូវពួកអសប្បុរស តែគួរសេពគប់ពួកសប្បុរស ព្រោះ

ពួកអសប្បុរសតែងនាំទៅកាន់នរក ឯពួកសប្បុរសតែងផ្តល់នូវសុគតិ"។[១]

ពិតណាស់ បុគ្គលសេពគប់នូវជនពាល សូម្បីមិនបានធ្វើនូវអំពើអាក្រក់ក៏ដោយ ក៏រមែងទទួលបាននូវការពោលតិះដៀលថា ជាអ្នកសេពគប់ជាមួយនឹងបុគ្គលពាល (ជាមនុស្សអន់ ព្រោះរកបុគ្គលល្អមកធ្វើជាមិត្តពុំបាន)ដូច្នោះដែរ។ ចំណែកបុគ្គលសេពគប់ជាមួយអ្នកប្រាជ្ញ សូម្បីមិនអាចកើតជាប្រាជ្ញបាន ក៏រមែងបានទទួលនូវកេរ្តិ៍ឈ្មោះដ៏ល្អថា ជាអ្នកចេះសេពគប់ជាមួយនឹងកល្យាណមិត្ត(ជាមនុស្សឆ្លាតចេះ សេពគប់ជាមួយនឹងអ្នកចេះដឹង ដែលជាហេតុឈានទៅរកការចេះដឹង) ដូច្នេះ ។

កុំថាឡើយដល់របស់មានជីវិតមានវិញ្ញាណចម្ងាត សូម្បីតែរុក្ខជាតិដែលជារបស់ឥតវិញ្ញាណ ក៏អាចកាត់ទៅរកគ្នានឹងគ្នាបានដែរ។ ដូចជារឿងផ្លែស្វាយរបស់ព្រះរាជាព្រះនាម ទធិវាហនៈ ពីដើមឡើយមានរសជាតិឆ្ងាញ់ពិសា តែលុះពេលក្រោយមក អ្នករក្សាដើមស្វាយនោះ បានយកនូវដើមបណ្តូលពេជ្រ ដែលមានរសជាតិល្វីង មកដាក់ដាំឱ្យរួបរឹតដើមស្វាយនោះ ក្រោយពេលស្វាយផ្លែមកមានរសជាតិល្វីង មិនជាទី

---

[១] មង្គលទីបនី ភាគ ១ ទំព័រ ២៥

ប្រាថ្នារបស់មនុស្សទាំងឡាយ ក៏ក្លាយទៅជារបស់ដែលគេមិនត្រូវការ ព្រោះប្រកបជាមួយនឹងរបស់ដែលគេមិនត្រូវការ ។ វាអាចក្លាយទៅជារបស់ដែលគេប្រាថ្នាចង់បានវិញ ព្រោះវាប្រកបដោយរបស់ដែលគេប្រាថ្នាចង់បាន ដូចដែលបានពណ៌នាមកហើយនេះឯង ។

ដោយហេតុនោះ ក្នុងអត្ថុប្បត្តិហេតុនៃទធិវាហនជាតកព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាការនៅជាមួយមនុស្សមិនល្អ ជារឿងដ៏លាមក បង្កើតតែរឿងរ៉ាវគ្មានប្រយោជន៍ មិនចាំបាច់ពោលថ្វី ក្នុងការនៅរួមគ្នាជាមួយនឹងមនុស្សមិនល្អនោះឡើយ ព្រោះការនៅរួមជាមួយនឹងមនុស្សអាក្រក់ តែងធ្វើសេចក្តីអន្តរាយ និងអំពើមិនមែនជាប្រយោជន៍ ដល់មនុស្សទាំងឡាយដ៏ច្រើនរួមទាំងខ្លួនឯងផង ។ សូម្បីដើមស្វាយដែលមិនមានចេតនា មានរសជាតិផ្អែម ប្រៀបស្មើនឹងរសជាទិព្វ ដែលវាស្រ័យនៅជាមួយគ្នានឹងដើមស្ពៅ ដែលមានជាតិល្វីង មិនមានរសជាតិផ្អែម ក៏បានក្លាយទៅជាដើមឈើ ដែលមិនមានរសជាតិផ្អែម បែរជាមានរសជាតិល្វីងទៅវិញ ។

## ☞ ជនពាលដូចជាអមិត្ត បណ្ឌិតដូចជាញាតិ [១]

មួយវិញទៀត បុគ្គលពាលទាំងឡាយ ប្រៀបដូចជាអមិត្តដែលមានទូវដាវក្នុងដៃ។ បណ្ឌិតទាំងឡាយ ប្រៀបដូចជាញាតិដែលជាទីស្រលាញ់ (ធម្មតាបុគ្គលអ្នកមានញាតិច្រើន ទោះទៅដល់ទីណាក៏មិនមានការព្រួយបារម្ភអំពីអន្តរាយទាំងឡាយឡើយ ព្រោះមានគេស្រលាញ់ចូលចិត្តច្រើន) សមដូចគាថាដែលព្រះអង្គទ្រង់ត្រាស់សម្តែង ថា:

**មែនពិត បុគ្គលអ្នកប្រព្រឹត្តសេពគប់ដោយជនពាល រមែងសោកសៅអស់កាលដ៏យូរអង្វែង ការនៅរួមជាមួយគ្នានឹងជនពាល រមែងជាទុក្ខសព្វកាល ដូចជាការនៅរួមជាមួយនឹងសត្រូវ។ ចំណែកខាងបណ្ឌិតវិញ មានការនៅរួមជាសុខ ប្រៀបដូចជាការជួបជុំនៃពួកញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់នូវសប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្តនិងធុតង្គវត្តផង ជាអ្នក**

---

[១] មង្គលទីបនី ភាគ ១ ទំព័រ ទំ ៣៣

**ឆ្ងាយចាកកិលេសផង មានបញ្ញាដ៏ល្អផង ប្រាកដដូច្នេះ នោះ ឱ្យដូចជាព្រះច័ន្ទគប់រកនូវផ្លូវនៃនក្ខត្តឫក្ស យ៉ាងដូច្នោះឯង ។**[1]

ប្អូនឃើញទេព្រះពុទ្ធដីកា ដែលព្រះអង្គទ្រង់ត្រាស់សម្ដែងមក គឺមិនដែលសរសើរថា បុគ្គលពាលជាបុគ្គលល្អទេ មានតែបណ្ឌិតប៉ុណ្ណោះ ដែលព្រះអង្គសរសើរ ហើយអ្នកប្រាជ្ញទាំងឡាយ លោកក៏មិនចង់ជួបជាមួយនឹងបុគ្គលពាលដែរ ។

## ☞ តាបសឱ្យដំបូន្មានដល់បុត្រ[2]

សូម្បីព្រះពោធិសត្វ កាលកើតជាតាបសនៅក្នុងព្រៃហិមវន្តប្រទេស កាលទូន្មាននូវតាបសកុមារជាបុត្ររបស់ខ្លួន ដែលធុញទ្រាន់ប្រាថ្នាចេញអំពីព្រៃ ហើយទៅរស់នៅក្នុងទីលំនៅនៃមនុស្ស បានពោលនូវគាថាទាំងឡាយនេះ ក្នុងហាលិទ្ទរាគជាតក ក្នុងនវកនិបាត ថា:

---

[1] បិដក លេខ ៥២ ទំព័រ ៦៤-៦៥

បុគ្គលណាមិនមានអំពើអាក្រក់ ដោយកាយ វាចា និង ចិត្ត អ្នកចេញអំពីព្រៃនេះទៅហើយ ចូរតាំងខ្លួនឱ្យដូចជាកូនដែលកើតអំពីទ្រូង ហើយចាំសេពគប់រកនូវបុគ្គលនោះចុះ។ មួយទៀតបុគ្គលណាប្រព្រឹត្តតាមធមិ ទោះបីកំពុងប្រព្រឹត្តក៏មិនប្រកាន់ខ្លួន។ អ្នកចេញអំពីព្រៃនេះទៅហើយ ចូរសេពគប់នូវបុគ្គលដែលធ្វើនូវអំពើល្អបរិសុទ្ធ ប្រកបដោយបញ្ញានោះចុះ។ នែបា! បុគ្គលណា មានចិត្តដូចជាសំពត់ដែលជ្រលក់រមៀត មានចិត្តដូចជាសត្វស្វា ត្រេកអរហើយបែរជាមិនត្រេកអរវិញ បើទុកជាផ្ទៃនៃជម្ពូទ្វីបទាំងមូលនេះ មិនមានមនុស្សសោះក៏ដោយ ចូរអ្នកកុំសេពគប់នូវបុគ្គលបែបនោះឡើយ អ្នកចូរចៀសវាង (បុគ្គលបែបនោះ) អំពីចម្ងាយ ឱ្យដូចជាបុគ្គលអ្នកភ័យខ្លាច ចៀសវាងអាសិរពិសដ៏កាចសាហាវអំពីចម្ងាយ ឬ ដូចជាបុគ្គលឆ្កើមលាមក ចៀសវាងផ្លូវធំដែលប្រឡាក់ដោយលាមក ឬ ដូចបុគ្គល ទៅដោយយាន ចៀសវាងនូវផ្លូវដែលមិនរាបស្មើដូច្នោះ។ នែបា! អំពើដែលមិនមែន

ជាប្រយោជន៍ទាំងឡាយ រមែងចម្រើនដល់បុគ្គល ដែលសេពគប់នូវជនពាលផ្តេសផ្តាស ចូរអ្នកកុំគប់រក នូវបុគ្គលពាលឡើយ ព្រោះការនៅរួមជាមួយបុគ្គល ពាល ជាហេតុនាំមកនូវសេចក្តីទុក្ខមកឱ្យខ្លួនប្រៀប ដូចជាការនៅរួមជាមួយសត្រូវសព្វៗកាល។ នែបារ ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរអ្នក ចូរ អ្នកធ្វើតាមពាក្យរបស់យើង ចូរអ្នកកុំសេពគប់រក ជាមួយបុគ្គលពាលឡើយ ព្រោះការសមាគមជាមួយ បុគ្គលពាលទាំងឡាយ រមែងជាហេតុនាំមកនូវ សេចក្តីទុក្ខ។[១]

មិនប្រកាន់ខ្លួនមានន័យថា សូម្បីការប្រព្រឹត្តធម៌(កាន់សីល៥ សីល ៨ សីល១០ ជាដើម) ក៏មិនប្រកាន់ថាអញជាអ្នកប្រព្រឹត្តធម៌ ។ អំពើ ដ៏បរិសុទ្ធ បានដល់ អ្នកធ្វើនូវកម្ម (អំពើទង្វើ ឬ ការងារ)ដែលបរិសុទ្ធ បានដល់កុសលកម្មបថ ១០(កាយកម្ម៣ វចីកម្ម៤ មនោកម្ម៣) ។ មាន

---

១ បិដកលេខ ៥៩ ទំព័រ ១៥៣

ចិត្តដូចជាសំពត់ដែលជ្រលក់រមៀត មានន័យថា ជាអ្នកមានចិត្តមិនស្ថិតស្ថេរ ។

គ្រប់ជំនាន់គ្រប់សម័យកាល មិនដែលមានអ្នកប្រាជ្ញណាដែលសរសើរអំពីគុណរបស់បុគ្គលពាលឡើយ គឺមានតែការតិះដៀល មានតែការចៀសវាង និង ហាមឃាត់មិនឱ្យទៅសេពគប់ជាមួយ ដូចជារឿងពាបសឱ្យដំបូន្មានដល់បុត្រនេះជាដើម ។

បងលើកយកនូវរឿងនេះមក គឺដើម្បីឱ្យប្អូនត្រិះរិះពិចារណា យកធ្វើជាមេរៀនរបស់ជីវិត ជាពិសេសដើម្បីបាននូវសតិ គ្រាន់ជាទីរលឹកក្នុងពេលណាដែលប្អូនបំរុងនឹងធ្វើ ហើយដែលប្អូនគិតថា វាគួរសម្រាប់ប្អូននោះ។ ប៉ុន្តែសូមប្អូនកុំភ្លេចថា ទុក្ខភ័យអន្តរាយទាំងឡាយទាំងពួងមិនដែលកើតឡើងអំពីបណ្ឌិតទេ ។

## ភ័យឧបទ្រពនិងឧបស័គ្គកើតមានព្រោះជនពាល[១]

មួយទៀតសោត ភ័យឧបទ្រពនិងឧបស័គ្គទាំងឡាយណាមួយដែលកើតមាន ភ័យឧបទ្រពឧបស័គ្គទាំងឡាយទាំងអស់នោះ កើតឡើង

---

១មង្គលទីបនី ភាគ ១ ទំព័រ ៣៣

ព្រោះអាស្រ័យបុគ្គលពាលទាំងស្រុង។ មែនពិត បុគ្គលពាល កាលប្រាថ្នានូវភារៈជាព្រះរាជាក្ដី ភារៈជាឧបរាជក្ដី ឬក៏ មុខតំណែងដ៏ធំផ្សេងទៀតក្ដី ក៏បបួលពួកអ្នកលេងធំៗ ពីរទៅបីនាក់ឬច្រើនជាងនេះ ដែលស្មើនឹងខ្លួន ហើយនិយាយថា អ្នកទាំងឡាយចូរមកចុះ ខ្ញុំនឹងឱ្យពួកអ្នកធ្វើជាធំ ហើយអាស្រ័យទីស្ងាត់ៗ មានញៀតស្បាតនៃព្រៃភ្នំជាដើម ហើយប្លន់ស្រុកដែលនៅដាច់ស្រយាល ប្លន់និគមខ្លះ ជនបទខ្លះ តាមលំដាប់ ។



សមដូចព្រះពុទ្ធដីកា ដែលព្រះអង្គទ្រង់ត្រាស់ នៅក្នុងលក្ខណសូត្រនៃតិកនិបាតអង្គុត្តរនិកាយថា ភ្លើងតែងឆេះរាលអំពីផ្ទះបបុសឬផ្ទះស្បូវ មកឆេះផ្ទះដ៏បូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូលបាន មានសន្ទះទ្វារដ៏ស្និទ្ធជិត មានបង្អួចបិទជិតហើយ ដូចម្ដេចមិញ។ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតឡើងអំពីបណ្ឌិតទេ។ ឧបស័គ្គទាំងឡាយណាមួយកើតឡើង ឧបស័គ្គទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតឡើងអំពីបណ្ឌិតទេ ក៏យ៉ាងដូច្នោះដែរ។ ម្នាលភិក្ខុទាំងឡាយ

បុគ្គលពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ បុគ្គលពាលប្រកបដោយឧបទ្រពដ៏ពន្លឹក បណ្ឌិតមិនមានឧបទ្រពដ៏ពន្លឹកទេ បុគ្គលពាលប្រកបដោយឧបស័គ្គដ៏ពន្លឹក បណ្ឌិតមិនមានឧបស័គ្គដ៏ពន្លឹកទេ ដោយប្រការដូច្នេះឯង។ ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានមកអំពីបណ្ឌិតឧបទ្រពមិនមានមកអំពីបណ្ឌិត ឧបស័គ្គមិនមានមកអំពីបណ្ឌិតឡើយដូច្នេះ ។[១]

*" អាគារភ្លោះនៅសហរដ្ឋអាមេរិក ឆេះដោយយន្តហោះបុកកំទេច តើនេះជាសកម្មភាពរបស់មនុស្សដូចម្ដេច ? "*



នេះជាសេចក្ដីនៃព្រះសូត្រ ដែលព្រះអង្គទ្រង់សម្ដែង គឺព្រះអង្គទ្រង់បញ្ជាក់ហើយបញ្ជាក់ទៀត ដើម្បីឱ្យឃើញច្បាស់ដឹងពិតព្វមែន។ ជាការពិតណាស់ ចំពោះបញ្ហាសព្វបែបយ៉ាងដែលកើតមានក្នុងពេលបច្ចុប្បន្ន

---

១ បិដក លេខ ៤១ ទំព័រ ទី ៣

នេះ គឺប្អូនអាចឃើញនិងដឹងបានដោយខ្លួនឯងហើយ ដូចជា ចោរកម្ម (លួចប្លន់) ឃាតកម្ម (ការសម្លាប់) អាណាចារកម្ម (ការរំលោភបំពាន) ដែលមានតាម ភូមិ ស្រុក ខេត្ត សាលាគ្រប់ទីណាៗទាំងអស់ ដោយហោចទៅសូម្បីក្នុងគ្រួសារក៏មាន ដែលហៅថាអំពើហិង្សាក្នុងគ្រួសារ ។ ហើយដើម្បីឱ្យយល់ នូវសេចក្ដីនៃព្រះសូត្រនេះឱ្យទូលាយ បងនឹងលើកយកនូវព្រះអដ្ឋកថា ដែលមាននៅក្នុងមង្គលទីបនី មកសម្ដែងបន្ថែមទៀត ។

[១]បុគ្គលពាលទាំងឡាយ គឺអ្នកមានប្រាជ្ញាគប្បីជ្រាបថា ប្រៀបដូចជាផ្ទះដែលត្រូវភ្លើងឆេះហើយ ។ ព្រោះថាបុគ្គលពាលទាំងឡាយនោះ ជាអ្នកអាចក្នុងការនាំសេចក្ដីទុក្ខមានភ័យជាដើមគ្រប់យ៉ាង មកប្រគល់ឱ្យដល់បុគ្គលទាំងឡាយអ្នកធ្វើតាមពាក្យរបស់ខ្លួន។ គប្បីជ្រាបថា បណ្ឌិតទាំងឡាយ ប្រៀបដូចជាការថែរក្សាក្នុងទីដែលមានភ័យ ប្រៀបដូចជាប្រទីបក្នុងទីដែលងងឹត និងប្រៀបបានដូចជាការបានទទួលបាយនិងទឹកជាដើម ក្នុងវេលាដែលត្រូវសេចក្ដីទុក្ខ មានការស្រេកឃ្លានជាដើម មកគ្របសង្កត់ដូច្នោះឯង។ ព្រោះថា បណ្ឌិតទាំងឡាយនោះ ជាអ្នកអាចក្នុង

---

១ មង្គលទីបនីភាគ ១ ទំព័រ ៤១

ការកម្ចាត់នូវសេចក្ដីទុក្ខទាំងឡាយ មានភ័យជាដើមគ្រប់យ៉ាង ដល់បុគ្គលទាំងឡាយដែលធ្វើតាមពាក្យរបស់ខ្លួន ។ បុគ្គលដឹងនូវភារៈនៃជនពាលទាំងឡាយ ប្រៀបស្មើនឹងរបស់ដែលស្មោកគ្រោក មានត្រីស្អុយជាដើម និងបណ្ឌិតទាំងឡាយ ប្រៀបស្មើនឹងគ្រឿងសំអាង មានគ្រឿងក្រអូបជាដើម ទាំងការសេពគប់រកបុគ្គលពាល ជាហេតុនាំឱ្យកើតទុក្ខ និងការសេពគប់រកនូវបណ្ឌិត ជាហេតុនាំឱ្យកើតសេចក្ដីសុខ។ ហេតុយ៉ាងដូច្នេះហើយ គប្បីសេពគប់រកនូវបណ្ឌិតតែប៉ុណ្ណោះ មិនគួរសេពគប់រកបុគ្គលពាលឡើយ ។ សូម្បីព្រះមានព្រះភាគ កាលទ្រង់អប់រំទូន្មានព្រះឆន្នត្ថេរ ទ្រង់បានត្រាស់នូវព្រះគាថានេះ ក្នុងបណ្ឌិតវគ្គនៃ ធម្មបទថា:

**អ្នកមានប្រាជ្ញា មិនគួរគប់មិត្តអាក្រក់ មិនគួរគប់រកបុគ្គលថោកទាប គួរគប់រកតែមិត្តដែលល្អប្រសើរ គួរគប់រកតែបុរសខ្ពង់ខ្ពស់ ។**

បុរសថោកទាប គឺបុរសដែលអាក្រក់ (មនុស្សដែលប្រព្រឹត្តធ្វើតែអំពើអាក្រក់សព្វបែបយ៉ាង) បើខាងគ្រហស្ថបានដល់ បុគ្គលណាដែលត្រេកអរក្រៃលែងក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិត គឺប្រព្រឹត្តអាក្រក់ដោយកាយ មានឃាតកម្ម ចោរកម្ម អាណាចារកម្ម ។ វចីទុច្ចរិត

គឺប្រព្រឹត្តអាក្រក់ដោយវចីទ្វារ មានការពោលពាក្យមិនពិត និយាយធ្វើឱ្យគេបែបបាក់គ្នា និយាយតែពាក្យដែលធ្វើឱ្យគេមិនពេញចិត្ត និយាយតែពាក្យដែលយកមកធ្វើជាប្រយោជន៍មិនបាន។ មនោទុច្ចរិត គឺ ការប្រព្រឹត្តិអាក្រក់ដោយចិត្ត មានការគិតលោភលន់ ចង់បានទ្រព្យសម្បត្តិអ្នកដទៃ គិតបៀតបៀនប្រទូស្តរ៉ាយអ្នកដទៃ គិតយល់ខុសចាកគន្លងធម៌ ថាគ្មានបុណ្យគ្មានបាប ឬ ឪពុកម្តាយឥតគុណជាដើម ។ ចំណែកខាងបព្វជិត( អ្នកបួស)វិញ រមែងមានការប្រព្រឹត្តិខុសចាកធិវិន័យប្រកបដោយបាបធម៌៥ និងអនេសនៈ ២១ មានការប្រចុបប្រចែងគ្រហស្ថជាដើម។ ការសេពគប់នូវបណ្ឌិត សូម្បីអស់រយៈពេលតែមួយដង ក៏ឈ្មោះថា រមែងរក្សាឃុំគ្រង់ខ្លួនបាន ការសេពគប់នូវបុគ្គលពាល សូម្បីអស់កាលជាយូរ ក៏មិនឈ្មោះថាជាការថែរក្សាឃុំគ្រងនូវខ្លួនបានឡើយ។ ពិតដូច្នោះមែន សូម្បីទន្តព្រាហ្មណ៍ កាលទៅកាន់នគរឥន្ទបុត្តបុរី ក្នុងទីបំផុតនៃផ្លូវចម្ងាយ១២០យោជន៍ អំពីក្រុងតក្កសិលា ហើយសម្តែងធម៌ ថ្វាយព្រះរាជាព្រះនាមសុតសោម បានពោលគាថានេះ ក្នុងមហាសុតសោមជាតក ថា:

**បពិត្រមហារាជ ទ្រង់ព្រះនាមសុតសោម ការជួបប្រ**
**ទះ ដោយសប្បុរសទាំងឡាយ សូម្បីអស់វារៈតែម្តង**

**ការជួបប្រទះនោះ រមែងថែរក្សានូវបុគ្គលនោះបាន ។ ការជួបប្រទះដោយអសប្បុរសទាំងឡាយសូម្បីអស់វារៈច្រើនផង ក៏រមែងថែរក្សានូវបុគ្គលនោះ មិនបានឡើយ ។**[១]

តាមរយៈនៃគាថានេះ គឺធ្វើឱ្យយើងមានជំហររឹងមាំ ក្នុងការប្រុងស្មារតីដើម្បីកុំឱ្យក្លាយខ្លួន ទៅជាមនុស្សដែលមានការសេពគប់ខុស ។ ព្រោះថាបើយើងសេពគប់ខុសហើយ មិនអាចឈានទៅរកសេចក្ដីរីកចម្រើនបានឡើយ គឺមានតែទុក្ខទោស និងការស្ដាយក្រោយតែប៉ុណ្ណោះ។ ហេតុនេះទើបបងហាមប្អូនម្ដងហើយម្ដងទៀត ថាកុំឱ្យទៅសេពគប់ជាមួយនឹងបុគ្គលពាល ឯប្អូនខ្លួនឯងក៏ត្រូវតាំងចិត្តជាដាច់ខាតថា មិនសេពគប់ជាមួយបុគ្គលពាលទេ ហើយសូមប្អូនតាំងចិត្តបែបនេះ ឱ្យបានរហូតដូចដែលមានរឿងខាងក្រោមនេះជាគំរូ ។

---

*១ បិដកលេខ ៦១ ទំព័រ ២០២ ។*

## ១ រឿងអកិត្តិបណ្ឌិតមិនចង់ជួបប្រទះជនពាល[២]

អកិត្តិបណ្ឌិតនេះ ជាអ្នកមានទ្រព្យច្រើន ។ ក្រោយពីពេលដែលមាតាបិតារបស់លោកស្លាប់ទៅ លោកក៏បានលះបង់ទ្រព្យសម្បត្តិទាំងនោះ ហើយចេញទៅបួសជាតាបសឥសី ។ លុះបួសហើយ លោកជាអ្នកប្រាថ្នាតិច បរិភោគតែស្លឹកដង្ហែបក្តាម ដែលនៅជិតអាស្រមរបស់លោកតែប៉ុណ្ណោះ។ ក្នុងថ្ងៃមួយអកិត្តិបណ្ឌិតនោះ បានថ្វាយអាហារដែលជាស្លឹកដង្ហែបក្តាមនោះ ដល់សក្កទេវរាជហើយ បានពោលនូវគាថានេះថា:

**អាត្មាសូមកុំឱ្យជួបប្រទះនឹងបុគ្គលពាល សូមកុំឱ្យ ឮ**
**ដំណឹងមនុស្សពាល សូមកុំឱ្យនៅរួមនឹងមនុស្សពាល**
**សូមកុំឱ្យបានធ្វើ ទាំងកុំពេញចិត្តនិងការ ចរចារទៅ**
**មក នឹងមនុស្សពាល ។**

ស្តេចសក្កទេវរាជ ទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ ទ្រង់ក៏ត្រាស់សួរហេតុ ក្នុងការមិនចង់ជួបប្រទះ នូវមនុស្សពាលនោះ។ ទ្រង់បានពោលគាថានេះ ថា:

---

២ មង្គលទីបនី ភាគ ១ ទំព័រ ៤៣

បពិត្រកស្សបះ! ជនពាលបានធ្វើអ្វីដល់លោក ? សូមលោកមេត្តាប្រាប់ហេតុ . បពិត្រកស្សបះ ព្រោះហេតុអ្វី ? បានជាលោកមិនប្រាថ្នាចង់ ជួបមនុស្សពាល ។

តាបសនោះ កាលទូលហេតុនោះដល់ស្តេចសក្កទេវរាជ បានពោលថា:

បុគ្គលពាលរមែងណែនាំនូវអំពើដែលមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ។ ការណែនាំទៅរកអាក្រក់ ជាការប្រសើររបស់ជនពាលនោះ។ ជនពាលបើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង។ ជនពាលនោះ មិនដឹងវិន័យទេ។ ការមិនជួបប្រទះជនពាលនោះ ជាការប្រពៃ ។

តាបសកាលទទួលពរដទៃថ្មីទៀត ទើបបានពោលថា:

អាត្មាសូមឱ្យបានជួបប្រទះតែនឹងអ្នកប្រាជ្ញ សូមឱ្យបានស្តាប់ឮតែអ្នកប្រាជ្ញ សូមឱ្យនៅរួមជាមួយ គ្នានឹងអ្នកប្រាជ្ញ សូមឱ្យបានធ្វើ ទាំងសូមឱ្យបានចូល

ចិត្តនូវការចរចារប្រាស្រ័យគ្នាទៅវិញទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

ស្តេចសក្កទេវរាជ ទ្រង់បានត្រាស់សួរ ថា:

បពិត្រកស្សបៈ! អ្នកប្រាជ្ញ បានធ្វើប្រយោជន៍អ្វីខ្លះដល់លោក ? សូមលោកប្រាប់នូវហេតុ បពិត្រកស្សបៈព្រោះហេតុអ្វី ? បានជាលោកចង់ជួបជាមួយនឹងអ្នកប្រាជ្ញ ។

តាបសបានទូល ថា:

អ្នកប្រាជ្ញ មិនណែនាំនូវហេតុដែលមិនគួរណែនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ។ ការណែនាំល្អជាការប្រសើររបស់អ្នកប្រាជ្ញនោះ ។អ្នកប្រាជ្ញបើទុកជាគេនិយាយត្រូវហើយ ក៏នៅតែមិនក្រោធខឹងដែរ អ្នកប្រាជ្ញនោះ រមែងដឹងច្បាស់នូវឧបាយជាគ្រឿងណែនាំ។ ការសេពគប់រកជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃណាស់ ។

មែនពិត ការជួបប្រទះនឹងបណ្ឌិត ជាហេតុនាំឱ្យបាននូវសេចក្តីសុខ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ក្នុងសក្កទេវិន្ទវត្ថុ ថា:

[១] **ការជួបប្រទះនូវព្រះអរិយៈទាំងឡាយជាការប្រពៃ។ ការនៅរួមជាមួយគ្នា ជាហេតុនាំឱ្យបាននូវសេចក្តីសុខសព្វៗកាល។ បុគ្គលគប្បីជាអ្នកមានសេចក្តីសុខអស់កាលជានិរន្តរ៍ ដោយពិតប្រាកដបាន ព្រោះការមិនជួបប្រទះនូវជនពាលទាំងឡាយ ។**

ប្អូនត្រូវដឹងថា បុគ្គលណាសេពគប់នូវជនពាល ធ្វើតាមនូវពាក្យនៃជនពាល បុគ្គលនោះរមែងជួបប្រទះនូវសេចក្តីទុក្ខ អស់កាលជាអង្វែង ។ ដូចជារឿងព្រះបាទអជាតសត្រូវ ដែលបងតែងតែនិយាយប្រាប់ប្អូនជារឿយៗអ៊ីចឹងឯង គឺលោកបានទៅសេពគប់និងភិក្ខុឈ្មោះទេវទត្ត ត្រូវបានភិក្ខុរូបនេះបង្គាប់បញ្ជាឱ្យទៅសម្លាប់បិតាបង្កើតរបស់ខ្លួន ដើម្បីសោយរាជ្យ។ព្រះបាទអជាតសត្រូវ ធ្វើតាមពាក្យរបស់ភិក្ខុរូបនេះ រហូតបានធ្លាក់ទៅក្នុងនរកឈ្មោះលោហគុម្ភីរ ក៏ ដោយសារការអាស្រ័យ

---

១ បងកលេខ ៥២ ទំព័រទី ៦៤

នឹងភិក្ខុរូបនេះដែរ ។ ចំណែកជនណាសេពគប់នូវជនដែលជាបណ្ឌិតជារឿយៗ ធ្វើតាមពាក្យនៃជនដែលជាបណ្ឌិតនោះជារឿយៗ ជននោះរមែងបាននូវសេចក្ដីសុខសព្វៗកាល ។

## បណ្ឌិតធ្វើខ្លួនឯងនិងជនអ្នកធ្វើតាមខ្លួនឱ្យចម្រើន

បណ្ឌិតទាំងឡាយ រមែងមិនញ៉ាំងខ្លួននិងពួកជនអ្នកធ្វើតាមពាក្យរបស់ខ្លួនឱ្យវិនាសឡើយ រមែងឱ្យបានដល់តែសេចក្ដីចម្រើន ព្រោះកម្មដែលខ្លួនបានសាងមកល្អហើយ ដូចជាអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម។ មែនពិត ព្រះពុទ្ធទ្រង់បានសម្រេច នូវព្រះសព្វញ្ញុតញ្ញាណ ដែលប្រកបដោយគុណធម៌ទាំងឡាយទាំងពួង ព្រោះកម្មដែលព្រះអង្គទ្រង់ប្រកាន់យកហើយដោយល្អ។ ព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើម ក៏ដូច្នោះដែរ បានសម្រេចនូវគុណជាតិមានសាវកបារមីញាណជាដើម ។ ទេវតានិងមនុស្សទាំងឡាយ មានប្រមាណមិនបាន អាស្រ័យព្រះពុទ្ធហើយក៏បានសម្រេចនូវអាសវក្ខយញ្ញាណ ហើយបានចូលទៅកាន់ព្រហ្មលោក។ ត្រកូល៨ម៉ឺន ញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងព្រះសារីបុត្តត្ថេរ ហើយឧបត្ថម្ភព្រះថេរៈដោយបច្ច័យបួន បានកើតហើយក្នុងឋានសួគ៌ ។ មួយ

ទៀតព្រកូលទាំង៨ម៉ឺន បានញុំាំងចិត្តឱ្យជ្រះថ្លាហើយ ក្នុងព្រះមហាសាវ័កទាំងពួង មានព្រះមហាមោគ្គល្លាន និង ព្រះមហាកស្សបជាដើម ក៏យ៉ាងដូច្នោះដែរ ។ ព្រោះតែសេចក្តីសុខចំរើន កើតមកអំពីបណ្ឌិតយ៉ាងនេះឯង ទើបទេវបុត្តទាំង៦អង្គ បានពោលនូវគាថាទាំង ៦ ខាងក្រោមនេះ

ទេវបុត្តទី១ ពោលថា :[១]

**បុគ្គលគប្បីគប់រកនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើ**
**សេចក្តីស្និទ្ធស្នាលនឹងពួកសប្បុរស ព្រោះដឹងព្រះសទ្ធម្ម**
**របស់ពួកសប្បុរស គុណធម៌ដ៏ប្រសើររមែងកើតមាន**
**មិនមែនជាទោសដ៏លាមកទេ ។**

ទេវបុត្តទី២ ពោលថា :

**បុគ្គលគប្បីគប់រកតែនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើ**
**សេចក្តីស្និទ្ធស្នាលតែនឹងសប្បុរស ព្រោះដឹងនូវព្រះ**
**សទ្ធម្មរបស់ពួកសប្បុរស បុគ្គលតែងបាននូវបញ្ញា អំពី**
**បុគ្គលដទៃមិនមានឡើយ ។**

ទេវបុត្តទី ៣ ពោលថា:

---

១ បិដកលេខ ៦១ ទំព័រ ២០២

បុគ្គលគប្បីគប់រកតែនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើសេចក្តីស្និទ្ធស្នាលតែនឹងសប្បុរស ព្រោះដឹងនូវព្រះសទ្ធម្មរបស់សប្បុរស បុគ្គលរមែងមិនសោកសៅក្នុងកណ្តាល នៃបុគ្គលអ្នកសោកសៅ ។

ទេវបុត្តទី ៤ ពោលថា :

បុគ្គលគប្បីគប់រកតែនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើសេចក្តីស្និទ្ធស្នាលតែនឹងសប្បុរស ព្រោះដឹងនូវព្រះសទ្ធម្មរបស់សប្បុរស បុគ្គលរមែងរុងរឿងក្នុងកណ្តាលនៃញាតិ ។

ទេវបុត្តទី ៥ ពោលថា :

បុគ្គលគប្បីគប់រកតែនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើសេចក្តីស្និទ្ធស្នាលតែនឹងសប្បុរស ព្រោះដឹងនូវព្រះសទ្ធម្មរបស់សប្បុរស សព្វសត្វទាំងឡាយរមែងបាននូវសុគតិ ។

ទេវបុត្តទី ៦ ពោលថា :

បុគ្គលគប្បីគប់រកតែនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើសេចក្តីសិទ្ធស្នាលតែនឹងសប្បុរស ព្រោះដឹងនូវព្រះ

**សទ្ធម្មរបស់សប្បុរស សត្វទាំងឡាយរមែងស្ថិតនៅអស់កាលដ៏យូរអង្វែង ។**

ហើយព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះគាថាមួយទៀតបន្ថែមលើគាថាទាំង ៦ របស់ពួកទេវបុត្តទាំងនោះ ថា :



**បុគ្គលគប្បីសេពគប់តែនឹងពួកសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្ដីស្និទ្ធស្នាលនឹងសប្បុរស ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស បុគ្គលរមែងបានរួចចាកទុក្ខទាំងពួង ។**

ពាក្យថាសេពគប់ គឺការសម្រេចនូវឥរិយាបថទាំងពួងជាមួយនឹងសប្បុរសទាំងឡាយ ហើយពាក្យថាស្និទ្ធស្នាលនោះ គឺស្និទ្ធស្នាលដោយភាពជាសំឡាញ់ដែលយើងគប្បីធ្វើជាមួយនឹងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវ័ករបស់ព្រះពុទ្ធ ។ ចំណែកសេចក្ដីស្និទ្ធស្នាលដោយអំណាចតណ្ហា

គឺយើងមិនគប្បីធ្វើជាមួយនឹងអ្នកណាឡើយ ។ ពិតណាស់ ធម្មតាបញ្ញាពុំដែលបុគ្គលណាមួយបានអំពីបុគ្គលពាលទេ បុគ្គលពាលប្រៀបដូចជាដីខ្សាច់ ព្រោះធម្មតាដីខ្សាច់ គឺវាមិនដែលមានប្រេងខាងក្នុងនៃគ្រាប់ខ្សាច់នោះទេ ទោះជាគេយកវាទៅចម្រាញ់យ៉ាងណា ក៏វាឥតចេញប្រេងដែរ ព្រោះខ្សាច់វាឥតប្រេង ។ ចំណែកបណ្ឌិតវិញ ប្រៀបដូចជា ល្ងឬដូង ជាធម្មតា ល្ង និង ដូង កាលណាគេចម្រាញ់ រមែងបាននូវប្រេង ហើយអាចយកទៅប្រើប្រាស់តាមសេចក្តីប្រាថ្នា។ ហេតុនេះហើយបានជាលោកពោលថា បុគ្គលដទៃមិនមានឡើយ បុគ្គលដទៃនោះគឺបុគ្គលពាលហ្នឹងឯង ។

កាលដែលបង លើកយកនូវសេចក្តីនៃព្រះពុទ្ធដីកា និង ព្រះអដ្ឋកថាមកក្នុងទីនេះ ព្រោះចង់ឱ្យប្អូនបានដឹងថា តើអ្នកប្រាជ្ញទាំងឡាយលោកមានការតិះដៀលនិងចៀសវាងយ៉ាងណាខ្លះចំពោះបុគ្គលពាល? ហើយនឹងដើម្បីប្អូនបានដឹងថា ការសេពគប់ជាមួយបុគ្គលពាល គឺធ្វើឱ្យយើងខាតប្រយោជន៍ និងមានអន្តរាយជាច្រើនដែលអាចកើតមានដល់យើង ។

ក្នុងពេលកំពុងសិក្សាហើយមានការសេពគប់ ជាមួយបុគ្គលពាល ប្អូននឹងក្លាយជាមនុស្សដូចតទៅ :

១- គេចសាលា

២- មិនទទួលការស្រឡាញ់អំពីលោកគ្រូអ្នកគ្រូនឹងមិត្តរួមថ្នាក់

៣- មានការសិក្សាថយចុះ

៤- បង្កបញ្ហាក្នុងសាលា

៥- បាត់បង់នូវការស្រឡាញ់ពីមាតាបិតានិក្រុមគ្រួសារ

*"ហើយអនាគត គឺបែបនេះ"*





ប្អូនៗពិតជាបានឃើញ បានស្គាល់ នូវពាក្យស្លោកខាងក្រោមនេះ

"កុមារជាទំពាំងស្នងឫស្សី"

"យុវជនយុវតីជាសសរទ្រូងនៃប្រទេសជាតិ"

"ពលរដ្ឋជាស្ថាបនិកនៃមាតុភូមិ"

ដើម្បីក្លាយខ្លួនជាកុមារឈានមុខ យុវជនឆ្នើម ពលរដ្ឋល្អ ជាដំបូង ប្អូនត្រូវចាប់ផ្តើមពីការខិតខំក្រេបជញ្ជក់យកចំណេះវិជ្ជា ដោយស្មារតីឧស្សាហ៍ព្យាយាម។ ប្អូនត្រូវរៀនហើយរៀនទៀត រៀនដោយមានការតស៊ូ អំណត់អត់ធន់ រហូតទទួលបាននូវចំណេះដឹងនិងចំណេះធ្វើពិតប្រាកដ គឺការសិក្សាផ្សារភ្ជាប់និងការអនុវត្តន៍ ។ មនុស្សដែលមានចំណេះដឹងខ្ពង់ខ្ពស់និងមានវិជ្ជាជីវៈល្អ ទើបសមមានឈ្មោះជាពលរដ្ឋពេញលេញ។ សូមប្អូន១ កុំទុកឱ្យ"និទាឃរដូវនៃវ័យ"[១] កន្លងហួសឱ្យសោះ ។ បើប្អូនបណ្តែតបណ្តោយ ឱ្យពេលវេលាដ៏មានតម្លៃនេះកន្លងហួសទៅ ដោយពុំបានធ្វើអ្វីសោះនោះ ប្អូននឹងមានវិប្បដិសារីស្តាយក្រោយជាពុំខាន ហើយការស្តាយក្រោយរបស់ប្អូន វានៅតែជាការស្តាយក្រោយដដែល ទោះជាប្អូនខំយំសោកស្តាយក្រោយយ៉ាងណាក៏ដោយ ព្រោះប្អូនមិនអាចទាញបង្វិលពេលវេលាឱ្យថយក្រោយវិញបានឡើយ ដូចជាទឹកទន្លេដែលហូរចូល

១ គឺវ័យរបស់យុវជនដែលពោរពេញទៅដោយកម្លាំងពលំ ភាពសប្បាយរីករាយ ក្នុងការសិក្សានិងក្តីសង្ឃឹម ដូចគ្នានិង និទាឃរដូវ ដែលគេឃើញមានផ្ការីកស្គុសស្គាយគ្រប់ទិសទីហើយ បក្សាបក្សីក៏សប្បាយខ្សៀវខ្សារក្រោមពន្លឺថ្លាដ៏ល្អល្អះនៃព្រះអាទិត្យ ។

សមុទ្រ មិនអាចហូរពីសមុទ្រមកទន្លេវិញបានឡើយ ។ តទៅនេះ ប្អូននឹងបានឃើញកំណាព្យមួយដែលមានចំណងជើងថា "ស្តាយវ័យកុមារ" កំណាព្យនេះ តុបតែងតាមលំនាំបទកគតិ និយាយអំពីការសោកស្តាយរបស់កុមារម្នាក់ ដែលកាលពីកុមារពុំបានយកចិត្តទុកដាក់ក្នុងការសិក្សា ។

**ស្តាយវ័យកុមារ**

ស្តាយវ័យកុមារ វរវ័យថ្លៃថ្លា វ័យអត់កង្វល់
វ័យស្រស់ត្រកាល វ័យអត់ខ្វាយខ្វល់ វ័យអំណោយផល
ដល់ការសិក្សា ។

ភ្ញាក់ឡើងញញឹម មុខមានសង្ឃឹម ប៉ប្រិមស្រស់ថ្លា
មាតាលួងលោម លុយទៅសាលា ស្បៀកពាក់ហ៊ឺហា
ចិន្តាសប្បាយ ។

ត្រឡប់វិលវិញ គ្មានទុក្ខទោមនេញ ទឹកមុខស្រស់ស្រាយ
មាតាបម្រុង ប្រុងប្រៀបរៀបបាយ ស្នាដៃអ្នកម្តាយ
បំប៉នកូនស្ងួន ។

កូនគួរខំរៀន ចំណេះរបៀន របស់ជាប់ខ្លួន
វិជ្ជាជាទ្រព្យ គាប់គួរថែថូន វិជ្ជាមាំមួន
សម្បូរសប្បាយ ។

*សេចក្តីល្អជាលម្អនៃជីវិត*

កូនបែរជាខ្ជិល ជាកូនរមិល គុណឪពុកម្តាយ
ភ្លើតភ្លើនភ្លេចរៀន ភ្លេចក្តីអន្តរាយ រហើររហាយ[1]
សប្បាយភ្លេចខ្លួន ។

វិប្បដិសារី តិះដៀលដេរស្តី ដេរស្តីផ្ទួនៗ
កូនភ្ញាក់រលឹក ទឹកស្រណោះខ្លួន ស្តាយខួរក្បាលរូន[2]
អារម្មណ៍មិនស្ងប់ ។

ប្អូនៗកូនខ្មែរ គួរគប្បីតែ រៀនឱ្យចេះចប់
រៀនហើយរៀនទៀត រៀនឱ្យចេះសព្វ ដល់ទីបញ្ចប់
គង់តែសប្បាយ ។

អំពើពាលា គ្រឿងញៀននានា ល្បែងអន្តរាយ
សេពគប់អ្នកប្រាជ្ញ ប្រាជ្ញារីកសាយ សេពគប់អបាយ[3]
ក្លាយជាអ្នកខ្លៅ ។

១ រហើររហាយ (គុ) ដែលច្រាស់ច្រាល់ដោយកម្លាំងកាម រើរុះរវើរវាយ មិនតាំងនៅយូរមួយកន្លែង។ ២ រូន (គុ) ផុស ឬ ស្អុយខូច។ ខួរក្បាលរូន មានន័យថា ខួរក្បាលល្ងើល្ងើ ប្រើការមិនកើតដូចស៊ុតរូន។ ៣ អបាយ (ន) ទីរងទុក្ខ សេចក្តីវិនាស។

ប្អូនត្រូវដឹងថា ចំណេះវិជ្ជាគឺជាឃ្លាំងទ្រព្យដ៏សំខាន់ សម្រាប់មនុស្សម្នាក់ៗ ព្រោះអ្នកមានចំណេះ គឺអាចធ្វើកិច្ចការណាដែលលំបាកបានដោយងាយ និងមានប្រសិទ្ធភាពល្អ។ ដូច្នេះហើយប្អូនត្រូវប្រឹងរកវិជ្ជាមកដាក់ក្នុងខ្លួនឱ្យបានច្រើន។ បើប្អូនមានចំណេះដឹងផ្នែកបច្ចេកទេស និងចំណេះដឹង ផ្នែកវិទ្យាជីវិតក្នុងខ្លួនហើយ ប្អូននឹងទៅជាមនុស្សម្នាក់ដែលមានសិរីសួស្តី និងសុភមង្គលល្អ ។ ព្រោះថាគ្រប់ទីកន្លែង មិនថាលើដីក្នុងទឹកលើអាកាសទេ គឺសុទ្ធតែត្រូវការចំណេះទាំងអស់ តែសូមកុំភ្លេច រក្សាកាយវាចាចិត្តឱ្យបានល្អផង ។

ជនទាំងឡាយ គេតែងសរសើរ និង លើកតម្កើងនូវបុគ្គលអ្នកចេះដឹង ហើយក៏ច្រើនគ្នាណាស់ដែរ ដែលគេតែងតែតិះដៀលរិះគន់ និងស្អប់ខ្ពើមចំពោះបុគ្គលពាលល្ងង់ខ្លៅ។ ដូច្នេះហើយ ចូរប្អូនសម្លឹងមើលនូវទោសនៃការសេពគប់នឹងបុគ្គលពាលឱ្យបានច្រើន ដើម្បីកុំឱ្យចិត្តរបស់ ប្អូនឈានទៅរកការពេញចិត្តនឹងបុគ្គលពាល មានន័យថា កុំសេពគប់ជាមួយជនពាល មិនសេពគប់ មិនមែនឈ្មោះថាស្អប់ទេ គឺគ្រាន់តែយើងមិនបានចូលរួមគំនិតនឹងធ្វើកម្មជាមួយតែប៉ុណ្ណោះ ។

ហើយម្យ៉ាងទៀត បងសូមឱ្យប្អូនជាមនុស្សឆ្លាតឈ្លាស ក្នុងការដោះស្រាយនូវរាល់បញ្ហាដែលកើតឡើងអំពីបុគ្គលពាល ដោយសន្តិវិធី

ពុំចាំបាច់ប្រើអំពើហិង្សាឡើយ ។ ព្រោះវាអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ជាទីបំផុត ដល់ខ្លួនយើងព្រមទាំង អ្នកឯទៀតដែលយើងរាប់អាន ។

"មនុស្សដែលខ្លាំងពូកែ មិនមែនដោយអាស្រ័យការកាប់ចាក់នោះទេ គឺដោយអាស្រ័យជំនាញ ឬ ទេពកោសល្យ "



ប្អូនត្រូវចាំថា កាលណាបើយើងសេពគប់ជាមួយបុគ្គលពាលហើយ នៅរាល់ករណីយកិច្ចទាំងអស់ មិនអាចឈានទៅរកការសម្រេចបានឡើយ ថែមទាំងធ្វើឱ្យយើងទៅជាមនុស្សអនាថាគ្មានទីពឹង និង មានកេរ្តិ៍ឈ្មោះមិនល្អ ដល់វង្សត្រកូល ភូមិឃុំស្រុកនិងដល់ប្រទេសជាតិទៀតផង ។ មុននឹងយើងសេពគប់ជាមួយនរណាម្នាក់ ត្រូវពិនិត្យមើលឱ្យបានល្អិតល្អន់សិន ដើម្បីកុំឱ្យស្តាយក្រោយ និងខាតពេលឥតប្រយោជន៍ ។

បុគ្គលពាលកាលបើយើងសេពគប់ហើយ តែងនាំឱ្យប្រព្រឹត្តនូវអបាយមុខទាំង ៨ ប្រការ គឺ:

១- លេងស្រី[១]

២- បរិភោគទឹកស្រវឹង សេពគ្រឿងញៀន

៣- ស៊ីចាយសប្បាយខ្ជះខ្ជាយ

៤- លេងល្បែងភ្នាល់ ល្បែងស៊ីសង

៥- ដើរយប់តាមច្រកល្ហកញើយៗ

៦- ដើរមើលមហោស្រពរបាំរាំរែកញើយៗ

៧- ប្រកបរឿយៗនូវសេចក្តីខ្ជិល

---

*១ មនុស្សជាមួយនឹងការងារ ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទំព័រទី ៧*

៨- សេពគប់បាបមិត្ត ។

ការប្រព្រឹត្តិអបាយមុខទាំងនេះ ទោះបីមិនមែនជាការបៀតបៀនអ្នកដទៃដោយត្រង់ចំពោះក៏ដោយ តែវាជាការបៀតបៀនដោយអែបខាង១ សន្សឹម១ស្ងាត់១។ ដូចជាអ្នកខ្លះទៅជាមនុស្សឥតបានការ ខ្លះទៅជាទីរង្កៀសភ័យខ្លាច និងរំខានដល់អ្នកផ្ទះជិតខាង បញ្ចុះតម្លៃនៃជីវិតខ្លួនឯង ធ្វើឱ្យបុត្រភរិយា ឬ វង្សត្រកូលធ្លាក់ចុះសន្សឹម១ក្លាយទៅ ជាត្រកូលអន់ថយ ប្រាសចាកនូវសេចក្តីសុខ ។ ការប្រព្រឹត្តនូវអបាយមុខរមែងកាត់បន្ថយនូវស្មារតី ដែលជារបស់មានតម្លៃបំផុតសម្រាប់ជីវិតមនុស្ស គឺជាការបៀតបៀនសង្គមដោយប្រយោល ឬ ដោយត្រង់តែម្តងព្រោះការបាត់បង់នូវស្មារតីហ្នឹងឯង ។

អបាយមុខគឺជាយានជំនិះ សម្រាប់ជិះទៅកាន់ឋាននរក ជាថ្នាំពុលជាហេតុនាំឱ្យប្រកបកិច្ចការដែលមានទុក្ខទោស គឺជាប្រធាននៃសេចក្តីហិនហោចសព្វបែបយ៉ាង ។ តាមពិតទៅ មនុស្សយើងមិនគួរយកខ្លួនឯងធ្វើជាសត្រូវទេ ព្រោះមិនមាននរណាស្រលាញ់ខ្លួនរបស់យើង ជាងយើងខ្លួនឯងឡើយ ហើយក៏មិនមានអ្នកណាជួយយើង ឱ្យដូចជាយើងជួយខ្លួនឯងដែរ ។ ដូច្នេះ ប្អូនគ្រប់គ្នាត្រូវតាំងចិត្តជួយខ្លួនឯង ប្រឹង

ប្រែងកុំឱ្យបាត់បង់ស្មារតី ឱ្យស្មារតីរឹងរឹតតែចម្រើនឡើង ទើបជាការប្រពៃ ។

មនុស្សមួយចំនួនមិនចង់ជួបនិងមិនចង់យកនូវបុគ្គលពាល មកធ្វើជាមិត្តទេ គឺគេខំគេចពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត រហូតអ្នកខ្លះទៀតនោះ អុចធូបប្រាថ្នាថា "សូមកុំឱ្យជួបបុគ្គលពាលជាមិត្ត" តែទីបំផុតនៅតែជួបមិត្តដែលជាបុគ្គលពាលនោះដដែល ។ នោះគឺមកតែពីការដែលមិនបានស្គាល់ អំពីលក្ខណៈរបស់មិត្តល្អ និង លក្ខណៈរបស់មិត្តអាក្រក់ហ្នឹងឯង ។

## អំពីការសេពគប់មិត្ត

ប្អូនមិនត្រូវសេពគប់បាបមិត្តទេ បើសេពគប់ៗតែជាមួយបណ្ឌិតបានហើយ តែសូមប្រយ័ត្ន កុំឱ្យបាបមិត្តក្លាយជាសត្រូវ ហើយបើនៅតែមាន សូមប្អូនចៀសឱ្យឆ្ងាយ បើចៀសមិនផុតទេ ត្រូវមានស្មារតី ឬប្រុងប្រយ័ត្នគ្រប់ពេលទាំងអស់ ។ ប្អូនត្រូវរៀនឱ្យស្គាល់ មនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តបួម នេះជារឿងសំខាន់ណាស់ កុំប្រហែសឱ្យសោះ ។ តើប្អូនមានដឹងទេថា មនុស្សដូចម្ដេច ជាមិត្តអាក្រក់ ?

មនុស្សខ្លះជាមិត្តក្នុងរោងសុរា ខ្លះទៀតទាល់តែមានការពឹងពាក់ទើបមករាក់ទាក់ ហើយហៅយើងថាមិត្តៗអ៊ីចឹងទៅ ខ្លះទៀតហៅយើងថាសំឡាញ់ក្នុងទីចំពោះមុខ តែក្រោយខ្នងធ្វើការចងគំនុំព្យាបាទ ច្រណែនចង់ឱ្យយើងវិនាស ហើយសប្បាយចិត្តនៅពេលដែលយើងធ្លាក់បុណ្យស័ក្តិ ។ ឥឡូវនេះ សូមប្អូនសិក្សាអំពីលក្ខណៈរបស់មិត្តជាមួយនឹងបងបន្តិចសិន ដើម្បីស្រួលចំណាំ តែមិនពិស្ដារទេ បើប្អូនចង់បានពិស្ដាសូមអាននៅក្នុងសៀវភៅ មនុស្សជាមួយនឹងការងារ ដែលរៀបរៀងដោយលោកគ្រូ អគ្គបណ្ឌិត ប៊ុត សាវង្ស ទៀតចុះ។

## មិត្តដែលមិនគួរសេពគប់មាន ៤ ប្រភេទ

- បុគ្គលដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន
- បុគ្គលដែលល្អតែសម្ដី
- បុគ្គលដែលនិយាយចាក់បណ្ដោយ
- បុគ្គលដែលនាំទៅរកផ្លូវវិនាស

### ១ -លក្ខណៈរបស់បុគ្គលដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន

ចង់បានអ្វីៗពីយើងតែម្យ៉ាង ពោលសរសើរស្មើរសុំស្មើរមិនសុំឱ្យមិនចេះគ្រប់ បើមិនបានថាយើងជាមនុស្សអាក្រក់

- ឱ្យតិចតែចង់បានច្រើនមកវិញ ( យករបស់តូច ទាក់របស់ធំ)
- មិនជួយគ្នាក្នុងពេលមានអាសន្ន
- រាប់អានគ្នាព្រោះតែឃើញប្រយោជន៍អ្វីមួយសម្រាប់ខ្លួនគេ

**២- លក្ខណៈរបស់បុគ្គលដែលល្អតែសម្ដី**

- ទទួលភាក់ទាក់តែនឹងរបស់ដែលអស់ទៅហើយ មាននិយាយថា ( ទាល់តែថ្ងៃហ្នឹងបានសម្លាញ់ឯងមក បើមកពីម្សិលមិញត្រូវម៉ាច់តែម្ដង ព្រោះមានរបស់ជាច្រើនដែលខ្ញុំបានទុកឱ្យឯង តែថ្ងៃនេះអស់ហើយ ព្រោះគ្នាស្មានថាឯងឥតមក)
- ចាំលើកក្រោយ ខែក្រោយ ខ្ញុំឱ្យឯង ឬ ជួយឯង
- ប្រសិនបើខ្ញុំមាន ខ្ញុំនឹងជួយឯង ( ទោះបីគេមាន ក៏គេមិនឱ្យយើងដែរ គេនិយាយឱ្យគ្រាន់តែស្រួលស្ដាប់តែប៉ុណ្ណោះ)
- ពេលដែលយើងត្រូវការពឹងពាក់ គេនិយាយថា គ្មានពេល ឬ របស់ខូចជាដើម ទោះជារបស់គេនៅទំនេរក៏ដោយ ។

**៣- លក្ខណៈរបស់បុគ្គលនិយាយចាក់បណ្ដោយ**

- ពេលដែលយើងធ្វើអាក្រក់ ក៏មិនហាមឃាត់ តែបែរជានិយាយថា អីចឹងក៏បានដែរ ទាំងដែលយើងនោះ ជាមនុស្សល្ងង់ស្រាប់

☼ ពេលដែលយើងធ្វើល្អ ក៏យល់ព្រមថាល្អដែរ ពេលណាយើងយល់ថាអាក្រក់ក៏ថាអាក្រក់ដែរ( និយាយសរសើរបញ្ជោរលើកជើងធ្វើឱ្យយើងវង្វេងដោយសាររូបគេតែម្តង)

☼ និយាយសរសើរចំពោះមុខមានប៉ុន្មានចេញទាំងអស់

☼ និយាយរឿងអាក្រក់ពីយើងក្នុងទីកំបាំងមុខ ។

**៤ លក្ខណៈរបស់បុគ្គលដែលនាំទៅរកផ្លូវវិនាស**

☼ ជាអ្នកសេពនូវសុរាមេរ័យនិងគ្រឿងញៀន

☼ ត្រាច់ទៅតាមច្រកល្ហកខុសកាលពេលវេលា ចូលចិត្តដើរលេងយប់

☼ ចូលចិត្តដើរមើលល្បែងមហោស្រព

☼ ចូលចិត្តលេងល្បែងភ្នាល់គ្នា មានបៀរអាប៉ោងជាដើម ។

បុគ្គលទាំង ៤ ប្រភេទនេះ យើងមិនគួរយកមកធ្វើជាមិត្តឡើយ ព្រោះកាលណាដែលយើងមានបុគ្គលប្រភេទទាំងនេះនៅជិត ពិតជាខាតបង់ច្រើន គឺខាតបង់ទាំងពេលវេលាមាសប្រាក់ទ្រព្យសម្បត្តិ រហូតដល់អាយុជីវិតទៀតផង ។ ហេតុនេះ ចូរប្អូនៗគ្រប់គ្នា នាំគ្នាអានហើយពិចារណាឱ្យបានស៊ីជម្រៅនូវសេចក្តីនៃពាក្យនីមួយៗរបស់បុគ្គលទាំងនោះហើយបើប្អូនមិនយល់ទេ នោះប្អូនមុខជាបានបុគ្គលទាំងនោះមកជាមិត្ត

ដោយមិនដឹងខ្លួន។ នៅទីបំផុតទិសដៅ និង អនាគតនៃជីវិតរបស់ប្អូន នឹងត្រូវរលាយសូន្យ ដូចក្រមួនត្រូវថ្ងៃ រឺដូចជាអំបិលដែលត្រូវទឹកយ៉ាងនោះឯង ។

ចំពោះប្អូនខ្លួនឯងផ្ទាល់ ពេលដែលបានស្គាល់ពីលក្ខណៈរបស់បុគ្គលទាំងនោះហើយ មិនត្រូវធ្វើព្រងើយហើៗ ធ្វើតាមតែចិត្តនឹកឃើញនោះទេ ត្រូវគិតឱ្យបានច្បាស់លាស់សិនសឹមធ្វើ ។ ក្នុងការគិតនោះទៀតក៏មិនមែនសុទ្ធតែត្រឹមត្រូវទាំងអស់នោះដែរ ព្រោះវាអាស្រ័យទៅលើកម្រិតនៃការចេះដឹង ហើយការចេះដឹងនោះទៀត ក៏មិនមែនចេះតែម្នាក់យើងទេ អ្នកដទៃទៀតក៏គេចេះដែរ ហើយអាចថានឹងចេះច្រើនជាងយើងរាប់រយដងទៅទៀត ។ ប្រភពនៃចំណេះដឹង មិនមែនចេញមកតែពីយើងម្នាក់ទេ គឺវាចេញមកពីមាតាបិតា លោកគ្រូអ្នកគ្រូ មិត្តភក្តិ និងសង្គមបរិយាកាសដែលនៅជុំវិញនៃយើងផងដែរ ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់ថា :

បុគ្គលអ្នកប្រព្រឹត្តនូវចំណុចទាំងឡាយ ៤ នឹងបាននូវសេចក្តីរីកចម្រើនគឺ សេពគប់ជាមួយសប្បុរស១ ស្តាប់នូវពាក្យទូន្មានរបស់សប្បុរស១ ត្រិះរិះឱ្យស្គាល់របស់ល្អ ឬ អាក្រក់ ដោយឧបាយដែលត្រឹមត្រូវ១ ប្រព្រឹត្ត

ឱ្យបានត្រឹមត្រូវ ដូចដែលយើងបានគិតដោយឧបាយត្រូវទំនងរួចមកហើយ។[១]

ខាងក្រោមនេះ ប្អូនៗនឹងបានអានកំណាព្យមួយទៀត ដែលបរិយាយអំពីយុវជនម្នាក់បោះបង់ការសិក្សាដោយធ្លាក់ខ្លួនចាញ់ឃោសនារបស់ពួកជួញដូរថ្នាំញៀន។ យុវជននោះ បានរ៉ាយរ៉ាប់ប្រាប់យើង ឱ្យដឹងពីឥទ្ធិពលអាក្រក់នៃថ្នាំញៀន និងបង្កឱ្យអ្នកសេពថ្នាំញៀន វិនាសអន្តរាយ ហើយអំពាវនាវកុំឱ្យអ្នកដទៃទៀតយកគម្រាប់តាមគេ និងបដិសេធមិនទទួលយកគ្រឿងញៀនមកសាកសេពជាដាច់ខាត។

## ឱ! មិនត្រូវអាវ ឱ!

(បទពាក្យ៧)

សម្តីផ្អែមល្ហែមថែមបញ្ចោរ ខ្ញុំឡើងជំនោរលោលូកល
មិនដឹងអីថាគេភូតភរ ខិតខំគាំទ្ររបរបោក។
គ្រឿងញៀនអាភៀនរួមកញ្ឆា យ៉ាម៉ាយ៉ាបាននាំទុក្ខសោក
មិត្តអើយកុំល្ងើលង់ចាញ់បោក គេក្តីឈ្មោះថយថោកដោយថ្នាំឆ្កួត។

---

១ ប្រជុំកងធម៌ថ្នាក់ត្រី ទំព័រទី ៨

កុំសាកកុំសេពវាឱ្យសោះ ចាត់បង់កេរកោះតាមគេអួត
គន់គិតឆ្គាំឆ្គងដូចឆ្កែឆ្កួត ពីតពួកដៃតាមបក្សពួកពាល ។
គ្រឿងញៀនញាំញីញូកញោតិមិត្ត ងុបងល់ងងឹតទាំងរសៀល
វង្វេងវង្វាន់កណ្ដាលវាល ពួកពាលអូសទាញទៅនរក ។
គ្រឿងញៀនបំពានសរីរាង្គ បំពុលសារពាង្គវិញ្ញាណស្លក់
ស្លេកស្លាំងស្គាំងស្គមទ្រមគគ្រក់ លង់ឈ្លក់ក្នុងភក់ភពអន្ធការ ។
អ្នកសេពគ្រឿងញៀនហ៊ានហួសបទ មិនអាចកំណត់ចិត្តអាត្មា
ហ៊ានកាប់ហ៊ានចាក់ហ៊ានប្រហារ ទោះជាមាតាបិតាខ្លួន ។
ពេលអស់អត់អាចម៍សាច់អាភៀន រូបរាងធ្លាប់ញៀនញ័រផ្ទួន១
ញាក់ញ័រជើងដៃដូចអង្រួន រោលរាល់រុកគួនខ្លួនខ្លោចផ្សា ។
ទ្រាំទ្រមិនបានហ៊ានលួចប្លន់ សម្រក់សម្រន់រាល់តណ្ហា
ឱ្យតែបានថ្នាំតាមប្រាថ្នា លែងគិតគួរថាធ្វើខុសច្បាប់ ។
គ្រឿងញៀនប្រធានទោសទុក្ខទណ្ឌ ជាឈ្នាន់ជាន់ទៅរកក្ដីស្លាប់
ពូជពង្សវង្សត្រកូលអោនអាប់ ដកខ្លួនឱ្យឆាប់ទាន់ញៀនតិច ។
មិត្តអើយខ្ញុំខុសព្រោះខ្ញុំអឿ ខ្ញុំជក់ខ្ញុំជឿជនមានល្បិច

ខ្ញុំភ្លើភ្លាត់ភ្លាំងចាញ់កលកិច្ច ចងចាំជានិច្ចកំហុសច្បង[១] ។
សូមផ្ដែសូមផ្ដាំឃើញខ្ញុំស្រាប់ កុំយកតម្រាប់កុំសាកល្បង
គ្រឿងញៀនហៅរកសូមប្អូនបង ឆ្លើយសង "ទេ!មិនត្រូវការទេ!" ។

(ដោយលោកគ្រូ ម៉ម សឿង)

នេះឯងជាលទ្ធផលដែលបានមកពីការសេពគប់មិត្តមិនល្អ តែបើមិត្តល្អវិញ មិនមែនបានផលអាក្រក់បែបនេះទេ គឺនឹងរីកចម្រើន។ ចុះធ្វើដូចម្ដេចទៅ ទើបស្គាល់អ្នកនេះ អ្នកនោះ ថាជាមិត្តល្អបាន ? ចូរប្អូនកុំលំបាកពេក ព្រោះលក្ខណៈ របស់មិត្តល្អ ឬ មិត្តដែលគួរសេពគប់នោះ គឺព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែងទុកហើយ គឺនៅខាងក្រោមនេះ ។

## មិត្តដែលគួរសេពគប់មាន ៤ ប្រភេទ

- មិត្តដែលមានឧបការ
- មិត្តដែលរួមសុខរួមទុក្ខ
- មិត្តដែលប្រាប់នូវប្រយោជន៍



[១] កំបុង (គុ) ដែលជាប្រធានធំជាងគេ ដែលជាដើមបង្អស់ ។កំហុសច្បង គឺកំហុសធំបំផុត

- មិត្តដែលមានការឈឺឆ្អាល ។

**១ លក្ខណៈរបស់មិត្តដែលមានឧបការៈ** ✓

☞ រក្សាមិត្តដែលធ្វេសប្រហែស ( ជួយដាស់តឿនមិត្ត)

☞ ជួយយកចិត្តទុកដាក់ពេលមិត្តភ្លេចរបស់របរ

☞ ជួយគ្នាក្នុងគ្រាមានអាសន្ន ថែមទាំងធ្វើឱ្យជាទីសង្ឃឹមនៃយើង

☞ សុំតិចឱ្យច្រើន ដោយចិត្តស្មោះ

**២ លក្ខណៈរបស់មិត្តដែលរួមសុខរួមទុក្ខ** ✓

☞ ប្រាប់នូវរឿងដែលអាថ៌កំបាំងដល់មិត្តដោយមិនលាក់លៀម

☞ ជួយបិទបាំងនូវរឿងអាថ៌កំបាំងរបស់មិត្ត

☞ មិនបោះបង់មិត្តក្នុងគ្រាមានវិបត្តិ ឬ ភ័យ

☞ សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍មិត្ត

៣ មិត្តដែលប្រាប់នូវប្រយោជន៍✓

☞ ហាមឃាត់មិនឱ្យធ្វើនូវអំពើអាក្រក់

☞ ដឹកនាំមិត្តឱ្យប្រព្រឹត្តនូវអំពើល្អ

☞ ឱ្យមិត្តស្តាប់នូវពាក្យដែលល្អ ដែលមិនធ្លាប់បានស្តាប់

☞ ប្រាប់ផ្លូវទៅកាន់ទីកន្លែងដ៏ត្រេកអរ បានដល់ផ្លូវបុណ្យកុសល

៤ លក្ខណៈរបស់មិត្តដែលមានការឈឺឆ្អាល✓

☞ មិនត្រេកអរនៅពេលដែលមិត្តមានសេចក្ដីវិនាស

☞ ជួយត្រេកអរចំពោះការរីកចំរើនរបស់មិត្ត

☞ ហាមឃាត់ចំពោះមនុស្សដែលនិយាយអាក្រក់អំពីមិត្ត

☞ សរសើរនូវមនុស្សណា ដែលនិយាយរឿងល្អ និយាយពីគុណរបស់មិត្ត។[១]

---

១ បិដកលេខ ១៩ ទំព័រ ៨១

ចំណុចទាំងអស់ខាងលើនេះហើយ ដែលធ្វើឱ្យយើងអាចស្វែងរក
នូវមិត្តល្អបាន ព្រោះវាជាកញ្ចក់សំរាប់ឆ្លុះឱ្យឃើញពីគុណភាពពិត របស់
មិត្ត ឬ តម្លៃពិតរបស់មិត្ត ដែលយើងកំពុងតែសេពគប់ ឬ បំរុងនឹង
សេពគប់ ។

## ចរិតមនុស្ស

ប្អូនៗ កាលដែលបានសិក្សាអំពីលក្ខណៈរបស់មិត្តល្អ មិត្តអាក្រក់
និងប្រភេទនៃបុគ្គលពាលរួចមក ក៏អាចស្គាល់ថា ណាជាបាបមិត្ត និង
ណាជាកល្យាណមិត្តបានហើយ ប៉ុន្តែដើម្បីឱ្យរឹតតែច្បាស់ទៅទៀតនោះ
គឺប្អូនត្រូវសិក្សាឱ្យបានស្គាល់អំពីចរិតរបស់មនុស្សថែមទៀត ។

មនុស្សយើងភាគច្រើនមិនសូវយល់ពីចិត្តអ្នកដទៃទេ ហើយបញ្ហា
ផ្សេងៗ មានការចាញ់បោកគេ និងឈ្លោះទាស់ទែងគ្នាជាដើម ភាគច្រើន
ក៏កើតមកពីការមិនយល់គ្នានេះដែរ ។ សូម្បីគូស្វាមីភរិយា ដែលបានរស់
នៅរួមគ្នារាប់សិបឆ្នាំមកហើយក្តី ក៏នៅតែមានបញ្ហាខ្លះៗដែរ ។ ប៉ុន្តែបើ
មនុស្សយើងចេះយល់ចិត្តគ្នា និងអាចប៉ាន់ស្មានពីព្រឹត្តិកម្ម រវាងគ្នានិងគ្នា
ហើយដឹងថា គួរនិយាយយ៉ាងណា គួរធ្វើយ៉ាងណា ជាមួយមនុស្ស
ប្រភេទផ្សេងៗគ្នាបាន នោះបញ្ហាក្នុងគ្រួសារ ឬ ក្នុងសង្គម ក៏ថយចុះតិចៗ
ទៅតាមលំដាប់ដែរ ។ម្យ៉ាងទៀត យើងអាចនឹងកើតមានក្តីអាណិត ចេះ

អត់ឱនឱ្យគ្នា ចេះថ្នាក់ថ្នមចិត្តអ្នកដទៃ ហើយអាចរស់នៅរួមគ្នាយ៉ាងមានសេចក្តីសុខ ។

ដូចនេះ ការស្វែងយល់ពីចរិតមនុស្ស គឺជាអ្វីដែលយើងចាំបាច់គួរធ្វើ ព្រោះការយល់ដឹងពីចរិតផ្សេងៗ អាចធ្វើឱ្យយើងសង្រួមចិត្តបាន កើតមានក្តីមេត្តាដល់ខ្លួនឯងនិងអ្នកដទៃ និងអាចប៉ាន់ប្រមាណហេតុការណ៍បាន ព្រោះថាយើងអាចយល់ដឹងពីខ្លួនឯង និងយល់ដឹងពីអ្នកដទៃផង ។

ចរិត មកពី [1] ចរ+ឥ+ត ចរ ប្រែថា ត្រាច់ទៅ ប្រព្រឹត្តទៅ។ ចរិត ប្រែថា កិរិយាប្រព្រឹត្ត កិរិយាត្រាច់ទៅ ឬ ប្រែម្យ៉ាងទៀតថា( [2] ការប្រព្រឹត្តិ កិរិយា មារយាទ ឬកពារ បែបបទ ) ចរិតល្អចរិតមិនល្អជាដើម។ សរុបសេចក្តីឱ្យខ្លីមកថា ការប្រព្រឹត្តិរបស់ចិត្ត ដំណើរត្រាច់ទៅនៃចិត្ត ឬ កិរិយាមារយាទឬកពាររបស់មនុស្ស ទាំងនេះ ឈ្មោះថាចរិតមនុស្ស ។

---

១ បទានុក្រម ធម្មបទ ភាគ ២ ទំព័រ ១៨៥ បន្ទាត់ ទី ៦

២ វចនានុក្រមខ្មែរ ភាគ ១ ទំព័រ ១៨៩ បន្ទាត់ ទី ២១

## មនុស្សមានចរិត ៦ យ៉ាង

១- រាគចរិត ប្រព្រឹត្តទៅតាមរាគៈ ចូលចិត្តស្អាត

២- ទោសចរិត ប្រព្រឹត្តទៅតាមទោសៈ ឆាប់ខឹង

៣- មោហចរិត ប្រព្រឹត្តទៅតាមមោហៈ ភ្លេចច្រើន

៤- សទ្ធាចរិត ប្រព្រឹត្តទៅតាមសទ្ធា ឆាប់ជឿ

៥- ពុទ្ធិចរិត ប្រព្រឹត្តទៅតាមបញ្ញា គិតច្រើនៗជឿខ្លួនឯង

៦-វិតក្កចរិត ប្រព្រឹត្តទៅតាមវិតក្ក ត្រិះរិះច្រើន រាយមាយ [១] ។

**១ រាគៈចរិត**[២] ជាមនុស្សចូលចិត្តភាពស្អាត ពូកែតែងខ្លួន សំលៀកបំពាក់ របស់របរប្រើប្រាស់ ទីកន្លែង អាហារបរិភោគ ក៏ត្រូវតែឆ្ងាញ់ល្អស្អាតនឹងទាន់សម័យដែរ ។ រាគចរិត ចូលចិត្តធ្វើការណាដែលមានមុខមានមាត់ ចំណែកមនុស្សដែលគេរាប់អាន គឺជាមនុស្សដែលមានរូបរាងល្អស្រស់សង្ហារស្អាតនិងមានទ្រព្យច្រើន ។ ជាមនុស្សមានចិត្តអណ្តែតអណ្តូង ស្រមើលស្រមៃ ចង់បាននេះចង់បាននោះ ចង់ក្លាយជាយ៉ាងនេះ ចង់ក្លាយជាយ៉ាងនោះ ហើយចូលចិត្តដឹងឮនិងមើល នូវរឿង

---

*១ ឧបករណ៍ សមថ វិបស្សនា របស់លោកគ្រូ អ៊ិន ភេន ទំព័រ ៣៦*

*២ សិល្បៈសម្របតាមចរិតមនុស្ស របស់ លោក ចាន់ រិទ្ធី*

ដែលស្រើបស្រាល ។ អ្នកខ្លះមានភាគៈចរិតជ្រុលពេក ក៏មានអាការប្រព្រឹត្តចេញមកក្នុងលក្ខណៈ អែបឡែប អែបអបប្រចុបប្រចែង។ ភាគៈចរិតជាមនុស្សចូលចិត្តជួយសង្គ្រោះអ្នកដទៃ ប៉ុន្តែក្នុងបំណងចង់ឱ្យគេដឹងគុណ ឬ ចង់បានអ្វីមួយពីអ្នកនោះ បើពុំនោះទេ ក៏ចង់ឱ្យអ្នកដទៃស្រលាញ់ ។ មុននឹងជួយអ្នកណាម្នាក់ គេតែងមានបំណងអ្វីមួយលាក់ទុកក្នុងចិត្ត តែបើមិនបានដូចដែលខ្លួនត្រូវការ ក៏ត្រៀមជាស្រេចដើម្បីនឹងរករឿងឡូឡាខឹងរាលដាលភ្លាម ។

ក្នុងការប្រើពាក្យសម្ដី គេមានការប្រយ័ត្នប្រយែងណាស់ នឹងតែងជៀសវាង មិនប្រើពាក្យសម្ដីណា ដែលធ្វើឱ្យបំផ្លាញអារម្មណ៍របស់អ្នកដទៃដែលជាហេតុនាំឱ្យខូចប្រយោជន៍របស់គេ ។ ពេលនិយាយ គេអាចគ្រប់គ្រងទឹកសម្លេង ឱ្យយើងស្ដាប់ទៅ ទទួលអារម្មណ៍ថាល្អ ផ្អែមល្ហែមពិរោះនិងទន់ភ្លន់ ។ គេនិយាយស្ដីផ្អែមល្ហែមពិតមែន ប៉ុន្តែចិត្តរបស់គេមានការគិតផ្សេងពីការនិយាយនោះ ព្រោះនេះជាទម្លាប់របស់គេ។



ស្របគ្នានោះដែរ គេក៏ចូលចិត្តពាក្យសម្ដីផ្អែមល្ហែមដែរ ចូលចិត្តពាក្យយកចិត្តយកថ្នើម ទោះបីពោលដោយចិត្តស្មោះ ឬ មិនស្មោះក៏ដោយ ។មនុស្សចរិតនេះ មិនអាច

ទ្រាំស្តាប់សម្តីកំហកខ្លាំងបានទេ។

ភាគៈចរិត ជាមនុស្សមានចិត្តឆាប់ប្រែប្រួល ពុំសូវគោរពពាក្យសន្យាប៉ុន្មានទេ សូម្បីមិត្តភក្តិដែលគេរាប់អាន បែរជាមិនរាប់អាន ឬ ពុំសូវរាក់ទាក់ទៅវិញ ពេលណាដែលគេបានប្រយោជន៍អ្វីមួយពីមិត្តភក្តិ ។ មនុស្សប្រភេទនេះ មានកលល្បិចច្រើនណាស់ ហើយគេអាចបោកបញ្ឆោតអ្នកដទៃបានដោយងាយ ដោយអាស្រ័យពាក្យសម្តីដ៏ផ្អែមល្ហែមរបស់គេហ្នឹងឯង ។

**-ទោសចរិត** មនុស្សដែលមានលក្ខណៈជាទោសចរិត គឺជាមនុស្សដែលគោរពតួនាទី បទបញ្ជា ,និង ស្មោះត្រង់មឹងម៉ាត់ជាងចរិតដទៃទៀត។ ហេតុនេះហើយទើបធ្វើឱ្យមនុស្សមានទោសចរិត អត់ទ្រាំមិនបានពេលជួបនឹងមនុស្សដែលមិនគោរពបទបញ្ជា មិនគោរពពាក្យសម្តី មិនគោរពពេលវេលាឬមិនគោរពវិន័យ ។

**ការស្តីបន្ទោស**



ក្នុងការប្រើពាក្យសម្តី គេចូលចិត្តនិយាយត្រង់ទៅត្រង់មក មិនខ្លាចអ្នកណាឡើយ ។ សម្លេងនៃការនិយាយរបស់គេឮ ខ្លាំងៗ អាចស្តាប់បានច្បាស់

ស្ដាប់ទៅគួរឱ្យញញើត ។សម្ដីរបស់គេហាក់ដូចជាទ្រគោះ ស្ដាប់ទៅពុំសូវពិរោះ ព្រោះគេមិនសូវមានការក្រែងចិត្តរបស់អ្នកស្ដាប់ទេ ។ គេនិយាយហាក់ដូចជាលឿនបន្តិច ព្រោះមិនបានពួសម្លេងរបស់ខ្លួនក្នុងពេលដែលកំពុងនិយាយនោះទេ ទើបធ្វើឱ្យអ្នកស្ដាប់ទទួលអារម្មណ៍ ថា ហាក់ដូចជាមិនសុភាព និងបង្កប់នូវហិង្សាផង ។

ទោសចរិត ជាមនុស្សត្រង់ទៅត្រង់មក មិនមានកលល្បិច ម៉ាត់ណាម៉ាត់ហ្នឹង ជាហេតុធ្វើឱ្យយើងយល់ថា គេជាមនុស្សមិនគួរសេពគប់ បើមើលពីសំបកក្រៅ ។ ម្យ៉ាងទៀត មនុស្សដែលមានចរិតបែបនេះ ធ្វើឱ្យយើងពឹងពាក់បាន ដោយគេជាអ្នកមានគោលការណ៍ ធ្វើតាមបទបញ្ជា មិនប្រកាន់បក្សពួក ហើយមានចិត្តស្មោះចំពោះអ្នកដទៃ និយាយពាក្យណាពាក្យហ្នឹង មិនមែនជាមនុស្សវាយប្រហារក្រោយខ្នង តែអាចវាយចំពីមុខតែម្ដង ។ បើជេរគឺជេរចំពោះមុខ មិនជេរក្រោយខ្នង ហើយត្រៀមជាស្រេចនឹងជេរ គ្រប់ពេលគ្រប់ទីកន្លែង ទោះជានៅកណ្ដាលអង្គប្រជុំ ឬ នៅកន្លែងសាធារណៈក៏ដោយ គេមិនគិតខ្លាចក្រែងក្រសែភ្នែកមនុស្សម្នា និងមិនខ្លាចក្រែងចិត្ត ឬការទទួលអារម្មណ៍របស់អ្នកស្ដាប់

ឡើយ លក្ខណៈនេះ បានធ្វើឱ្យមនុស្សដែលជាទោសចិត្តមានអំណាច ជាទីខ្លាចក្រែងរបស់អ្នកដទៃដោយធម្មជាតិ ។



**-មោហចរិត** មនុស្សដែលមានលក្ខណៈជាមោហចរិត ជាមនុស្ស មិនសូវនិយាយស្តី ហើយតែងងោកងុយ ឬ ស្ងាបជាប្រចាំ ។ ពេលអាន សៀវភៅ ឬ ស្តាប់ការអធិប្បាយមួយសន្ទុះធ្វើភ្នែករីម១ ឬលក់តែម្តង ។ គេជាមនុស្សតាំងសតិមិនបាន មិនដឹងថាអ្វីល្អអ្វីអាក្រក់ ហើយជាធម្មតា គេក៏មិនចូលចិត្តធ្វើការអ្វីដែរ បើមិនមានអ្នកដទៃដាស់តឿនទេនោះ តែ បើជ្រុលជាធ្វើហើយ ធ្វើមិនចង់ឈប់។ ជួនកាលគេគេង ឬ គិតអណ្តែត អណ្តូងទៅតាមអារម្មណ៍រាយមាយពេញមួយថ្ងៃមិនបានធ្វើការក៏មាន ។

មោហចរិត ច្រើនមានការធុញទ្រាន់ សោះកក្រោះ ពេលធ្វើអ្វីមួយ តែងទទួលអារម្មណ៍ថាលំបាក ហួសពីសមត្ថភាពរបស់ខ្លួន ឬ គិតច្រើន ឈឺក្បាលជាដើម។ មោហចរិត មិនសូវយកចិត្តទុកដាក់នឹងអ្នកដទៃទេ ចូលចិត្តនៅកន្លែងស្ងាត់ៗតែឯង ព្រោះគេជាមនុស្សមានការអៀនខ្មាស

ច្រើន សូម្បីតែការតែងខ្លួន ក៏មិនសូវស្អាតប៉ុន្មានដែរ ដោយសារតែខ្លាច អ្នកដទៃគេបង្អាប់ហ្នឹងឯង ។




ក្នុងការប្រើពាក្យសម្ដីវិញ បុគ្គលមោហចរិត តែងតែនិយាយតិចៗ ទន់ភ្លន់ មិនសូវខូចអារម្មណ៍ មិនសូវខឹងនឹងនរណា តែងញញឹមញយៗ តែញញឹម បែបធុញថប់ ។ មនុស្សប្រភេទនេះ មិនចូលចិត្តចូល ក្នុងចំណោមទីប្រជុំជនដែលមានមនុស្សច្រើនទេ ព្រោះមិនដឹងថា ត្រូវរៀបចំខ្លួនយ៉ាងម៉េច ត្រូវនិយាយយ៉ាងម៉េចនឹងមនុស្សទាំងនោះ ។ បើសិនមានមិត្តភក្ដិនាំទៅលេងផ្ទះ គេទៅតែមិនអង្គុយកន្លែងដែលជុំគ្នាទេ គេតែងអង្គុយពីក្រោយអ្នកទាំងនោះ ឬ គេចៀសជញ្ជាំងតែម្ដង ។

សរុបសេចក្ដីមក មនុស្សដែលស្ថិតនៅក្នុងក្រុមមោហចរិត ជាទូទៅ ច្រើនតែជាមនុស្សល្អ នេះបើនិយាយអំពីសណ្ដាប់ធ្នាប់សង្គម ជាមិត្តដែលគួរសេពគប់ គួរឱ្យស្រលាញ់ ព្រោះគេមិនសាងអំពើអាក្រក់ ទាំងក្នុងការគិត ទាំងក្នុងការនិយាយ និង ក្នុងការប្រព្រឹត្ត ។ ពោលគឺមោហចរិត មិនគិតអាក្រក់ មិនកេងប្រវ័ញ្ច មិនបោកបញ្ឆោត មិននិយាយឱ្យនរណាខូចចិត្ត មិននិយាយផ្ដេផ្ដា និង ជាមនុស្សអាចប្រមូលអារម្មណ៍បានល្អ ។

**-សទ្ធាចរិត** ជាទូទៅ មនុស្សដែលស្ថិតនៅក្នុងក្រុមសទ្ធាចរិត ជាបុគ្គលចង់ក្លាយជាមនុស្សល្អនិងចេះដឹង ចង់ឱ្យគ្រួសារ ឬ សង្គមឆ្ពោះទៅកាន់សេចក្តីរីកចម្រើន ហេតុនេះហើយ បានជាគេខំស្វែងរកបុគ្គល ឬ ជំនឿអ្វីមួយ ដែលគេយល់ថា អាចជួយឱ្យគេមានសេចក្តីសុខចំរើនបាន ហើយគេត្រៀមជានិច្ចដើម្បីលះបង់ នូវរបស់សព្វបែបយ៉ាងទាំងអស់ចំពោះបុគ្គលឬ ជំនឿនោះដោយហោចទៅ សូម្បីតែជីវិត ក៏ហ៊ានលះបង់ដែរ ។ ជាមួយគ្នានេះដែរ សទ្ធាចរិត ជាមនុស្សត្រចៀកស្រាល឵ ឆាប់ជឿពាក្យគេ ដែលជាហេតុធ្វើឱ្យអ្នកដទៃបោកបញ្ឆោតបានដោយងាយ ។



មានបុគ្គលខ្លះទៀតនោះ ប្រើការជឿរបស់ខ្លួនខ្លាំងពេក រហូតដល់អ្នកដទៃយករបស់ដែលមិនគួរជឿ មកបោកបញ្ឆោត ក៏ជឿតាមដែរ ដូចជាបញ្ឆោត ថា សត្វមានបុណ្យ ដើមឈើស័ក្តិសិទ្ធ ឬ មានមនុស្សអ្នកមានបុណ្យចុះមកជួយជាដើម ដោយភ្លេចគិតអំពីផលនៃកម្លាំងពលកម្ម និងការប្រព្រឹត្តិរបស់ខ្លួន ។ មានបុគ្គលមួយចំនួន ត្រូវគេបោកបញ្ឆោតហើយ ក៏ពោលសរសើរអ្នកបោកបញ្ឆោតនោះ ដោយប្រការផ្សេងៗ ថាល្អយ៉ាងនេះល្អយ៉ាងនោះ ទាំងដែលមិនដឹងថាខ្លួនត្រូវគេបោកទៀត ។ ហេតុនេះ

សូមមនុស្សគ្រប់រូប មុននឹងជឿតាមពាក្យនរណាមួយ ត្រូវត្រិះរិះជាមុនសិន ត្រូវប្រើការជឿបូកនិងបញ្ញាទើបជាការល្អ ។



**-ពុទ្ធិចរិត** មនុស្សដែលស្ថិតនៅក្នុងក្រុមពុទ្ធិចរិត ជាមនុស្សដែលគិតអ្វីៗច្រើនមានហេតុផល និង មើលហេតុការផ្សេងៗតាមសេចក្តីពិត មិនថែមថយ មិនមានលំអៀងព្រោះស្រលាញ់ ស្អប់ ឬ ខ្លាច មិនចូលចិត្តយកគំនិតរបស់ខ្លួនទៅលាយឡំនឹងគំនិតអ្នកដទៃ ។ ពុទ្ធិចរិត ច្រើនយកគំនិតខ្លួនជាធំ មិនងាយជឿអ្នកដទៃ កំណត់ផែនការបានយ៉ាងត្រឹមត្រូវ មានសេចក្តីព្យាយាមច្រើន ហ៊ានទទួលខុសត្រូវនូវរាល់ទង្វើដែលខ្លួនបានធ្វើ ។ គេជាមនុស្សប៉ិនសង្កេត ហេតុនេះទើបពុទ្ធិចរិត អាចនិងវិភាគរឿងផ្សេងៗបានតាមការពិត ។ ម្យ៉ាងទៀត ពុទ្ធិចរិត ស្ថិតក្នុងស្ថានភាពបច្ចុប្បន្ន ដោយការតាំងចិត្តសង្កេត ថាតើមនុស្សដែលកំពុងនិយាយជាមួយ គឺជាមនុស្សបែបណា សភាពនៃចិត្តរបស់មនុស្សនោះក្នុងខណៈនោះដូចម្តេច ជាហេតុធ្វើឱ្យគេអាចយល់ដឹងពីភាគីម្ខាងទៀត និង ដឹងពីវិធីនិយាយជាមួយបុគ្គលនោះ។ ស្របពេលនោះដែរ គេក៏មានការសង្កេត ពីលក្ខណៈប្រែប្រួលផ្សេងៗរបស់ភាគីម្ខាង

ទៀតដែរ ដូចជាទឹកមុខ ឬ ទឹកសម្លេង ទើបគេអាចសម្របគំនិត ការនិយាយស្តី និងការប្រព្រឹត្តិរបស់ខ្លួនបានយ៉ាងសាមញ្ញនិងឆាប់រហ័ស ។ ពុទ្ធិចរិត ពេលឃើញអ្នកដទៃមានបញ្ហា ក៏កើតសេចក្តីមេត្តា ហើយតែងផ្តល់ការណែនាំឱ្យដល់អ្នកដទៃ ក្នុងបំណងឱ្យគេដោះស្រាយបញ្ហាបានផងដែរ ។ យើងអាចសង្កេតឃើញបានយ៉ាងច្បាស់ថា មនុស្សដែលមានពុទ្ធិចរិត មានទឹកមុខស្រស់ស្រាយ ភ្នែកមានពន្លឺចិញ្ចាច មុខមិនសូវកើតទុក្ខ ព្រោះមានកំលាំងចិត្តនឹងនរ ។ បុគ្គលដែលមានចរិតបែបនេះអាចរាប់បានថា ជាកល្យាណមិត្ត ជាមនុស្សដែលអាចជឿទុកចិត្តបាន និងជាមនុស្សដែលចង់ឱ្យអ្នកដទៃរីកចំរើន។ បុគ្គលប្រភេទនេះ មិនមែនផ្ញើលតាមគេ និង មិនធ្វើតាមតែនឹកឃើញទេ ។ ពុទ្ធិចរិត មុននឹងសម្រេចចិត្តធ្វើអ្វីមួយ តែងគិតដល់ចំនុចពីរយ៉ាង គឺ ១ ចំណង់ចំណូលចិត្តរបស់ខ្លួន ២ ភាពស្ទាត់ជំនាញរបស់ខ្លួនឯង ។

**-វិតក្កចរិត** ជាមនុស្សពូកែគិត ពូកែនិយាយ ពូកែសួរ ចូលចិត្តបញ្ចេញមតិ មិនសូវទុកចិត្តអ្នកដទៃ ច្រើនលាក់បាំងនូវអ្វីដែលខ្លួនត្រូវការ ពូកែចាប់កំហុសអ្នកដទៃ មិនសូវគោរពពាក្យសន្យា មានចិត្តគិតផ្សេងពីការនិយាយ ពាក្យសម្តីមានអត្ថន័យច្រើនយ៉ាង មិនចេះខ្វិលក្នុងការនិយាយ និយាយស្តីមិនចេះខ្លាចប៉ះពាល់ដល់អ្នកដទៃ ពូកែអួត តែង

គិតច្រណែនឈ្នានីសអ្នកដទៃ ចូលចិត្តធ្វើរឿងតូចឱ្យក្លាយជារឿងធំ មុខក្រញូវមិនសូវញញឹម តែងគិតថា អ្នកដទៃយកប្រៀបលើខ្លួនជានិច្ច ពេលមានអ្វីប៉ះទង្គិចចិត្តក៏ខឹងឆេវឆាវ ប្រើពាក្យសម្ដីគំរោះគំរើយឧស្សាហ៍ព្យាយាមធ្វើការមិនរើសមុខ ហើយអាចធ្វើបានយ៉ាងឆាប់រហ័ស តែមិនសូវមានរបៀបរៀបរយល្អទេ ព្រោះគេខ្វះការយកចិត្តទុកដាក់ ហើយច្រើនចង់ដឹង ចង់ឮ និងឃើញនូវ




រឿងដែលឥតប្រយោជន៍ ពូកែរិះគន់គេ លើកតម្កើងខ្លួនឯង មិនចូលចិត្តធ្វើអ្វីភ្លាមៗទេ តែងតែចាំពេលនេះចាំពេលនោះ សម្លេងនិយាយដាច់ៗ គេចូលចិត្ត និយាយលឿន គិតលឿន សរសេរលឿន និង ធ្វើអ្វីក៏លឿន តែមិនផ្ចិតផ្ចង់ទេ ដែលគេធ្វើយ៉ាងនេះ ក៏ ព្រោះតែចង់ឱ្យអ្នកដទៃ ដឹងថាខ្លួនគេពូកែ ឆ្លាតធ្វើអ្វីមិនឆ្គង និង រវៀសរវៃជាងអ្នកឯទៀត ។

ក្រៅពីនេះ វិតក្កចរិត ចូលចិត្តធ្វើរឿងងាយឱ្យក្លាយជារឿងពិបាក រឿងតូចឱ្យក្លាយជារឿងធំ ដើម្បីបង្អួតអ្នកដទៃ នឹង ចង់បញ្ជាក់ថា ខ្លួនឯងពូកែអាចមើលអ្វីធ្លុះ ។ សម្ដីរបស់គេស្ដាប់ពេលដំបូង ហាក់ដូចជាល្អ តែបើស្ដាប់យូរទៅៗ ញយៗទៅ ក៏ធុញថប់យ៉ាងងាយ ។ តាមពិត

វិតក្កចរិត មិនមែនពូកែពិតប្រាកដទេ ព្រោះមនុស្សដែលពូកែ រមែងអាចអធិប្បាយអ្វីផ្សេងៗ យ៉ាងខ្លីៗសមល្មមត្រូវចំណុច និង ងាយយល់ តែវិតក្កចរិតពុំមានលក្ខណៈទាំងនោះឡើយ ។

ការតែងខ្លួនគេតែងចាប់នេះផ្សំនោះ បំណងឱ្យល្អជាង់គេ មើលទៅឆើតឆាយ ប៉ុន្តែមិនមានភាពស្រស់ស្អាតទេ ដោយសារតែគេមានការខ្វល់ខ្វាយចិត្តជាប្រចាំ ។

ចរិតទាំង ៦ នេះ គឺមានក្នុងមនុស្សគ្រប់រូប ឥតមាននរណាមួយដែលមិនមាននូវចរិតទាំង៦នេះទេ គឺមនុស្សម្នាក់ៗ ត្រូវមានចរិតទាំង៦នេះឯង ។ ក្នុងចំណោមចរិតទាំង៦ នៃបុគ្គលម្នាក់ បើចរិតណាមួយចេញមុខខ្លាំងជាងគេ ក៏សន្មតនូវបុគ្គលនោះ ថាជាចរិតនោះៗ អ៊ីចឹងទៅ ។

កាលដែលសិក្សាអំពីចរិតនេះមក ធ្វើឱ្យយើងយល់ និង ស្គាល់មនុស្សបានមួយចំនួនហើយ តែបងដឹងថា ប្អូនៗពិតជាមានការលំបាកក្នុងការសំគាល់ចរិតមនុស្សឱ្យបានច្បាស់ណាស់ ព្រោះថាធម្មជាតិនៃចិត្តរបស់មនុស្ស គឺជារឿងមួយដែលយល់បានដោយលំបាក តែបងសូមប្រាប់ប្អូនថា ដែលយើងអាចយល់និងស្គាល់ នូវគុណតម្លៃរបស់មនុស្សបាន គឺវាអាស្រ័យទៅលើទង្វើ គឺការប្រព្រឹត្តិរបស់បុគ្គលនោះ យ៉ាងណាមិញ ការសំគាល់ចរិតមនុស្សក៏ដូចគ្នា ព្រោះថាមនុស្សយើង មិនអាចមើលចិត្ត

របស់អ្នកដទៃឃើញទេ ព្រោះចិត្តជាធម្មជាតិមួយដែលមិនមានរូប វាគ្រាន់តែជានាមធម៌តែប៉ុណ្ណោះ ដែលអាស្រ័យនៅខាងក្នុងនៃមនុស្ស ។ ប៉ុន្តែដែលយើងអាចយល់និងស្គាល់អំពីចិត្ត ឬ ចរិតរបស់បុគ្គលនោះបាន លុះត្រាតែពិនិត្យនូវសកម្មភាព ឬ ទង្វើរបស់បុគ្គលនោះ។ ព្រោះទង្វើទាំងនោះ ដែលអាចស្តែងចេញទៅបាន ក៏ដោយអាស្រ័យចិត្តជាអ្នកដឹកនាំ ចិត្តជាធំ ចិត្តជាប្រធាន បើចិត្តគិតយ៉ាងណាហើយ ទង្វើក៏យ៉ាងនោះដែរ ។

ដើម្បីសំគាល់ចរិតរបស់មនុស្សឱ្យបានច្បាស់ គឺប្អូនត្រូវរៀន អំពីវិធីមើលនូវចរិតរបស់មនុស្ស ដូចខាងក្រោមនេះ ។

## - វិធីមើលចរិតមនុស្ស [១]

លោកអ្នកប្រាជ្ញ តែងកំណត់សម្គាល់នូវចរិតមនុស្ស ដោយចំណុច ៥ យ៉ាង គឺ :



-ដោយឥរិយាបថ

-ដោយការងារ ឬ ទង្វើ

-ដោយភោជន ឬ ការបរិភោគ

---

១ មហាដីកា បរមត្ថមញ្ជូសា ភាគ ១ ទំព័រ ៨១

-ដោយកិរិយាមើល

-ដោយកិរិយាប្រព្រឹត្តិធម៌

**១- សំគាល់ដោយឥរិយាបថ**

មនុស្សដែលជារាគៈចរិត កាលបើដើរដោយដំណើរជាប្រក្រតីនោះ តែងមានដំណើរសមរម្យ បែបជាមនុស្សឆ្លាតឈ្លាស កាលនឹងដាក់ជើងចុះក្តី លើកឡើងក្តី ក៏តែងលើកដាក់ដោយសន្សឹមៗស្រាលៗ ( មិនថា ដេក ដើរ ឈរ អង្គុយទេ គឺត្រូវតែស្អាតនឹងសមរម្យជានិច្ច ) ឯស្នាមជើងនៃបុគ្គលនោះ មានសណ្ឋានកោងបន្តិច ឬ ខ្ពស់កណ្តាល ( បាទជើងផតកណ្តាល) ។

-មនុស្សដែលជាទោសចរិត កាលបើដើរដោយដំណើរជាប្រក្រតីនោះ តែងដើរចុចចុងជើងដូចគេជីក កាលនឹងដាក់ជើងចុះក្តី លើកឡើងក្តី ក៏តែងតែលើកដាក់បែបរហ័សរហួនមិនបង្អង់ ឯស្នាមជើងនៃបុគ្គលនោះ មានសណ្ឋានធ្ងន់មុខ ( បើពាក់ស្បែកជើងវិញ តែងសឹកខាងមុខខ្លាំងជាងខាងក្រោយ) ។

-មនុស្សដែលជាមោហចរិត កាលបើដើរដោយដំណើរជាប្រក្រតីនោះ តែងដើរទើសទាស បែបញ្ញើតញ្ញើម កាលនឹងដាក់ជើងចុះក្តី កាលនឹង

លើកជើងឡើងក្តី ក៏តែងលើកដាក់បែបញ៉ូរ។ ឯស្នាមជើងនៃបុគ្គលនោះ មានសណ្ឋានផ្ងូន់ក្រោយ ឬ អូសកែង ។

សេចក្តីនេះមានឧប្បត្តិហេតុនៃមាគណ្ឌិយាសូត្រ ក្នុងគម្ពីរធម្មបទ ដ្ឋកថាភាគ ២ ថា :

រត្តស្ស ហិ ឧក្កុដិកំ បទំ ភវេ
ទុដ្ឋស្ស ហោតិ សហសានុបីឡិតំ
មុឡ្ហស្ស ហោតិ អវកឌ្ឍិតំ បទំ
វិវដច្ឆទស្ស ឥទមីទិសំ បទំ ។

សេចក្តីថា ស្នាមជើងនៃមនុស្សរាគចរិតនោះ បែបកោងកណ្តាល ស្នាមជើងនៃមនុស្សទោសចរិតនោះ បែបផ្ងូន់មុខ ស្នាមជើងនៃមនុស្ស មោហចរិតនោះ បែបផ្ងូន់ក្រោយ ឬ អូសកែង ឯស្នាមជើងយ៉ាងនេះ( មិន កោង មិនផ្ងូន់មុខ មិនផ្ងូន់ក្រោយ គឺស្មើស្អាត)ជាស្នាមជើងនៃបុរសដែល មានកិលេសជាគ្រឿងបិទបាំង បើកចេញហើយ ។

- ម្យ៉ាងទៀត មនុស្សរាគចរិត កាលបើឈរតែងមានជំហរ សមរម្យស្រួលបួលល្អ គួរឱ្យគាប់ចិត្ត ។

- មនុស្សទោសចរិត កាលបើឈរ តែងមានជំហរបែបរឹង។ ច្រងេងច្រងាង មិនសូវសមរម្យ ។

- មនុស្សមោហៈចរិត កាលបើឈរ តែងមានជំហរបែបទ្រេតទ្រោតមិនសូវនឹងនួន ។ កំណត់ឥរិយាបថអង្គុយរបស់ជន ទាំង៣( រាគ ទោស មោហចរិត)នេះ មានទំនងប្រហែលគ្នានឹងឈរដែរ មនុស្សរាគចរិតតែងមានដំណើរមិនសូវរហ័ស កាលបើក្រាលកម្រាលដេក ក៏ ក្រាលរៀបស្មើល្អ វេលាប្រះខ្លួនដេកប្រះតិចៗ ហើយរៀបចំជើងដៃដាក់ស្រួលបួល ទើបដេកដោយការសមរម្យ កាលបើមានគេដាស់ មិនសូវក្រោកប្រញាប់រួសរាន់ទេ ហើយតែងនិយាយតបមកវិញដោយសំដីតិចៗ ហាក់ដូចជាមានរង្កៀស ។

- មនុស្សទោសចរិត តែងមានដំណើររហ័សរហួន កាលនឹងក្រាលកម្រាលដេក ក៏ក្រាលឱ្យតែបានៗ មិនមានរបៀបរៀបរយ វេលានឹងប្រះខ្លួនដេក តែងធ្វើមុខក្រញូវ កាលបើមានគេដាស់តែងក្រោកឡើងដោយរហ័សរហួន វេលានឹងនិយាយក៏និយាយពាក្យធំៗ ហាក់ដូចជាខឹង ។

- មនុស្សមោហចរិត តែងមានដំណើរញញៀតញញៀម កាលនឹងក្រាលកម្រាលដេក ក៏ ក្រាលមិនស្អាត វេលានឹងដេកតែងដាក់ដៃជើងផ្តេសផ្តាសឱ្យតែបានៗ ហើយច្រើនដេកផ្កាប់ផង កាលបើមានគេដាស់តែងនិយាយមិនច្បាស់ថាជាអ្វីៗនោះឡើយ ។

- ចំពោះសទ្ធាចរិត មានទំនងប្រហែលគ្នានឹងរាគចរិត ឯពុទ្ធិចរិត មានទំនងប្រហែលគ្នានឹងមោហចរិត នេះបើពោលដោយឥរិយាបថ ។

## ២- សំគាល់ដោយកិច្ចការ

- មនុស្សរាគចរិត កាលបើធ្វើការអ្វីៗ មានបោសច្រាសជាដើម វេលានិងចាប់ដងអំបោស ក៏ ចាប់កាន់ដោយស្រួលបួល មិនកញ្ជក់កញ្ឆែង វេលានឹងបោសច្រាសទៀត ក៏មិនក្រវាត់ក្រវែងខ្ចាត់ខ្ចាយ បោសស្អាតស្មើល្អ គរទុកជាគំនរដូចជាបាច់ផ្កា ។

- មនុស្សទោសចរិត កាលនឹងបោសច្រាស តែងកាន់ដងអំបោសនោះយ៉ាងមាំ ហើយធ្វើយ៉ាងរហ័សប្រញាប់ប្រញាល់ វេលានឹងបោសក៏បោសខ្លាំងៗ ខ្ចាត់ខ្ចាយធូលីទៅខាងទាំងពីរ ហើយបោសទីស្ថាននោះសោត ក៏មិនបានស្អាតល្អដែរ ។

- មនុស្សមោហចរិត កាលនឹងបោសច្រាស តែងកាន់អំបោសនោះដោយបន្ធើៗ វេលានឹងបោសៗវិលវក់ទៅមកដដែលៗ ហើយទីស្ថាននោះមិនបានស្អាតល្អទេ ។

- មនុស្សរាគចរិតនោះ កាលបើស្លៀកពាក់ គ្រឿងសំលៀកបំពាក់មិនសូវតឹងពេកធូរពេក ចេះប្រមូលឱ្យជាបរិមណ្ឌល មើលទៅស្អាតសមរម្យ ( នេះបើនិយាយពីការឃ្លុំគ្រងសម្រាប់ព្រះសង្ឃ ចំណែក

ជនទូទៅធម្មតាវិញ តែងស្លៀកពាក់បែបសមរម្យរៀបរយល្អ អ្នកខ្លះមានរាគចរិតខ្លាំង គេតែងស្លៀកបែបស៊ីវិល័យទៅតាមសម័យនិយម របស់សម័យនោះៗ ដោយពុំសូវមានការអៀនខ្មាសឡើយ ) ។

-មនុស្សទោសចរិត វេលាស្លៀកពាក់ តែងទាញរឹតគ្រឿងស្លៀកពាក់នោះឱ្យតឹងមាំ តែមិនសូវស្មើល្អទេ (នេះបើនិយាយពីព្រះសង្ឃ)ចំណែកមនុស្សទូទៅធម្មតាវិញ តែងស្លៀកពាក់ឱ្យតែជិតៗ មិនសូវគិតពីស្អាត ឬ មិនស្អាតអីប៉ុន្មានទេ ធម្មតាៗ ។

-មនុស្សមោហចរិត វេលាស្លៀកពាក់ គ្រឿងប្រដាប់ច្រើនធូរៗ រយីករយាកមិនសូវសមរម្យ ( ឬ មិនសូវថែទាំសម្លៀកបំពាក់ជាដើម ) ។

## ៣- សំគាល់ដោយភោជន

- មនុស្សរាគចរិត ច្រើនពេញចិត្តនឹងភោជន ( អាហារ ) ដែលស្អាតឈ្ងុយឆ្ងាញ់ កាលនឹងបរិភោគ (តែងដួសបាយមិនតិចពេក មិនច្រើនពេក ល្មមទំពារបានស្រួល ការទំពារៗ បែបសមរម្យល្អ ) តែងសង្កេតដឹងរសដែលឆ្ងាញ់ពិសា ហើយធ្វើអាការបាក់ដូចជាមិនរវាសរវាមពេក បើបានរបស់អ្វីឆ្ងាញ់ពិសា សូម្បីបន្តិចបន្តួចក៏ត្រេកអរដែរ ។

- ទោសចរិត ច្រើនគាប់ចិត្តនឹងភោជនដែលសៅហ្មង មានរស ជូរហឹរ ជាដើម ការបរិភោគច្រើនពមបាយពេញៗមាត់ ហើយមិនសូវ

កំណត់ដឹងរសឆ្ងាញ់ពិសាទេ បែបរវាសរវាមខ្លាំង (បរិភោគលឿន ) បើមានវត្ថុបន្តិចបន្តួច ជារបស់អាក្រក់ច្រើនខឹង ។

- មោហចរិត ជាអ្នកមានសេចក្តីគាប់ចិត្តនឹងវត្ថុអ្វីៗ មិនសូវប្រាកដ ម្តងដូច្នេះម្តងដូច្នោះ កាលបើបរិភោគតែងដួសបាយតិចៗ តែងធ្វើគ្រាប់បាយឱ្យជ្រុះរាត់រាយក្នុងភាជន(ចាន ឬថាសសម្រាប់ដាក់បាយ ) ច្រើនប្រឡាក់មាត់ដោយភោជនផង កំពុងបរិភោគចិត្តមិនសូវនឹងច្រើនគិតផ្តេសផ្តាស ។

## ៤- សំគាល់ដោយការមើល

- មនុស្សរាគចរិត បើសិនជាបានឃើញរូបអ្វីបន្តិចបន្តួចជាទីគាប់ចិត្ត តែងសម្លឹងមើលយូរក្រដាក់ភ្នែក ហាក់ដូចជាអស្ចារ្យក្នុងចិត្ត ច្រើនជាប់ចិត្តនឹងគុណគេ សូម្បីគេមានគុណបន្តិចបន្តួច ក៏មិនសូវភ្លេចគុណ ហើយជាអ្នកមិនសូវប្រកាន់ទោសដែលមានប្រាកដ កាលនឹងចៀសចេញទៅ មិនសូវភ្លេចគុណគេ តែងមានសេចក្តីអាល័យគុណ ។

- មនុស្សទោសចរិត ប្រសិនបើបានឃើញរូបអ្វីមួយបន្តិចបន្តួចមិនជាទីគាប់ចិត្ត តែងមិនសម្លឹងមើលយូរទេ ច្រើនមានចិត្តខ្នាំងខ្ចប់និងទោស សូម្បីទោសបន្តិចបន្តួចក៏អាក់អន់ដែរ ហើយជាអ្នកមិនកាន់យក

គុណដែលមានប្រាកដ កាលនឹងចៀសចេញទៅតែងភ្លេចគុណគេ មិនអាឡោះអាល័យឡើយ ។

- មនុស្សមោហចរិត ប្រសិនបានឃើញរូបអ្វីនីមួយ ច្រើនមានចិត្តប្រព្រឹត្តទៅផ្សេងៗ បើឮគេនិន្ទាក៏និន្ទាតាមគេ មិនអាចដឹងការអ្វីដោយខ្លួនឯង ហើយជាមនុស្សព្រងើយៗ ភ្លេចៗ ។

- ម្យ៉ាងទៀត ចរិតទាំង ៦ នោះ កាលបើសំគាល់ដោយកិច្ចដោយភោជន និងដោយការមើលនោះ សទ្ធាចរិតប្រហែលគ្នានឹង រាគចរិត ពុទ្ធិចរិតប្រហែលគ្នានឹងទោសចរិត វិតក្កចរិតប្រហែលគ្នានឹងមោហចរិត មិនជាខុសគ្នាអីប៉ុន្មានទេ ។

## ៥- សំគាល់ដោយការប្រព្រឹត្តិធម៌

**មនុស្សរាគចរិត តែងមានធម៌ ៨ យ៉ាង គឺ:**

ក- **មាយា** បិទអំពើទុច្ចរិតរបស់ខ្លួនមិនឱ្យគេដឹង

ខ- **សាថេយ្យំ** មានសេចក្តីអួតអាង

គ- **មានោ** ប្រកាន់ខ្លួនថាអញប្រសើរជាងគេ

ឃ- **បាបិច្ឆតា** ប្រាថ្នាខុស ខ្លួនគ្មានសទ្ធានិងសីល ថា ខ្លួនមានសទ្ធានិងសីល( ឬបញ្ចោញនូវសកម្មភាពអ្វីមួយដែលធ្វើអ្នកដទៃយល់ថាគេជាមនុស្សមានគុណសម្បត្តិ រឺគុណវិសេសអ្វីម្យ៉ាងដែលអ្នកដទៃមិនមាន )

ង- **មហិច្ឆតា** ប្រាថ្នាច្រើន លោភច្រើន ក្នុងចតុប្បច្ច័យ(សម្លៀកបំពាក់ គ្រឿងបរិភោគ ទីជំរក ថ្នាំព្យាបាល )និងបញ្ចកាមគុណ (រូប សម្លេង ក្លិន រស និង ការប៉ះពាល់ត្រូវរាងកាយ )

ច- **អសន្តុដ្ឋិតា** មិនមានសន្តោស ( លោភច្រើន )

ឆ- **សិង្គំ** ឈ្លាសវៃប៉ិនប្រសប់

ជ- **ចាបល្យំ** មានចិត្តឃ្លេងឃ្លោងដោយគ្រឿងបរិក្ខារ (របស់ប្រើប្រាស់ឬ គ្រឿងអលង្ការ វីសម្ភារៈផ្សេងៗ) ។

**មនុស្សទោសចរិត តែងមានធម៌ ៦ យ៉ាង គឺ:**

ក- **កោធោ** មានសេចក្តីក្រោធច្រើន

ខ- **ឧបនាហោ** ចងសេចក្តីក្រោធទុកជាប្រចាំមិនរសាយ

គ- **មក្ខោ** លុបគុណគេ រមិលគុណ

ឃ- **បលាសោ** ប្រឡងវាសនា គឺធ្វើឬកស្មើនឹងគេ

ង- **ឥស្សា** ច្រណែនលាភសក្ការៈ និងការគោរពរាប់អាន

ច- **មច្ឆរិយំ** កំណាញ់លំនៅ កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់គុណ កំណាញ់ធម៌ កំណាញ់ចំណេះដឹង មានគំនិតចង្អៀតចង្អល់ច្រើន មិនខ្វល់ពីអារម្មណ៍របស់អ្នកដទៃ ។

**មនុស្សមោហចរិត តែងមានធម៌ ៧ ប្រការ គឺ :**

ក- **ថីនំ** ងងុយច្រអូសកាយជាប្រចាំ

ខ- **មិទ្ធំ** ងោកងុយច្រអូសចិត្តជាប្រចាំ

គ- **ឧទ្ធច្ចំ** រវើរវាយ ឬ រាយមាយ

ឃ- **កុក្កុច្ចំ** សេចក្តីតូចចិត្តនិងការស្តាយក្រោយ

ង- **វិចិកិច្ឆា** សន្ទិះសង្ស័យ ( ឆ្ងល់គ្មានព្រំដែន)

ច- **អាទានគ្គាហិតា** ប្រកាន់មាំដោយឧបាទាន ( មានសេចក្តីប្រកាន់ ច្រើន)

ឆ- **ទុប្បដិនិស្សគ្គិតា** លះបង់បានដោយកម្រ ។

**មនុស្សសទ្ធាចរិត តែងមានធម៌ ៧ ប្រការ គឺ :**

ក- **មុត្តចាគតា** បរិច្ចាគទានដោយរូសរាន់( លះបង់ភ្លាម១ )

ខ- **អរិយានំ ទស្សនកាមតា** ចង់ឃើញព្រះអរិយបុគ្គល ( បុគ្គលប្រសើរ បុគ្គលអស្ចារ្យ អ្នកមានគុណធម៌ខ្ពស់ )

គ- **សទ្ធម្មំ សោតុកាមតា** ចង់ស្តាប់ព្រះសទ្ធម្ម ( ព្រះធម៌ )

ឃ- **បាមោជ្ជពហុលតា** ត្រេកអរីករាយច្រើន ( សប្បាយច្រើន)

ង- **អសឋតា** មិនអួតអាង

ច- **អមាយាវិតា** មិនលាក់ទោសកំហុសរបស់ខ្លួន

ឆ- **បសាទោ** ជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា (ក្នុងទីដែលគេយល់ថា ប្រសើរខ្ពង់ខ្ពស់សម្រាប់រូបគេ)។

**មនុស្សពុទ្ធិចរិត មានធម៌ ៧ ប្រការ គឺ :**

ក- **សោវចស្សតា** ប្រដៅងាយ (មិនលំបាកអប់រំ)

ខ- **កល្យាណមិត្តតា** មានមិត្តល្អ (សេពគប់មិត្តល្អ)

គ- **ភោជនេ មត្តញ្ញុតា** ដឹងប្រមាណក្នុងភោជន (ដឹងប្រមាណក្នុងការបរិភោគរឺប្រើប្រាស់)

ឃ- **សតិសម្បជញ្ញំ** រលឹកដឹងខ្លួនជានិច្ច

ង- **ជាគរិតានុយោគោ** ប្រកបក្នុងការភ្ញាក់រលឹក

ច- **សំវេគោ** សង្វេគក្នុងទីគួរសង្វេគ

ឆ- **សមាវិត្តស្ស យោនិសោ បធានំ** តំកល់ធម៌ដែលខ្លួនសង្វេគដោយឧបាយនៃប្រាជ្ញា។

**មនុស្សវិតក្កចរិត តែងមានធម៌៧ យ៉ាងគឺ :**

ក- **ភស្សពហុលតា** ច្រើននិយាយតិរច្ឆានកថា (ពាក្យឥតប្រយោជន៍)

ខ- **គណារាមតា** ត្រេកអរក្នុងពួក ( ហ្វូង ក្រុម គណៈ )

គ- **អរតិ** មិនសូវត្រេកអរ ឬ មិនសូវអើពើ នឹងការធ្វើបុណ្យកុសល រឺ សេចក្តីល្អផ្សេងៗ

ឃ- **អនវដ្ឋិតកិច្ចតា** ប្រកបការមិនចេះឈប់ ( ពូកែធ្វើការ )

ង- **រតិជមាយនា** វេលាយប់គិតដល់ការងារដែលត្រូវធ្វើនូវពេលថ្ងៃ

ច- **ទិវាបជ្ជលនា** ពេលថ្ងៃប្រកបការងារ តាមគំនិតដែលខ្លួនគិតទុក

ឆ- **ហុរាហុរំ ធាវនា** មានអារម្មណ៍ស្ទុះទៅកាន់ទីផ្សេងៗ ( គឺ អន្ទះអន្ទែង មានចិត្តរវើរវាយ មិននឹងនរ ) ។

ខាងលើនេះប្អូនបានឃើញចរិត៦យ៉ាងរបស់មនុស្ស ក៏ប៉ុន្តែចរិតមនុស្សមិនមែនមានត្រឹមតែប៉ុណ្ណឹងទេគឺនៅមានតទៅទៀត ដោយអំណាចនៃការ



លាយគ្នា របស់ចរិតនោះៗ ។ នៅក្នុងមហាដីកា ឈ្មោះ បរមត្ថមញ្ជូសា លោកបាន សម្តែងថា មានរហូត ដល់ ៦១ ឯណោះ ដោយអំណាចនៃការរួមបញ្ចូលគ្នារបស់ចរិតនីមួយៗ ។ ដែលថាមាន ៦ នេះ ព្រោះពោលដោយសង្ខេបប៉ុណ្ណោះ ប្រៀបដូចជាពណ៌ ដែលមាននៅលើលោកយើងនេះ កាលដែលពោលដោយខ្លី គឺ ពណ៌មានត្រឹមតែ៧ពណ៌តែប៉ុណ្ណោះ គឺពណ៌ខៀវ ក្រហម លឿង ។ល។ តែដល់ពេលយើងយកមកលាយបញ្ចូលគ្នា ពណ៌ជាច្រើន និងកើតឡើងទៀត ដូចជាយើងយកពណ៌ខៀវលាយជាមួយនិងពណ៌ក្រហម វាទៅជាផ្សេងពីពណ៌ខៀវ ហើយក៏ផ្សេងពីពណ៌ក្រហមដែរ តែវាបានពណ៌ថ្មីមួយទៀត។ បើយើងដាក់ពណ៌ណាច្រើនជាង វាកាត់ទៅរកពណ៌នោះច្រើនជាងគេ។ ហេតុនេះហើយបានជាក្នុងកុំព្យូទ័រ គេរកឃើញពណ៌រាប់រយពណ៌ ដោយសារការលាយ រវាងពណ៌និងពណ៌នេះឯង។ ដូចនេះចរិតទាំង៦ ដែលបានលើកមកនេះ គឺជាចរិតដើម ហើយវាមាននៅខាងក្នុងនៃមនុស្សគ្រប់រូប បើមនុស្សណាមានចរិតណាច្រើនជាងគេ ចរិតនេះនិងលេចមុខខ្លាំងជាងគេ ហើយក៏សន្មតមនុស្សនោះថា ជាចរិតនោះៗទៅ។

នៅក្នុងពេលដែលពិនិត្យវិនិច្ឆ័យទៅលើលក្ខណៈរបស់មិត្ត ឬវត្ថុអ្វីផ្សេងៗទៀតក្តី ប្អូនត្រូវដកនូវអគតិទាំងបួនចេញ គឺ:



១-**ឆន្ទាគតិ** លំអៀងព្រោះស្រឡាញ់

២-**ទោសាគតិ** លំអៀងព្រោះស្អប់

៣-**មោហាគតិ** លំអៀងព្រោះល្ងង់

៤-**ភយាគតិ** លំអៀងព្រោះខ្លាច

ការដែលពិនិត្យវិនិច្ឆ័យឃ្លៀងឃ្លាតពីការពិត មិនត្រឹមត្រូវទៅតាមសច្ចភាព ហៅថាអគតិ ។ កាលបើយើងស្រឡាញ់ ចិត្តរបស់យើងរមែងទន់ទោរទៅរកសេចក្តីល្អ និង លើកលែងទោស ឬលាក់ទុកសេចក្តីអាក្រក់នៅក្នុងចិត្ត ។ បើមានការខឹងខ្ញាញ់ ក្នុងចិត្តរបស់យើងតែងតែបំពេញ ឬពង្រីកនូវសេចក្តីអាក្រក់របស់អ្នកនោះ ឱ្យលុបបាត់អស់នូវសេចក្តីល្អ ឬគុណដែលគេមាន ។ បើល្ងង់នៅក្នុងចិត្តវិញ តែងបង្កាច់បង្ខូច នូវសកម្មភាពដែលល្អ ថាអាក្រក់ សកម្មភាពអាក្រក់ថាល្អ ព្រោះមោហៈមិនដឹងការពិត ។

ដូច្នេះអគតិទាំងបួននេះ កាលណាវាមានចំពោះប្អូន ក្នុងពេលកំពុងវិនិច្ឆ័យឬវិភាគពិចារណា មិនអាចឈានចេញទៅរកការពិតបានឡើយ ។ ប្អូនត្រូវចាំថា អគតិទាំងបួននេះ ប្រៀបដូចជាវ៉ែនតាពណ៌

កាលណាពាក់ទៅ មិនអាចឃើញធម្មជាតិទៅតាមសេចក្តីពិតបានឡើយ គឺវាតែងតែកែទៅតាមពណ៌របស់កញ្ចក់វ៉ែនតានោះ ។

កាលដែលប្អូនៗ បានសិក្សាអំពី ពាល បណ្ឌិត មិត្ត និង ចរិត រួចមក ប្អូនអាចវិនិច្ឆ័យនិងស្វែងយល់បានដោយខ្លួនឯង ថាអ្នកណាខ្លះជាមិត្តពិត អ្នកណាខ្លះដែលគួរនៅជិត និងធ្វើសកម្មភាពជាមួយ ហើយមិនត្រឹមតែប៉ុណ្ណោះ គឺប្អូនអាចដឹងបានថា ខ្លួនឯងនេះជាមនុស្សប្រភេទណាទៀតផង ។ តែបងសូមផ្តាំថា មនុស្សយើងមួយចំនួន ដែលបានសិក្សារៀនសូត្រ មុខវិជ្ជាផ្នែកបច្ចេកទេសជាច្រើនដែលពូកែ តែមិនបានអប់រំចិត្ត ក៏យកនូវចំណេះដឹងដែលខ្លួនបានចេះនោះ ទៅបង្អួតបង្អរ មើលស្រាលដល់អ្នកដែលគ្នាមិនចេះដូចខ្លួន ហើយមិនសូវស្តាប់យោបល់ ឬពាក្យពេចន៍របស់អ្នកដទៃទេ ព្រោះគិតថាគេមិនដល់អញ ។ ចំណុចទាំងអស់នេះហៅថា ( មានះ) ប្អូនត្រូវតាំងចិត្តឱ្យបានថា ដាច់ខាតមិនឱ្យ( មានះ )មាននៅក្នុងចិត្តរបស់ប្អូនឡើយ ។

ពាក្យថា ( មានះ) ប្រែថា ការប្រកាន់ខ្លួន , ការរឹងរូស , ការប្រព្រឹត្តិចចេស , ការឆ្មើងឆ្មៃ , ការប្រកាន់ឬក ក្រអើតក្រទម ។ សេចក្តីប្រកាន់ខ្លួនថា ជាអ្នកលើសគេ ជាអ្នកស្មើនឹងគេ ថាជាអ្នកថោកទាបជាងគេនោះ កំណត់ដោយ ជាតិ ត្រកូល រូបសម្បត្តិ ទ្រព្យសិល្បវិទ្យា ជាដើម ។ មានះ

នេះ រាប់បានថាជាគ្រឿងពុលមួយ ដែលធ្វើឱ្យចិត្តវង្វេងមិនស្គាល់គ្នានិងគ្នា ជាហេតុធ្វើឱ្យបែកបាក់សាមគ្គី របស់ជនរួមជាតិក្តី ជនបរទេសក្តី ជាពិសេស ប្រព្រឹត្តទៅដើម្បីបង្ខូចនូវប្រយោជន៍ របស់ជាតិសាសនាបាន ដោយពិត ។



អស្មិមានៈ ៩ យ៉ាង

១- អ្នកប្រសើរជាងគេ ប្រកាន់ថា អញប្រសើរជាងគេ ។

២- អ្នកប្រសើរជាងគេ ប្រកាន់ថា អញស្មើនឹងគេ ។

៣- អ្នកប្រសើរជាងគេ ប្រកាន់ថា អញអន់ថយជាងគេ ។

៤- អ្នកស្មើនឹងគេ ប្រកាន់ថា អញប្រសើរជាងគេ ។

៥- អ្នកស្មើនឹងគេ ប្រកាន់ថា អញស្មើនឹងគេ ។

៦- អ្នកស្មើនឹងគេ ប្រកាន់ថា អញអន់ថយជាងគេ ។

៧- អ្នកអន់ថយជាងគេ ប្រកាន់ថា អញប្រសើរជាងគេ ។

៨- អ្នកអន់ថយជាងគេ ប្រកាន់ថា អញស្មើនឹងគេ ។

៩- អ្នកអន់ថយជាងគេ ប្រកាន់ថា អញអន់ថយជាងគេ។

**ក្រុមមានះ បើចែកជាក្រុមមាន ៣ គឺ:**

☞ **១- ក្រុមប្រសើរ**

ប្រសើរ
ស្មើ
អន់ថយ
} អញហ្នឹងប្រសើរជាងគេ ត្រូវតែស្តាប់អញ ធ្វើតាមអញ ពួកឯងទៅមិនរួចទេ មានតែយើងទេទើបអាច។



*"ដកនិងដាក់ធ្មេញដោយខ្លួនឯង"*

*សូមប្អូនជួយគិតទៅមើល ថាតើរូបគាត់ម្នាក់នេះ ពេលដែលគាត់ស្លាប់ទៅ គាត់ដើរទៅចូលរណ្តៅខ្លួនឯង ឬក៏ត្រូវការគេសែងដែរ?*

☞ ២- ក្រុមស្មើ

ប្រសើរ
ស្មើ } អញក៏មិនអន់ប៉ុន្មានដែរ កុំខ្លាំងតែឯងពេក
អន់ថយ កុំភ្លេច ថាកន្លែងនេះក៏មានអញដែរ ។

*"រកឈ្នះចាញ់*
*រៀងខ្លួន"*



*តើការប្រើប្រាស់វិធីបែបនេះ អាចដោះស្រាយបញ្ហាបាន ទេ ? តើសន្តិភាពកើតចេញ មកពីអ្វី ? ពេលដែលបាន ឃើញមនុស្សទាំងនោះ ធ្វើ បែបនេះ តើប្អូនគិតថាគេ*

**ខុសពីរ គឺមិនអាចធ្វើឱ្យមួយត្រូវទេ**

*ជាមនុស្សដូចម្តេច ? ចុះសម្រាប់រូបប្អូនវិញ តើមានវិធីសាស្ត្រអ្វីខ្លះដើម្បី ដោះស្រាយបញ្ហាបែបនេះ ?*

### ៣- ក្រុមអន់

ប្រសើរ
ស្មើ
អន់ថយ

ខ្ញុំហ្នឹងវាអន់ថយហើយ ខ្លាំងតែឯងទៅ ស្ដាប់មិនយល់ទេ ធ្វើមិនកើតទេ គ្មានផ្លូវទេ ពីព្រោះខ្ញុំវាអន់ ទៅតែឯងទៅធ្វើតែឯងទៅ កុំគិតពីខ្ញុំៗគ្មានលទ្ធិភាពទេ ។

*"គំនិតអសកម្ម*
*រឺ គំនិតអវិជ្ជមាន*
*ទុទិដ្ឋិនិយម"*




*តើពាក្យថាមិនអាច វាជាការពិត ឬក៏គ្រាន់តែជាទស្សនៈទេ ? បើមិនមែនជាការពិតទេ ហេតុអ្វីបានជាអ្នកវិចស្ពាយវាតាមខ្លួនបែបនេះ ?ប្រសិនបើមនុស្សសម័យមុន ប្រកាន់គំនិតដូចជាអ្នក តើអាចកសាងប្រាសាទអង្គរវត្តបានទេ ? ប្រសិនបើអ្នកប្រាជ្ញ និងអ្នកវិទ្យាទាំងអស់ ប្រកាន់គំនិតដូចជាអ្នក តើអាចជោគជ័យទេសម្រាប់កិច្ចការរបស់ពួកគេ ?*

ក្រុមអ្នកប្រសើរ ចាត់ចូលលក្ខណៈនៃមនុស្សទ្រនង់ មានភាពរឹងថ្លឹង គឺជាមនុស្សដណ្ដើមល្អ ដណ្ដើមថាខ្លួនប្រសើរជាងគេ ។ មានៈ ក្រុមនេះ ច្រើនកើតឡើងចំពោះ ឥស្សរជននិងបព្វជិត ដោយហេតុថា បើមាន សេចក្ដីប្រកាន់រឹងត្អឹងបែបនេះ ជាហេតុរាំងមិនងាយនឹងជឿស្ដាប់អ្នក ណាឡើយ កាលពីបួសនៅត្រឹមឋានៈជាសាមណេរ ជាភិក្ខុថម្មតា អាចគង់ (អង្គុយ)ស្ដាប់ធម៌ទេសនារបស់សាមណេរតូចបាន តែដល់ពេលឡើង ឋានៈជាអ្នកដឹកនាំ ជាសង្ឃរាជ ជាមេគណ ស្ដាប់ធម៌ទេសនារបស់ សាមណេរតូចនេះមិនកើតទេ ពីព្រោះឯងធំទៅហើយ ចុកចង្កេះណាស់ អង្គុយមិនកើតទេ សុំទៅមុនហើយ ។

ក្រុមស្មើ ចាត់ចូលក្នុងលក្ខណៈនៃបុគ្គលជាមនុស្សប្រកាន់ឬក ស្មើនឹងគេ ដោយសេចក្ដីប្រកាន់ថា ខ្លួនប្រសើរជាងគេពិតមែន ប៉ុន្តែដាក់ ខ្លួនថាអញហ្នឹងក៏ដូចគេដែរ ទោះបីខ្លួនថោកទាបជាងគេ ក៏ប្រកាន់ស្មើ នឹងគេ ។ មានៈ ក្រុមនេះក៏ច្រើនកើតមាន ចំពោះឥស្សរជនដែរ ។ មានៈ នេះ ក៏នាំឱ្យមិនជឿស្ដាប់ក្នុងសំណាក់ នៃលោកអ្នកចេះដឹងដែរ ។

ក្រុមអន់ចាត់ចូលក្នុងលក្ខណៈនៃបុគ្គលជាអ្នកបន្ថោកខ្លួនឯង ។ សេចក្ដីប្រកាន់ដោយការដាក់បន្ទាប់ខ្លួនហួសហេតុពេក ដោយខុសច្បាប់ សីលធម៌ សម្រាប់ឋានៈរបស់មនុស្សនេះ បើយើងគិតដោយសេរី១ ហាក់

ដូចជាពុំគួរចាត់ទុកថាជាមានៈ ជាសេចក្ដីប្រកាន់ខុសគេ ប៉ុន្តែតាមពិតការប្រកាន់ដូច្នេះ ក៏នាំឱ្យខូចប្រយោជន៍របស់ខ្លួនជាប្រាកដ ព្រោះថាមានៈប្រភេទនេះ កាលបើមានកម្លាំងបរិបូណ៌ក្នុងសន្ដានបុគ្គលណា អាចញុំាងបុគ្គលនោះមិនឱ្យចូលទៅជិតកាន់សំណាក់លោកអ្នកប្រាជ្ញ ដើម្បីនឹងទទួលការស្ដាប់នូវពាក្យពេចន៍ល្អៗ រឺ ច្បាប់ទម្លាប់ណាមួយបានទេ ដោយហេតុតែសេចក្ដីប្រកាន់ថាខ្លួនអញ ជាមនុស្សថោកទាបដោយជាតិក្ដី ដោយស័ក្តិក្ដី ឬទ្រព្យសម្បត្តិក្ដី ថោកក៏ថោកទៅចុះ ធ្វើម៉េចខ្លួនឯងបានជាថោកទៅហើយ មិនខ្ចីចូលទៅជិតលុតក្រាបស្ដាប់បង្គាប់ចុះចូលនឹងអ្នកណាមួយទេ។ ដំណើរនៃសេចក្ដីប្រកាន់នេះ ឃើញថាជាទោស ជាសេចក្ដីប្រកាន់ខុសគួរចាត់ចូលក្នុងលក្ខណៈនៃមានៈបានដោយពិត។

មានៈទាំង៩នេះ ចាត់ជា **បហាតព្វធម៌** គឺធម៌ដែលត្រូវលះបង់ចោល ព្រោះវាគ្មានសារៈអ្វីសម្រាប់រូបប្អូនឡើយ វាមានតែការបាត់បង់តែប៉ុណ្ណោះ ហើយថែមទាំងធ្វើឱ្យជីវិតគ្មានតម្លៃទៀតផង ។ គុណតម្លៃរបស់មនុស្សគឺស្ថិតនៅលើគុណធម៌ ហើយបុគ្គលដែលមានគុណធម៌ទាបឬខ្ពស់ មិនមែនស្ថិតនៅលើចំណេះដឹង តំណែង ឋានៈ ទ្រព្យសម្បត្តិ ជាអ្នកនៅវត្ត ឬជាអ្នកនៅកន្លែងដែលបដិបត្តិធម៌នោះទេ ។ បុគ្គលដែលមានគុណធម៌ខ្ពស់ គឺជាបុគ្គលដែលមាននូវ **ហិរិ** និង **ឱត្តប្បៈ ។ ហិរិ** ប្រែថាខ្មាសសេចក្ដី

អាក្រក់ **ឱតប្បៈ** ប្រែថា ខ្លាចសេចក្ដីអាក្រក់ អំពើអាក្រក់ ។ ថ្វីត្បិតតែអ្នកនោះ មានការចេះដឹងពិតមែន តែបើនៅតែមិនខ្លាចញញើតនូវអំពើអាក្រក់ទេ មិនឱ្យឈ្មោះថាអ្នកមានគុណតម្លៃនោះឡើយ ព្រោះតម្លៃរបស់មនុស្សវាស់ដោយការងារ ទង្វើឬសកម្មភាព របស់បុគ្គលនោះ ។

មនុស្សបុថុជ្ជន កាលបើមានការចេះដឹងច្រើន តែមិនបានអប់រំចិត្ត គឺនឹងទៅជាមនុស្សគ្មានតម្លៃ ហើយអ្នកទាំងអស់នោះ ធ្វើយ៉ាងនេះទៅកើតនោះ ព្រោះមិនស្គាល់ធម៌ដែលពួកសប្បុរស តែងតែប្រព្រឹត្ត គឺសប្បុរសធម៌។ ដូចនេះប្អូនត្រូវស្គាល់ អំពីសប្បុរសធម៌ ហើយយកមកបដិបត្តិឱ្យបាន ទើបជាការល្អប្រសើរ ។

## ធម៌របស់សប្បុរសមាន ៧ យ៉ាង

**១-ធម្មញ្ញូតា** ជាអ្នកស្គាល់ហេតុ ហេតុនៃសេចក្ដីសុខ ហេតុនៃសេចក្ដីវិនាស តែធ្វើល្អគឺសុខ បើធ្វើអាក្រក់ ខាតប្រយោជន៍ បាននូវសេចក្ដីវិនាស ។ តែស្រវឹងទៅ គឺមានបញ្ហា។ ឱ្យតែប្រហែស គឺគ្រោះថ្នាក់ ។ឱ្យតែខ្ជិល គឺក្រហើយ ល្ងង់ហើយ ។

➪ ២-**អត្តញ្ញុតា** ជាអ្នកស្គាល់ផល ដូចជាស្គាល់ថា សេចក្ដីសុខជាផលកើតអំពីហេតុនេះៗ (បានដល់សេចក្ដីល្អ) ទុក្ខជាផលកើតអំពីហេតុនោះៗ (បានដល់សេចក្ដីអាក្រក់) ដូចជាដឹងថា "ចេះមកពីរៀន មានមកពីរក" ជាដើម ។

➪ ៣- **អត្តញ្ញុតា** ជាអ្នកស្គាល់ខ្លួនឯង ថាយើងនេះ មានជាតិត្រកូល យសស័ក្តិ សម្បត្តិ បរិវារ ចំណេះដឹង និងគុណធម៌ដែលមានក្នុងខ្លួន






ត្រឹមនេះ ។ ហើយប្រព្រឹត្តខ្លួន ឱ្យសមគួរតាមឋានៈ (មិនមែនធ្វើជាប្រធានធំ ហើយទៅលេងបាញ់ឃ្លីជាមួយនឹងក្មេងអ្នកស្រុកនោះទេ ឬក៏ខ្លួនមានលុយ២០០រៀល ហើយចង់ទៅញ៉ាំគុយទាវមួយចានថ្លៃ ៦០០០ រៀលនោះទេ) ។

➪ ៤-**មត្តញ្ញុតា** ជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរក ដោយផ្លូវប្រពៃ ព្រមទាំងស្គាល់ប្រមាណក្នុងការបរិភោគ ។ អ្នកខ្លះ ហេតុតែចង់បានប្រាក់ខែ១០០$ ក៏ខំធ្វើការថែមម៉ោង ទាំងថ្ងៃទាំងយប់ មិនគិតពីសុខភាព ដល់ពេលព្រឹកឡើងចេញដើរទៅទាំងងោកងក់ ស្រវាំងភ្នែក

ធ្លាក់ចូលក្នុងលូទឹកស្អុយក៏មាន។ បែបនេះមិនគួរធ្វើទេ ត្រូវចេះប្រមាណផង ឬក៏ពុំនោះទេ ក្នុងមួយថ្ងៃរកបាន៤០០០រៀលចាយអស់ ៦០០០រៀល ជំពាក់គេ២០០០រៀល ក៏មិនគួរដែរ។

➡ **៥-កាលញ្ញូតា** ជាអ្នកស្គាល់កាលវេលា ដែលសមគួរនឹងធ្វើកិច្ចការនោះៗ (មិនមែនពេលយប់ម៉ោង១២ គេគេងស្ងាត់ស្រុកអស់ យើងឯណោះបើកម៉ាញ៉េ សម្លេងឮចង់ធ្លាយជញ្ជាំងផ្ទះនោះទេ ឬ ពេលគេសម្រាកសម្រាន្តយើងធ្វើការ ពេលគេធ្វើការយើងទៅសម្រាកនោះ ក៏មិនកើតដែរ ព្រោះវាអាចមានបញ្ហា) ។

➡ **៦-បរិសញ្ញូតា** ជាអ្នកស្គាល់ប្រជុំជន និងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះៗ ។ ទៅចូលរួមពិធីញ៉ាំការគេ គ្រប់គ្នាសុទ្ធតែស្លៀកពាក់ស្អាតបាតសមរម្យ ចំណែកយើងវិញ ស្លៀកក្រម៉ា ពាក់អាវយឺតវាលក្លៀកពណ៌ស ទើបនឹងមកពីភ្ជួរ មិនទាន់ងូតទឹកអត់ស្បែកជើង ហើយទៅញ៉ាំការនឹងគេដែរ ក្បួនហ្នឹងក៏មិនត្រឹមត្រូវដែរ ។

➡ **៧-បុគ្គលបរោបរញ្ញូតា** ជាអ្នកស្គាល់បុគ្គល ថា អ្នកនេះជាមនុស្សល្អ គួរសេពគប់ អ្នកនេះជាមនុស្សមិនល្អ មិនគួរសេពគប់ ។ គេមិនចូលចិត្តរឿងហ្នឹងហើយ នៅតែនិយាយដដែលៗ ប្រាកដជាត្រូវ

ខៀវភ្លែកហើយឱ្យតែយ៉ាងហ្នឹង ឬ ចង់បង្អាត់ពន្យល់ដល់គ្នាអ្នកមិនចេះអក្សរហើយបញ្ញាតិច ប្រើសុទ្ធតែ *English language* ភាសាអង់គ្លេស ឬ ពាក្យបច្ចេកទេសដែលមានន័យជ្រៅៗ លទ្ធផល គ្នាមិនយល់ មិនចង់ទៅជិតតែម្តង បែបនេះក៏ខុស *standard* ដែរ ព្រោះវាខុសតម្រូវការ ឬចំណង់ណ្ហូលចិត្តរបស់អ្នកទទួលយក ។

## សប្បុរសធម៌ ៧ យ៉ាងទៀត

១-មានសទ្ធា មានសេចក្តីខ្មាសបាប ខ្លាចបាប ជាអ្នកបានឮបានស្តាប់ច្រើន ជាអ្នកមានសេចក្តីព្យាយាម ជាអ្នកមានសេចក្តីខ្ជាប់ខ្ជួនជាអ្នកមានបញ្ញា ។

២-ប្រឹក្សាអ្វីជាមួយអ្នកណា ក៏មិនប្រឹក្សាដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃ ។

៣-គិតអ្វី ក៏មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នដទៃ ។

៤-ពោលអ្វី ក៏មិនពោលដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃ ។

៥-មានសេចក្តីយល់ឃើញប្រពៃ យល់ឃើញថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ។

៧-ឱ្យទានដោយគោរព គឺអើពើនឹងរបស់ដែលខ្លួនឱ្យ អើពើដល់អ្នកដែលទទួលទាន មិនធ្វើអាការៈដូចជាបោះចោល ។ (មិនមែនអ្នកសុំទានគ្នាសុំ២០០រៀល មុននឹងឱ្យដេរសិន ទើបយកលុយចេញពីហោប៉ៅហើយញីឡើងទក់ រួចគប់ចំកណ្ដាលមុខគ្នានោះទេ គឺត្រូវឱ្យដោយទឹកចិត្តមេត្តា ។

កាលដែលរៀបរាប់មកទាំងប៉ុន្មាននេះ ប្អូន១ប្រហែលបានយល់ច្រើន អំពីរឿងជ្រើសរើសមនុស្សមកធ្វើជាមិត្តនោះ ពីព្រោះប្អូនបានស្គាល់អំពីលក្ខណៈរបស់បុគ្គលនោះ១ តែបងគ្រាន់តែបញ្ជាក់ជាចុងក្រោយថា បើប្អូនមានចរិតឬកពាំបែបណា នោះប្អូននឹងជ្រើសរើសបាននូវមនុស្សដែលមានចរិតឬកពាំបែបនោះមកធ្វើជាមិត្តដែរ។ ព្រោះថា នូវរាល់អង្គធាតុទាំងអស់ ដែលនៅលើលោកយើងនេះ សុទ្ធតែមានធាតុរបស់វា ហើយធាតុនោះវានឹងរត់ទៅរកគ្នា កាលណាវានៅជិតគ្នា ដូចជាមេដែកនិងដែក ទោះបីគេយកកំណាត់ដែកតូច១ទៅទំលាក់នឹងគំនរគ្រួសឬខ្សាច់ ពេលដែលគេដាក់មេដែកចុះទៅ មេដែកឆក់យកតែកំណាត់ដែកតូច១តែប៉ុណ្ណោះ មិនឆក់យកគ្រាប់គ្រួសឬខ្សាច់ឡើយ ព្រោះគ្រាប់គ្រួសឬខ្សាច់ មិនមែនជាធាតុដែលត្រូវគ្នា នឹង មេដែកនោះ។ ឯមនុស្សយើងវិញ ក៏មានធាតុដែរ ហើយក៏កាត់ទៅរកគ្នានិងគ្នាយ៉ាងនោះដែរ គឺធាតុ

អ្នកផឹកតែ ស្កាត់ទៅរកអ្នកផឹកតែ ធាតុអ្នកផឹកស្រា ស្កាត់ទៅរកធាតុអ្នកផឹកស្រា។ អ្នកផឹកតែនិងអ្នកផឹកស្រាមិនអាចស្កាត់រកគ្នានិងគ្នាបានទេ។ បើតែនិងតែ ស្រានិងស្រា ទើបបានអាច។

ដូចនេះ ប្អូនត្រូវហាត់ធ្វើនូវសេចក្ដីល្អ ដោយផ្ដើមចេញពីខ្លួនប្អូនមុនគេ ហើយត្រូវដឹងថា ការដែលអប់រំចិត្តឱ្យស្ថិតនៅក្នុងសេចក្ដីល្អ វាជារឿងដែលសំខាន់ជាងគេ ព្រោះគុណតម្លៃរបស់មនុស្ស វាស្ថិតនៅលើទង្វើ គឺការធ្វើរបស់មនុស្ស។ បងក៏មិនចង់និយាយអ្វីច្រើនទៀតទេក្នុងរឿងមិត្តនេះនោះ គឺ នឹងបញ្ចប់វាត្រឹមហ្នឹងសិន។

**(ខួរក្បាលដែលប្រើការបានល្អ គឺជាខួរក្បាលដែលបានឆ្លងកាត់នូវការអប់រំ)**



ឥឡូវនេះ បងនឹងប្រាប់ប្អូនខ្លះៗ អំពីចំណុចដែលត្រូវអនុវត្ត ប្រចាំថ្ងៃក្នុងជីវិត។ ជីវិតដែលយើងមានក្នុងពេលបច្ចុប្បន្ននេះ ជារឿងមួយដ៏សំខាន់បំផុតសំរាប់យើង ព្រោះអ្វីដែលជីវិតទទួលបានក្នុងពេលនេះ ក៏ដោយអាស្រ័យអំពើអ្វីមួយដែលយើងបានធ្វើពីមុនមក ហើយអ្វីដែលត្រូវកែប្រែបាន ក៏មានតែក្នុងពេលនេះដែរ ព្រោះពេលនេះវាជាផលរបស់អតីត ហើយក៏ជាហេតុទៅពេលអនាគតដែរ ។ គុណភាពនៃការគិតរបស់បុគ្គលណា វាជាជោគវាសនារបស់បុគ្គលនោះ យើងគឺជាផលនៃការគិត បើយើងគិតយ៉ាងណា ការធ្វើក៏យ៉ាងនោះ ហើយអ្វីដែលយើងត្រូវទទួលបាន ក៏យ៉ាងនោះដែរ។



*សេចក្តីល្អជាលម្អនៃជីវិត*

## អ្វីៗទាំងអស់កើតព្រោះគំនិត

សម័យឥឡូវវិទ្យាសាស្ត្រ លូតលាស់ខ្លាំងណាស់ក្នុងសកល
គេខំស្រាវជ្រាវរកហេតុផល ឱ្យបានដឹងយល់ធ្វើកើតបាន ។
មានទាំងរោងចក្រសហគ្រាស ច្រើនមីរដេដាសគ្រប់ទីស្ថាន
ផលិតយន្តហោះកប៉ាល់ឡាន គ្រឿងប្រើប្រាស់មានគ្រប់ទាំងអស់ ។
ឈានដល់សម័យកុំព្យូទ័រ ទូរស័ព្ទទូរសារគ្មានចន្លោះ
ម៉ាញ៉េស៊ីតុឌីនិងទូរទស្សន៍ វីស៊ីឌីនោះឃើញរូបបាន ។
មានយានអាវកាសលឿនអនេក ហោះហើរពុះជ្រែកដល់ទីស្ថាន
ព្រះច័ន្ទអង្គារឃើញដឹងបាន ស្រាវជ្រាវទីស្ថានភពទាំងនោះ ។
អ្វីៗកើតឡើងព្រោះគំនិត ចេះគួរចេះគិតធ្វើទាំងអស់
គឺវាកើតឡើងដោយសារមនុស្ស គិតគូរទាំងអស់ធ្វើកើតបាន ។
សរុបពាក្យនេះឱ្យនៅខ្លី គឺមានអត្ថន័យឱ្យខំរៀន
អ្វីៗដែលមនុស្សអាចធ្វើបាន អ្វីៗកើតមានព្រោះគំនិត ។

(ដោយ ឡុង ចំរើន)

ការគិត → សកម្មភាព → លទ្ធផល



សេចក្តីល្អជាលម្អនៃជីវិត

គំនិតបីដូចជាគ្រាប់ពូជដែលរង់ចាំការបណ្ដុះ តែបើជាមនុស្សស្អុះ (SOS)[១] មិនអាចបណ្ដុះកើត ។



១ SOS គឺជាមនុស្សដែលបរាជ័យ មនុស្សដែលមានគំនិតអវិជ្ជមាន មានទស្សនៈជាទុទិដ្ឋិនិយម ជាមនុស្សដែលយកតែបញ្ហាមកដាក់ពីមុខ ជាមនុស្សដែលខ្វះគំនិតច្នៃប្រឌិត ជាមនុស្សដែលឆាប់រាថយជាមួយនឹងបញ្ហា ពេលធ្វើអ្វីមួយតែងមានអារម្មណ៍ថា លំបាកធ្វើមិនកើត ជាមនុស្សដែលខ្វះការជឿជាក់លើខ្លួនឯង តែងចាត់ទុកខ្លួនឯងថា ជាមនុស្សមិនបានការ ជាមនុស្សដែលឆាប់បាក់ទឹកចិត្ត និងមានភាពអស់សង្ឃឹមក្នុងជីវិត ។

## ☠ ការគិតតែពីខ្លួនឯង

មនុស្សយើងភាគច្រើន មិនសូវបានគិតពីអ្នកដទៃទេ គិតតែពីប្រយោជន៍ខ្លួនឯងជាធំ ឱ្យតែយើងគ្រប់គ្រាន់ទៅ អ្នកដទៃទោះយ៉ាងម៉េចក៏យ៉ាងនោះទៅ រួចហើយក៏បន្តធ្វើនូវការងាររបស់គេរៀង១ខ្លួន ដោយមិនគិតអំពីផលប៉ះពាល់ជារួម ហើយទីបំផុត ខ្លួនគេក៏ទទួលចំណែកក្នុងការប៉ះពាល់នោះដែរ ដោយមិនដឹងថាជាផលនៃអំពើរបស់ខ្លួនទៀត ។ ដើម្បីឱ្យយល់ត្រង់ចំណុចនេះ ចូរប្អូន១ពិចារណានូវរឿងមួយជាមួយនឹងបងសិន ។

ពូ (ក) គាត់ជាអ្នកដាំបន្លែលក់ ហើយគាត់គិតថា ដើម្បីឱ្យបន្លែនេះល្អនិងលូតលាស់ឆាប់នោះ គាត់ត្រូវដាក់ថ្នាំគីមី ចំពោះបន្លែដែលត្រូវលក់ តែអាមួយចំណែកតូចនេះ មិនប្រើគីមីទេ ព្រោះទុកបរិភោគខ្លួនឯងខ្លាចខូចសុខភាព ។

មីង (ខ) ជាអ្នកធ្វើប្រហុកលក់ ។ដើម្បីឱ្យប្រហុកគាត់ទុកបានយូរ ហើយរុយមិនរោម គាត់ត្រូវប្រើថ្នាំគីមី សម្រាប់ប្រហុកដែលត្រូវលក់ តែប្រហុកដែលទុកហូបខ្លួនឯង គាត់មិនដាក់ទេ ព្រោះខ្លាចខូចសុខភាព ។

ពូ (គ) គាត់ជាអ្នកលក់ផ្លែឈើ គាត់គិតថា ដើម្បីឱ្យផ្លែឈើគាត់ស្រស់បានយូរ គាត់ដាក់ថ្នាំគីមី នេះសម្រាប់អាផ្នែកណាដែល

ត្រូវលក់។ តែអាផ្លែកណាដែលគាត់ទុកបរិភោគខ្លួនឯង គាត់មិនដាក់ទេ ព្រោះខ្លាច ខូចសុខភាព ។

មីង (ឃ) គាត់ជាអ្នកលក់បន្លែកគូរ គាត់គិតថា បន្លែតែចិតទុកយូរទៅវាខ្មៅហើយមិនសូវមានអ្នកទិញទៀត ដូច្នេះ ខ្ញុំត្រូវដាក់ថ្នាំគីមីទើបវាស្រស់ហើយទុកបានយូរ តែបើអាចំណែកដែលទុកហូបខ្លួនឯង មិនបាច់ដាក់ទេ ខ្មៅក៏ខ្មៅទៅមិនអីទេ ព្រោះខ្លាចខូចសុខភាព ។

ឥឡូវបងសូមសួរប្អូនៗថា របស់របរដែលពួកគាត់ត្រូវយកទៅលក់នោះ តើគាត់ទៅលក់នៅកន្លែងណា លក់ក្នុងព្រៃស្ងាត់ ឬទីផ្សាររបស់មនុស្ស ?

បើលក់ក្នុងទីផ្សារ ប្រាកដជាមានមនុស្សជាអ្នកទិញ ហើយក្នុងចំណោមមនុស្សអ្នកទិញនោះ តើមានពួកគាត់ទាំងបួននាក់នេះដែរឬអត់? គឺប្រាកដជាមាន ។

ពូ (ក) គាត់មានបន្លែ តែដល់ពេលស្ល គាត់ត្រូវការប្រហុក ដូច្នេះ គាត់ត្រូវតែទិញប្រហុក ហើយប្រហុកនោះ ជាប្រហុកដែលមានជាតិគីមី ។ មីង (ខ) មានប្រហុក តែខ្វះបន្លែស្ល ដូច្នេះគាត់ត្រូវតែទិញបន្លែដើម្បីស្ល បន្លែក៏មានជាតិគីមី ។ ពូ (គ) ជាអ្នកលក់ផ្លែឈើ ហើយអ្នកលក់ផ្លែឈើ ក៏ត្រូវការទទួលទានបាយ តែកាលណាទទួលទានបាយ

ប្រាកដជាត្រូវការសម្លរ ដូច្នេះ គាត់ត្រូវតែទិញសម្លរ ហើយសម្លរជាសម្លរ ដែលមានជាតិគីមី ព្រោះដាក់បន្លែនិងប្រហុកដែលមានជាតិគីមី ។

អ្នកលក់បន្លែ អ្នកលក់ប្រហុក និង អ្នកលក់បន្លែកក្ងូរ ក្រោយពេល បរិភោគបាយហើយ ត្រូវការបរិភោគបង្អែម ឬ ផ្លែឈើ ហើយផ្លែឈើជា ផ្លែឈើដែលមានជាតិគីមី ។

ឥឡូវនេះ ចូរប្អូនពិនិត្យមើល តើអ្នកណាខ្លះជាអ្នកបរិភោគនូវ រាល់របស់របរទាំងនោះ ឃើញថាពួកគាត់ដដែល ហើយអ្នកឈឺឬស្លាប់ ក៏ពួកគាត់ដដែល ។ មិនត្រឹមតែពួកគាត់ទេ ដែលមានគ្រោះថ្នាក់ សូម្បី តែសត្វចិញ្ចឹម ឬ សត្វដទៃទៀតក៏ស្លាប់ដែរ ដូចជា ត្រី អណ្តើក និងសត្វផ្សេង១ជាច្រើនដែលរស់នៅលើដីនិងក្នុងទឹក ព្រោះវាបានស៊ីនូវ របស់ដែលសេសសល់ពីពួកគាត់ ឬ កាកសំណល់ដែលពួកគាត់បានយក ទៅចាក់ចោលនៅកន្លែងដែលពួកវារស់នៅ និយាយរួមគឺប៉ះពាល់ដល់ បរិស្ថាន ។

នេះហើយជាលទ្ធផលនៃការគិតតែពីខ្លួនឯង ដោយមិនបានគិតអំពីផលប៉ះ ពាល់រួម ទីបំផុត ឬ ចុងក្រោយគឺបែបនេះ។

មួយទៀត បុរសឈ្មោះ (ង) គាត់បរិភោគសុរាហើយបើកបរ ស្រាប់តែក្នុងពេលនោះមានបុរសម្នាក់ គាត់ប្រាប់ "បងប្រុស បើបងស្រ

រឹងបែបនេះ សូមកុំបើកបរអី ប្រយ័ត្នមានគ្រោះថ្នាក់"។ បុរស (ង)និយាយតបថា "ខ្ញុំផឹកលុយខ្ញុំ ខ្ញុំបើកបរ ក៏ជាយានជំនិះរបស់ខ្ញុំ បើគ្រោះថ្នាក់ ខ្ញុំក៏ជាអ្នកគ្រោះថ្នាក់ដែរ មិនមែនអ្នកឯងទេ ថយចេញទៅ កុំមកឃាត់ខ្ញុំ នេះជារឿងរបស់ខ្ញុំ បើស្លាប់ក៏ស្លាប់តែខ្ញុំដែរ"។

ចូរប្អូនស្មានទៅមើល! ថាយានជំនិះ ដែលគាត់ជិះនោះ តើជិះតាមណា ជិះលើចុងឈើ ឬលើផ្លូវជាតិ។ បើជិះលើចុងឈើ ជិះប្រហែស ធ្លាក់បាក់ក ស្លាប់តែឯង តែបើជិះលើផ្លូវជាតិវិញ យើងគិតទៅមើល! ថាផ្លូវជាតិ ក្នុងប្រទេសនីមួយៗ គេធ្វើសម្រាប់តែមនុស្សម្នាក់ជិះ ឬ សម្រាប់គ្រប់គ្នា ជិះផងដែរ ។ បើសម្រាប់គ្រប់គ្នាផងដែរ គ្រប់គ្នាប្រាកដជាប្រើផ្លូវនេះ ហើយមានច្រើនគ្នាទៀត។ ចុះបើបុរសនោះគាត់ជិះទៅបុកវិញ តើបុកអ្នក ណាខ្លះ គឺប្រាកដជាបុកមនុស្សឬយានជំនិះដូចគ្នា ហើយក្នុងយានជំនិះ នោះ អ្នកណាជាអ្នកបើកបរ ជាមនុស្ស ឬ ជាសត្វជ្រូក គឺប្រាកដ ជាមនុស្ស។ ចូរប្អូនៗ ស្តាប់រឿងបុរសនេះ បន្តទៀត ។ ក្រោយពេល និយាយចប់ ជាមួយនឹងបុរសនោះហើយ បុរស (ង)ក៏ឡើងម៉ូតូ២០០៩ យ៉ាងថ្មី ហើយចេញក្នុងល្បឿនយ៉ាងលឿនជាទីបំផុត ។ គាត់បើកបាន ប្រហែលជា២០នាទីក្រោយមក ក៏មកដល់ផ្លូវកែងមួយ ស្រាប់តែពេល នោះ មានក្មេងតូចៗពីរនាក់ ចេញពីសាលាហើយដើរកាត់ត្រង់ផ្លូវកែង

នោះដែរ ធ្វើឱ្យបុរសនោះបញ្ឈប់ម៉ូតូមិនទាន់ ក៏បុកក្មេងតូចពីរនាក់នោះស្លាប់មួយរំពេច ទាំងបុរសនោះក៏បានដួលទៅកណ្ដាលថ្នល់ បែកក្បាលហូរឈាមយ៉ាងច្រើន និងមានឈាមចេញតាមត្រចៀកទៀត។ ពេលនោះមានម៉ូតូមួយផ្សេងទៀត តាមពីក្រោយដោយគេចមិនទាន់ ក៏បើកទៅជាន់ម៉ូតូដែលដួលស្រាប់នោះ ដួលស្លាប់ម្នាក់១ទៀតសន្លប់នៅកណ្ដាលថ្នល់ ។ គាប់ជួនពេលនោះ ស្រាប់តែមានឡានក្រុងមួយយ៉ាងធំដឹកអ្នកដំណើរពេញ បើកក្នុងល្បឿនលឿនដែរ មកដល់កន្លែងនោះ កាច់ចង្កូតគេចចេញពីម៉ូតូ ជ្រុលទៅកិនបុរសពីរនាក់ដែលនៅកណ្ដាលថ្នល់ ហើយក៏ក្រឡាប់ ធ្លាក់ពីលើផ្លូវដីខ្ពស់នោះ ទៅសង្កត់បុរសពីរនាក់ដែលកំពុងតែបាចត្រីស្លាប់ទៀត នឹងធ្វើឱ្យអ្នកដំណើរដែលនៅក្នុងឡានស្លាប់និងរបួសយ៉ាងច្រើននាក់ថែមទៀត។

កាលពីមុនចេញដំណើរ បុរស (ង)និយាយថា (បើគ្រោះថ្នាក់ក៏គ្រោះថ្នាក់តែខ្ញុំ បើស្លាប់ក៏ស្លាប់តែខ្ញុំដែរ) ហើយដល់ឥឡូវ អ្នកណាខ្លះជាអ្នកស្លាប់ ស្លាប់តែគាត់ម្នាក់ឯង ឬ ក៏មានគេស្លាប់ដែរ ? នេះឯងដែលជាផលនៃការគិតតែពីខ្លួនឯង ដោយមិនខ្វល់ពីអ្នកដទៃ ទីបំផុតគឺបែបនេះ ស្លាប់តែឯងមិនអស់ចិត្ត នាំគេឱ្យស្លាប់ថែមទៀត។

នេះគ្រាន់តែរឿងដែលឧទាហរណ៍តែប៉ុណ្ណោះ ដែលលើកមកបញ្ជាក់ ព្រោះចង់ឱ្យប្អូនៗបានដឹងថា គ្រោះមហន្តរាយដែលកើតចេញអំពីការគិតតែពីខ្លួនឯងនោះ វាផ្តល់ផលអាក្រក់យ៉ាងណាខ្លះ ដល់ខ្លួនយើង និងសង្គមជាតិទាំងមូល ដូចនេះមិនត្រូវគិតតែពីខ្លួនឯងពេកទេ ត្រូវគិតពីអ្នកដទៃផង ព្រោះយើងជាអ្នករស់នៅក្នុងសង្គម ហើយសង្គម គឺមានការពាក់ព័ន្ធគ្នាបែបនេះ ។



" ត្រីទាំងនេះស្លាប់ ដោយសារទឹកមានជាតិពុល"

" ព្រៃឈើត្រូវខ្ទេចខ្ទី ដោយសារការកាប់បំផ្លាញរបស់មនុស្ស"



"ភ្នំសម្រាម ដែលត្រូវ ហូរចូលទៅក្នុង ទន្លេ វី ស៊ីង"



"មនុស្សស្លាប់ ប្រទេសជាតិ ខ្ទេចខ្ទី ដោយ សារសង្គ្រាម"



រូបភាពទាំងអស់នេះ គឺជាលទ្ធផលនៃការគិតតែពីខ្លួនឯង គិតត្រឹមតែពីក្រុមខ្លួនឯង គិតត្រឹមតែពីជាតិខ្លួនឯង គិតត្រឹមតែពីប្រទេសខ្លួនឯង

ដោយមិនខ្វល់ពីអ្នកដទៃ ហើយទីបំផុតគឺមហន្តរាយនេះឯង ដែលជាមរតកចុងក្រោយសម្រាប់រូបយើង និងកូនចៅយើងជំនាន់ក្រោយ ។

អ្វីដែលបានលើកមកនេះ គឺបងចង់ឱ្យប្អូនបានដឹង និងយល់ថា កាលណាបើយើងចេះតែឯង យករួចខ្លួនតែឯង ដោយមិនជួយពន្យល់ប្រាប់អ្នកដទៃផងទេនោះ ទីបំផុតយើងក៏មានបញ្ហាដែរ។ ដូច្នេះនៅពេលដែលប្អូនៗ បានស្គាល់ពីលក្ខណៈរបស់មនុស្សរួចហើយ ចូរប្អូនជួយពន្យល់ប្រាប់ និងដឹកនាំពួកគេឱ្យមករកផ្លូវត្រូវដូចប្អូនផង ព្រោះកាលណាពួកគេមិនបានដឹង គេទៅសេពគប់ជាមួយមនុស្សមិនល្អ គេក៏ទៅជាមនុស្សមិនល្អ ពេលនោះឯងដែលគេត្រូវរករឿង ឬ បង្កបញ្ហាជាមួយប្អូនៗ ព្រោះប្អូនជាមនុស្សល្អ គេជាមនុស្សអាក្រក់ ហើយការគិតរបស់មនុស្សអាក្រក់ គឺមិនស្របគ្នានឹងមនុស្សល្អទេ។ ដូច្នេះ សូមប្អូនៗកុំនៅស្ងៀម ត្រូវជួយពន្យល់ដល់ពួកគេផង ទើបបានសុខទាំងអស់គ្នា ។ តែបងដឹងថាប្អូនពិតជាលំបាក ក្នុងការទាក់ទាញចិត្តអ្នកដទៃ ដើម្បីឱ្យពួកគេទោរទន់ ស្តាប់តាមប្អូននោះ តែសូមកុំភ័យ ចូរប្អូនធ្វើតាមវិធីសាស្ត្រខាងក្រោមនេះចុះ នឹងទទួលជោគជ័យនៅក្នុងកិច្ចការនេះមិនខាន។

## វិធី៦យ៉ាងដើម្បីទាក់ទាញសន្តានចិត្តរបស់មនុស្ស[១]

១-យកចិត្តទុកដាក់ដោយស្មោះចំពោះអ្នកនោះ។

២-រក្សាស្នាមញញឹមនៅលើបបូរមាត់ជានិច្ច រាល់ពេលដែលជួបពួកគេ។

៣-សូមចាំទុកថា គេចាត់ទុកឈ្មោះរបស់គេ ជាសម្លេងមួយដ៏ពិរោះបំផុត សំខាន់បំផុត លើសសម្លេងដទៃទៀត (បើឈ្មោះគេមានពីរ ឈ្មោះណាពិរោះ ហៅឈ្មោះនោះចុះ ហើយប្រកបដោយទឹកដមសម្លេងផង)។

៤-ត្រូវចេះស្តាប់អ្នកដទៃ និយាយលើកទឹកចិត្តពួកគេនិយាយពីពួកគេ ។

៥-ពួកគេចូលចិត្តអ្វី អ្នកត្រូវនិយាយជាមួយពួកគេដោយប្រការនោះ។

៦-ត្រូវចេះស្មោះស្ម័គ្រ ធ្វើឱ្យពួកគេឃើញអំពីប្រការសំខាន់របស់ខ្លួនគេផ្ទាល់។

---

១ ចិត្តសាស្ត្រអនុវត្តន៍ ទំព័រ ១១៩

វិធីសាស្ត្រទាំង៦នេះ គ្រាន់តែធ្វើឱ្យគេចាប់អារម្មណ៍មកលើរូបប្អូនតែប៉ុណ្ណោះ វាជាការពិតណាស់ នៅពេលដែលយើងចង់ចូលរួមចំណែកក្នុងកិច្ចការអ្វីមួយ ជំហានដំបូង ត្រូវធ្វើឱ្យគេចាប់អារម្មណ៍មកលើរូបយើងឱ្យបានច្រើន ដើម្បីបានឱកាសចូលទៅជិតពួកអ្នកទាំងនោះ។ នៅពេលដែលមានឱកាសហើយ មិនត្រូវធ្វើសេចក្តីស្និទ្ធស្នាល ឱ្យហួសប្រមាណទេ ព្រោះវាបាត់បង់នូវការគោរព ប្អូនត្រូវចាំថា ត្រូវចេះធ្វើខ្លួនឱ្យគេស្រឡាញ់តែត្រូវចៀសវាងការស្និទ្ធស្នាលហួសប្រមាណ។

តើរូបស្អាតនិងទ្រព្យសម្បត្តិឬ ដែលជាតម្លៃពិតរបស់មនុស្ស? តើអ្នករស់នៅដើម្បីអ្វី? អ្វីខ្លះដែលអ្នកគិតថាជាភាពសំខាន់របស់មនុស្ស ?




សេចក្តីល្អជាលម្អនៃជីវិត

ម្យ៉ាងទៀតត្រូវចាំថា យើងមកទីនេះ មិនមែនមកដើម្បីសូមសេចក្ដីស្នេហាពីអ្នកដទៃទេ គឺមកពន្យល់ ឱ្យអ្នកនោះបានយល់ និង ធ្វើនូវសេចក្ដីល្អ ដូចដែលប្អូនបានយល់និងធ្វើរួចមកហើយ ។ ដូច្នេះ ប្អូនត្រូវណែនាំពួកគេ ដើម្បីឱ្យគេធ្វើតាមពាក្យដ៏ល្អរបស់ប្អូន ដែលបានមកពីការពិចារណាដោយត្រឹមត្រូវទៅតាមផ្លូវរបស់សប្បុរស ឱ្យអស់ពីចិត្តនិងសមត្ថភាពដែលខ្លួនមាន ។

នៅក្នុងការណែនាំនោះ ប្អូនត្រូវអនុវត្តតាមវិធីសាស្ត្រខាងក្រោមនេះទើបទទួលបានលទ្ធផលល្អ ។

## វិធីសាស្ត្រ ១២ យ៉ាងធ្វើឱ្យគេជឿស្ដាប់តាមខ្លួន[១]

១-វិធីសាស្ត្រមានតែមួយក្នុងការប្រកែកគ្នា គឺចៀសវាងការមិនប្រកែកនោះឯង ។

២-គោរពលើកតម្កើងនូវយោបល់របស់គេ ។ កុំប្រាប់ថាគេខុស ។

---

១ ចិត្តសាស្ត្រអនុវត្តន៍ ទំព័រ ១៩២

៣-បើអ្នកខុស អ្នកប្រញាប់សារភាពដោយរួសរាយភ្លាមទៅកាន់ពួកគេ ។

៤-គួរតែសុភាពនិងផ្អែមល្ហែម មិនត្រូវកោងកាច ។

៥-លើកសំណួរឡើង ហើយត្រូវធ្វើយ៉ាងណា ឱ្យគេឆ្លើយថា "បាទ" រឺ "ត្រូវ" ។

៦-ទុកឱ្យគេនិយាយឱ្យអស់ចិត្តសិនចុះ ។

៧-ធ្វើឱ្យគេជឿថា គឺខ្លួនគេផ្ទាល់ ជាអ្នកបានបញ្ចេញមតិយោបល់ ឬជាអ្នកគិតឃើញ នូវគំនិតដែលអ្នកបានលើកឡើងឱ្យគេនោះ ។

៨-ខំប្រឹងវិនិច្ឆ័យដោយស្មោះ តាមទស្សនៈអ្នកដទៃ (ទុកដាក់ខ្លួនជាអ្នកដទៃ) ។

៩-នរណាក៏ស្រេកឃ្លានចង់ឱ្យអ្នកដទៃស្រឡាញ់រាប់អាន ទទួលស្គាល់ និងអាណិតអាសូរខ្លួនដែរ ។ ដូច្នេះ ចូរអ្នកផ្តល់ជូនពួកគេដោយប្រការទាំងនោះចុះ ។

១០-បំផុសឱ្យគេមានមនោសញ្ចេតនាដ៏ថ្លៃថ្លា និងសេចក្តីថ្លៃថ្នូររបស់គេ ។

១១-ជំរុញចក្ខុវិញ្ញាណ និងគំនិតពិចារណារបស់គេ ។

១២-សាកល្បងបំផុសកំហឹង ដើម្បីឱ្យគេមានការប្តេជ្ញាចិត្ត ។

វិធីទាំង១២នេះ នៅពេលដែលយើងអនុវត្ត ប្រាកដជាទទួលបានលទ្ធផលល្អ តែមិនប្រាកដថាបានគ្រប់ទាំងអស់នោះទេ ព្រោះមានមនុស្សខ្លះក៏មិនងាយនឹងធ្វើតាមអ្នកដទៃដែរ បើគេមិនឃើញច្បាស់និងភ្នែកទេនោះមានន័យថាគេមិនទាន់ជឿទុកចិត្តនៅឡើយ ។

☞ មូលដ្ឋាន ៤ យ៉ាងឱ្យអ្នកដទៃជឿទុកចិត្ត

១-លទ្ធភាព និង សមត្ថភាព

២-ទីកន្លែង និង ពេលវេលា

៣-សិល្បៈក្នុងការនិយាយ

៤-ការទទួលខុសត្រូវ

-**សមត្ថភាព** ត្រូវបញ្ចេញសកម្មភាពធ្វើកិច្ចការនោះៗ ដោយមោះមុត ទៅតាមអ្វីដែលខ្លួនបានចេះចាំប្រាកដហើយ **លទ្ធភាព** ត្រូវធ្វើយ៉ាងណា ដើម្បីឱ្យឃើញថា ការងារដែលអ្នកបានធ្វើនោះ ពិតជាទទួលបានផលល្អពិតប្រាកដមែន ។

-**ទីកន្លែង** ជាកន្លែងដែលមានបរិយាកាសល្អ ដោយមិនមានអ្វីមករំខានដល់កិច្ចការនោះៗ ។ **ពេលវេលា** ជាពេលមួយដ៏ពេញលេញសម្រាប់ធ្វើកិច្ចការនោះ ពេលវេលាសម្រាប់ធ្វើគម្រោងការ ពេលវេលា

សម្រាប់ចាត់ចែងការងារ ពេលវេលាសម្រាប់ដឹកនាំ ឬ ណែនាំ និង ពេលវេលា សម្រាប់ត្រួតពិនិត្យ រឺ មើលនូវកិច្ចការទាំងនោះឡើងវិញ ។

**-សិល្បៈក្នុងការនិយាយ** អ្នកនិយាយត្រូវដឹងថា ពាក្យនោះប្រែដូចម្តេច មានន័យយ៉ាងម៉េច គោលដៅនៃពាក្យនោះសំដៅទៅលើអ្វី ពាក្យដែលនិយាយទៅនោះ វាមានប្រយោជន៍អ្វីខ្លះ ។ សម្លេងនៃការនិយាយ ត្រូវលើកដាក់ទៅតាមឃ្លា ឬ ប្រយោគ មិនយឺតមិនលឿន ម៉ាត់...ម៉ាត់...មួយម៉ាត់ស្តាប់បានទាំងអស់ និយាយធ្វើសម្លេងឱ្យស្រទន់ និយាយពាក្យសាមញ្ញខ្លី ហើយងាយយល់ ។ ត្រូវមើលបុគ្គលដែលអ្នកត្រូវនិយាយជាមួយនោះផង ថា អ្នកនោះមានកិរិតវប្បធម៌ត្រឹមណោ មានបញ្ញាស្មារតីយ៉ាងម៉េច ចំណង់ចំណូលចិត្តយ៉ាងម៉េច គឺត្រូវលៃលកឱ្យបានសមទៅតាម ឋានៈ វ័យ ភេទ និងចំណេះដឹងរបស់បុគ្គលនោះ ។

**-ការទទួលខុសត្រូវ** គឺទទួលយកនូវផលអ្វីដែលខ្លួនបានធ្វើ និងចេញមុខដោះស្រាយនូវបញ្ហាដែលបានកើតឡើង អំពីការងារនោះដោយសន្តិវិធី និងយុត្តិធម៌ ហើយនិងតាំងចិត្តថា នេះជាកត្តព្វកិច្ចរបស់អាត្មាអញ ។

នៅពេលដែលមូលដ្ឋានទាំង៤នេះ បានចាក់គ្រឹះមាំទៅក្នុងខ្លួនរបស់យើងហើយ អ្នកដទៃនឹងជឿទុកចិត្តយ៉ាងមុតមាំមកលើរូបប្អូន នេះ

ចំពោះអ្នកដែលយល់ ។ នៅក្នុងចំណោមអ្នកដែលជឿជាក់នោះ មិនប្រាកដថាមានចរិតដូចគ្នាទេ អ្នកខ្លះនិយាយមិនស្រួលខឹង អ្នកខ្លះទៀតទោះបីយើងនិយាយជ្រុលជ្រួសបន្តិចបន្តួចក៏មិនអីដែរ។ ថ្វីត្បិតតែពួកគេមានទិសដៅតែមួយ គឺការជឿជាក់មកលើខ្លួនប្អូនពិតមែន តែបើអធ្យាស្រ័យខុសគ្នា ក៏អាចធ្វើឱ្យមានបញ្ហាបានដែរ នៅក្នុងការណែនាំពួកគេនោះ។ ដូចនេះ ប្អូនត្រូវធ្វើយ៉ាងណា ក្នុងការកែប្រែពួកគេ ដោយមិនឱ្យគេទាស់ចិត្តនឹងយើង ។ បែបនេះទើបជៀសវាងការឈ្លោះប្រកែកគ្នាបាន ។

### ☺- វិធីកែមនុស្ស៥យ៉ាងដែលមិនឱ្យគេខឹងប្រឡោក[១]

១-មុនដំបូងត្រូវសរសើរគេពីរបីម៉ាត់សិន ដោយស្មោះអំពីចិត្ត

២-យកគំនិតដែលធ្វើឱ្យគេយល់ឃើញថានេះជាកំហុសឆ្គង។

៣-មុនពេលរិះគន់ ត្រូវសារភាពកំហុសរបស់ខ្លួនអ្នកជាមុនសិន សឹមបន្ទោសគេក្រោយ ។

---

១ ចិត្តសាស្ត្រអនុវត្តន៍ ទំព័រ ២២២

៤-កុំបញ្ជារ កុំស្តីបន្ទោស តែត្រូវចោទជាសំណួរ ដើម្បីចង្អុលប្រាប់គេ ។

៥-ត្រូវរក្សាកិត្តិយសឱ្យគេ ។

៦-ទទួលស្គាល់ការខំប្រឹងប្រែងរបស់គេ ដោយស្មើភាព ទោះបីគេទើបតែនឹងលូតលាស់បន្តិចបន្តួចក៏ដោយ ក៏ត្រូវតែសរសើរគេដែរ ។ ពាក្យលើកទឹកចិត្តរបស់អ្នក ត្រូវស្មោះត្រង់និងមានសប្បុរសធម៌ ។

៧-លើកតម្កើងគេ ដើម្បីឱ្យគេខំប្រឹងប្រែង ឱ្យសមទៅនឹងសម្តីដែលយើងសរសើរ ។

៨-លើកទឹកចិត្តគេ ឱ្យឃើញថា ងាយស្រួលកែប្រែកំហុសឆ្គង ហើយឃើញថាកិច្ចការធូរស្រាលទៅ ។

៩-ដោះស្រាយយ៉ាងណា ឱ្យគេមានអារម្មណ៍សប្បាយរីករាយ ដើម្បីទទួលធ្វើកិច្ចការដែលយើងពឹងពាក់ ។

ទាំង៩ចំណុចនេះ សូមប្អូនៗត្រិះរិះគិត ឱ្យបានស៊ីជម្រៅ នៅត្រង់ចំណុចទីមួយៗ ដើម្បីងាយស្រួលក្នុងការអនុវត្ត ។ ពេលប្អូនអនុវត្តទៅតាមចំណុចទាំងនេះហើយ អ្នកដែលប្អូនត្រូវណែនាំនោះ ប្រាកដជាគោរពនិងធ្វើតាម នូវអ្វីដែលប្អូនបានប្រាប់ហើយដោយពេញចិត្តជាទីបំផុត

ព្រោះគេយល់ថាប្អូនជាមនុស្សចេះយល់ចិត្ត យល់ថ្លើមរបស់គេ ហើយប្អូននឹងទៅជាមនុស្សម្នាក់ដែលមានមន្តស្នេហ៍ ក្នុងក្រសែភ្នែកអ្នកដទៃ ។

